# របាយការណ៍ប្រចាំឆ្នាំ

## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

# ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក



# ទស្សនវិស័យ

ឌី ប៊ី ឌី មានគោលបំណងអភិវឌ្ឍសមត្ថភាពរបស់ថ្នាក់ដឹកនាំរបស់ខ្លួន ដើម្បីបម្រើអតិថិជនទូទាំងប្រទេសកម្ពុជាក្នុងរយៈពេល ៣ (បី) ឆ្នាំខាងមុខនេះ ជាពិសេសសម្រាប់ខេត្តព្រះសីហនុ និងសៀមរាប។

# បេសកកម្ម

បេសកកម្មរបស់ ឌី ប៊ី ឌី គឺធ្វើឲ្យកេរ្តិ៍ឈ្មោះរបស់ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ពោពេញដោយគុណភាព ភាពឥតខ្ចោះ ទំនួលខុសត្រូវខ្ពស់ ភាពឆ្លាតវៃ និងសេវាកម្មបម្រើអតិថិជន ប្រកបដោយការប្រកួតប្រជែង ឲ្យនៅថិតថេរដូចដែលមានតាំងពីឆ្នាំ ១៩៩៥ មកម្លេះ។

# តម្លៃស្នូលរបស់យើង

យើងជឿជាក់លើក្រុមការងារបច្ចេកទេសរបស់យើង បុគ្គលិកគ្រប់កម្រិតរបស់យើង និងការប្តេជ្ញាចិត្តរបស់យើង ដើម្បីពង្រីកក្រុមហ៊ុនឲ្យក្លាយជាក្រុមហ៊ុនលំដាប់ពិភពលោក។ ពោលគឺ ក្រុមហ៊ុនរបស់យើងផ្តល់នូវសេវាកម្មជូនអតិថិជនដោយប្រកាន់ខ្ជាប់នូវៈ

| | | |
|---|---|---|
| ជំនាញឯកទេសពិតប្រាកដ | ប្រកបដោយវិជ្ជាជីវៈ | គុណភាព និងសុវត្ថិភាព |



# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| | | បានធ្វើសវនកម្ម ២០២១ | បានធ្វើសវនកម្ម ២០២០ | បានធ្វើសវនកម្ម ២០១៩ |
|---|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល)** | | | | |
| ទ្រព្យសកម្មសរុប | | ៦៦.៥៤០.៧៤៨ | ៤០.៤០៩.២៨០ | ៤០.៩៩៥.៨១៤ |
| បំណុលសរុប | | ២៩.៦៤៩.៨៥១ | ២០.៧១៤.២៤៨ | ២២.៣៩៧.១០៦ |
| មូលធនសរុប | | ៣៦.៨៩០.៨៩៧ | ១៩.៦៩៥.០៣២ | ១៨.៥៩៨.៧០៨ |
| **លទ្ធផលហិរញ្ញវត្ថុ** | | | | |
| ចំណូលសរុប | | ៧៣.០៧៨.៤៨០ | ៥៤.៨៨៩.៤១៧ | ៣៥.១២៩.០២៥ |
| ចំណេញ /(ខាត) មុនបង់ពន្ធ | | ២.៤១០.០៣០ | ១.៨១៣.៧៨៨ | ៤.៧២០.០៨៩ |
| ចំណេញ /(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | | ១.៦៧៨.៧៩១ | ១.២៤៣.០០៤ | ៤.៤៥៨.៤៥៩ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ១.៨៤៥.១០៩ | ១.០៩៦.៣២៤ | ៤.៦៨៤.៦០៣ |
| **អនុបាតហិរញ្ញវត្ថុ** | | | | |
| អនុបាតសាធនភាព | | ៨,១៣% | ៩,១៥% | ២០,៩១% |
| អនុបាតបំណុលធៀបនឹងមូលធន | | ៨០,៣៧% | ១០៥,១៧% | ១២០,៤២% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ២,១០ | ១,៨៦ | ១,៨៧ |
| | អនុបាតចរន្តលឿន | ១,៦៧ | ១,៣២ | ១,៣៩ |
| អនុបាតគម្លាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | ២,៧៧% | ២,៧១% | ១១,៤៣% |
| | អនុបាតចំណេញធៀបនឹងមូលធន | ៥,០០% | ៥,៥៧% | ២៥,១៩% |
| | អនុបាតគម្លាតចំណេញដុល | ១៤,២២% | ១៦,៧៨% | ២១,៤៨% |
| | អនុបាតគម្លាតចំណេញភាព | ២,៥២% | ២,០០% | ១៣,៣៤% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៩៩,៩៤ | ៩១,៣៦ | ១,៦៤៣,៧២០.៣៥ |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | ២,១៧ | ២,២០ | ១០,៦៨ |
| | | | | |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# សមាសភាពក្រុមប្រឹក្សាភិបាល



**លោក នាង វិធី**

ប្រធានក្រុមប្រឹក្សាភិបាល



**លោក ថៃ វ៉ាន់ថា**

អភិបាលមិនប្រតិបត្តិ



**លោកស្រី លឹម មុយលី**

អភិបាលប្រតិបត្តិ



**លោក ហ៊ុយ វ៉ាថារ៉ូ**

អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង

តំណាងអោយក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញរបាយការណ៍ប្រចាំឆ្នាំរបស់យើងខ្ញុំ នៅចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២១ ដល់ភាគីពាក់ព័ន្ធទាំងអស់។

នៅក្នុងឆ្នាំ២០២១ ក្រុមហ៊ុនទទួលបានប្រាក់ចំណូលសរុប ៧៣.០៧៨.៤៨០ ពាន់រៀល ដែល ៧១.៤៦១.៦៩៨ ពាន់រៀល ជាចំណូលបានមកពីគម្រោងសាងសង់ និងសេវាជុសជុលថែទាំ និង ១.៦១៦.៧៨២ ពាន់រៀល ជាចំណូលបានមកពីលក់សម្ភារៈសំណង់។ បើធៀបនឹងឆ្នាំ ២០២០ មានការកើនឡើង ៣៣,១៤% ដែលជាលទ្ធផល ក្រុមហ៊ុនទទួលបានប្រាក់ចំណេញចំនួន ១.៦៧៨.៧៩១ ពាន់រៀល។ ទ្រព្យសកម្មសរុបកើនឡើង ៦៤,៦៧% បើធៀបនឹងឆ្នាំ ២០២០ ពី ៤០.៤០៩.២៨០ ពាន់រៀល ទៅ ៦៦.៥៤០.៧៤៨ ពាន់រៀល។

ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិក សម្រាប់ដំបូន្មានល្អៗ និងការខិតខំប្រឹងប្រែងរបស់អ្នក សម្រាប់ការរីកចម្រើនប្រកបដោយនិរន្តរភាពរបស់ក្រុមហ៊ុន។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ និយ័តករមូលបត្រកម្ពុជា និងភាគហ៊ុននិក ដែលផ្តល់ទំនុកចិត្ត និងការគាំទ្រដល់ក្រុមហ៊ុន ឌី ប៊ី ឌី ។

កាលបរិច្ឆេទ: ១២ មេសា ២០២២

DBD ENGINEERING Plc. KINGDOM OF CAMBODIA

ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង

លោក នាង វិធី

# មាតិកា


ទស្សនវិស័យ និងបេសកកម្ម ... ១
តម្លៃស្នូល ... ១
ព័ត៌មានហិរញ្ញវត្ថុសង្ខេប ... ២
ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ... ៣
សមាសភាពក្រុមប្រឹក្សាភិបាល ... ៤
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ... ៥
ផ្នែកទី១: ព័ត៌មានទូទៅអំពីក្រុមហ៊ុន ... ៧
ក. អត្តសញ្ញាណរបស់ក្រុមហ៊ុន ... ៧
ខ. ទិដ្ឋភាពទូទៅរបស់ក្រុមហ៊ុន ... ៧
គ. សម្ព័ន្ធភាព ... ៧
ឃ. ព្រឹត្តិការណ៍សំខាន់ៗ ... ៨
ង. ស្ថានភាពទីផ្សារ ... ៨
ច. ស្ថានភាពប្រកួតប្រជែង ... ៨
ឆ. ផែនការអនាគត ... ៩
ជ. កត្តាហានិភ័យ និងវិធានការកាត់បន្ថយ ... ៩
ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន ... ១៤
១. លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន ... ១៤
២. រចនាសម្ព័ន្ធចំណូល ... ១៤
ផ្នែកកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម ... ១៥
ផ្នែកកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក ... ១៧
ផ្នែកកទី៥: របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ ... ១៩
ផ្នែកកទី៦: របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង ... ២០
ផ្នែកកទី៧: ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍ ... ២១
ផ្នែកកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ... ២២
ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ... ២២
ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេ ... ២៣
គ. ការប្រែប្រួលសំខាន់ៗលើចំណូល និងការលក់ ... ២៤
ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណបរទេស អត្រាការប្រាក់ និងថ្លៃទំនិញ ... ២៤
ង. ផលប៉ះពាល់នៃអតិផរណា ... ២៤
ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ... ២៤
ហត្ថលេខារបស់អភិបាល ... ២៥
ឧបសម្ព័ន្ធនៃរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មឆ្នាំ២០២១ ... ២៦
ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ២០២១ ... ៧៧

# ផ្នែកទី១: ព័ត៌មានទូទៅអំពីក្រុមហ៊ុន

## ក. អត្តសញ្ញាណរបស់ក្រុមហ៊ុន

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ: | **ឌីប៊ីឌី អ៊ិនជីនារីង ម.ក** |
| ជាអក្សរឡាតាំង: | DBD Engineering Plc. |
| លេខកូដសម្គាល់ដារ: | KH1000150008 |
| ទីស្នាក់ការ: | ដីឡូត៍ ៦៨ ផ្លូវ ៥៩៨ សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរសព្ទ: | (+៨៥៥) ០៧៨ ៧០០ ៥៩៨ |
| គេហទំព័រ: | dbdengineering.com |
| អ៊ីម៉ែល: | services@dbdengineering.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម: | ០០០០៤០២៩, ចុះថ្ងៃទី ១០ ខែមិនា ឆ្នាំ១៩៩៨ ចេញដោយ ក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម: | ៨៧០ នសគប / ១២ ស, ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២១ ចេញដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីលក់មូលបត្រ: | ១២៣/២១/ស.ស.រ/ន.ម.ក, ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២១ ចេញដោយ និយ័តករមូលបត្រកម្ពុជា |
| អ្នកតំណាងក្រុមហ៊ុន: | លោក នាង វិធី |

## ខ. ទិដ្ឋភាពទូទៅរបស់ក្រុមហ៊ុន

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក(ឌី ប៊ី ឌី) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ជាក្រុមហ៊ុនពហុមុខងារ ផ្នែកវិស្វកម្ម និងសំណង់ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងព្រះរាជាណាចក្រកម្ពុជា។ ឌី ប៊ី ឌី ផ្តល់សេវាកម្មដូចជា សេវាគូសប្លង់ សាងសង់ ដំឡើង និងថែទាំ ដែលសេវាកម្មទាំងនេះធ្វើអោយក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះលំដាប់ជាតិ និងអន្តរជាតិ។ ឌី ប៊ី ឌី ទទួលបានកំណត់ត្រាល្អក្នុងការផ្តល់សេវាកម្ម និងផ្គត់ផ្គង់ផលិតផល ប្រកបដោយគុណភាពខ្ពស់ ដែលស្តែងបញ្ជាក់តាមរយៈការពេញចិត្ត និងការសរសើរពីសំណាក់អតិថិជនរបស់ខ្លួន។

ឌី ប៊ី ឌី មានក្រុមបុគ្គលិកជំនាញផ្នែកសេវាកម្ម និងការថែទាំ ដើម្បីធានា និងរក្សាគុណភាពជាប់រឹងមាំរបស់សំណង់អគារ ឬការបំពាក់ឧបករណ៍ថ្មី ហើយបច្ចុប្បន្ននេះ ឌី ប៊ី ឌី បាននឹងកំពុងពង្រីកអាជីវម្មផ្នែក ផលិតកម្មលើប្រព័ន្ធបំពង់ គ្រឿងចក្រ ការថែរក្សារោងចក្រ និងឧបករណ៍។

## គ. សម្ព័ន្ធភាព

| ល.រ | ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយនៃការកាន់កាប់ភាគហ៊ុន | អាជីវកម្មចម្បង | កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម | ទីតាំងអាជីវកម្ម |
|---|---|---|---|---|---|---|
| ១ | មិនមាន | | | | | |

### ឃ. ព្រឹត្តិការណ៍សំខាន់ៗ

- នាថ្ងៃព្រហស្បតិ៍ ទី១៦ ខែធ្នូ ឆ្នាំ២០២១ ក្រុមហ៊ុន ឌី បី ឌី បានទទួលគម្រោងសម្រាប់ការងារ MEP របស់ Wing Office Tower ដែល កិច្ចសន្យាមានទំហំទឹកប្រាក់ ៦លានដុល្លារអាមេរិក ដោយមិនរាប់បញ្ចូលពន្ធលើតម្លៃបន្ថែម។
- បច្ចុប្បន្នក្រុមហ៊ុន ឌី បី ឌី កំពុងធ្វើការលើប្រព័ន្ធថ្មីមួយសម្រាប់គ្រប់គ្រងវត្តមានរបស់បុគ្គលិក និងកម្មករ តាមរយៈប្រព័ន្ធអ៊ីនធឺណេត។ វាសម្រួលដល់គណៈគ្រប់គ្រងដើម្បីទទួលបានរបាយការណ៍ភ្លាមៗ កាន់តែងាយស្រួលលើការរៀបចំគ្រប់គ្រង និងត្រួតពិនិត្យកម្លាំងពលកម្ម ដើម្បីកាត់បន្ថយការខ្វះខាតកម្លាំងពលកម្ម។ ឥឡូវនេះប្រព័ន្ធថ្មីនេះត្រូវបានសាកល្បងនៅការិយាល័យកណ្តាលក្រុមហ៊ុន ឌី បី ឌី មុនពេលត្រូវដាក់ឱ្យអនុវត្តនៅគ្រប់ការដ្ឋានសាងសង់នៅពេលក្រោយ។
- នៅថ្ងៃព្រហស្បតិ៍ ទី ២៣ ខែកញ្ញា ឆ្នាំ ២០២១ ក្រុមប្រឹក្សាភិបាលបានអនុម័តលើកញ្ចប់ថវិកាចំនួន ២,៥ លានដុល្លារអាមេរិក សម្រាប់ការសាងសង់ទីស្នាក់ការកណ្តាលថ្មីរបស់ក្រុមហ៊ុន ឌី បី ឌី និងអគារសម្រាប់សង្វាក់ផលិតកម្ម ហើយអគារទីស្នាក់ការនេះនឹងត្រូវបានសាងសាង់ដោយ ក្រុមហ៊ុន ឌី បី ឌី ខ្លួនឯងផ្ទាល់។
- នៅថ្ងៃច័ន្ទ ទី ៦ ខែកញ្ញា ឆ្នាំ ២០២១ មានប្រារព្ធពិធីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធជាផ្លូវការរបស់ក្រុមហ៊ុន ឌី បី ឌី នៅឯទីស្នាក់ការក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX)។ ភាគហ៊ុនរបស់ក្រុមហ៊ុន ឌី បី ឌី ចំនួន ៦.៤៦១.៥៣៨ ត្រូវបានលក់ចេញតាមការបញ្ជាទិញពីអ្នកវិនិយោគលើសពីចំនួនដែលបានបោះផ្សាយ។

### ង. ស្ថានភាពទីផ្សារ

ឱកាសក្នុងវិស័យសំណង់មានការថយចុះ គម្រោងចំនួន ៤.៣០៣ ត្រូវបានអនុម័តក្នុងឆ្នាំ ២០២១ ដែលស្មើនឹង ៥,៣៣ ពាន់លានដុល្លាអាមេរិក ថយចុះ ៣១,២១% បើធៀបនឹងឆ្នាំ២០២០ ដែលមានគម្រោងចំនួន ៤.៨៤១ ត្រូវបានអនុម័តស្មើនឹង ៧,៧៥ ពាន់លានដុល្លាអាមេរិក។ ការព្យាករណ៍ឱកាសកើនឡើងនៃឧស្សាហកម្មសំណង់មាន ៦.៧៦០ គម្រោងដែលបានអនុម័តក្នុងឆ្នាំ ២០២២ ស្មើនឹង ១៥,៥២ ពាន់លានដុល្លាអាមេរិក។ ឌី បី ឌី គឺជាក្រុមហ៊ុនសំណង់ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើការផ្តល់សេវាកម្ម MEP ដែលមានដូចជា (១) ផ្នែកមេកានិច និងអគ្គិសនី (២) ប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ (៣) កម្តៅ ខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់ និង (៤) ការថែទាំអគារ ដូច្នេះវាពិតជាឱកាសដ៏ល្អសម្រាប់ ឌី បី ឌី នៅក្នុងទីផ្សារកំណើននេះ។

### ច. ស្ថានភាពប្រកួតប្រជែង

ក្រុមហ៊ុន ឌី បី ឌី មានកេរ្តិ៍ឈ្មោះល្បីដ៏យូរអង្វែង និងបណ្តាញទំនាក់ទំនងអាជីវកម្មជាច្រើន ដែលជាហេតុធ្វើឱ្យ ក្រុមហ៊ុន ឌី បី ឌី ឈានមុខគេលើវិស័យសំណង់នាបច្ចុប្បន្ននេះ។ ក្រុមហ៊ុនមាន ចំណុចខ្លាំង និងគុណសម្បត្តិប្រកួតប្រជែងសំខាន់ៗមួយចំនួនដូចខាងក្រោម ដើម្បីទ្រទ្រង់អាជីវកម្ម ក៏ដូចជាគាំទ្រដល់ការរីកចម្រើនរហូតមក÷

១. ការគ្រប់គ្រងកិច្ចសន្យាប្រកបដោយជំនាញ និងជំនាញក្នុងការដោះស្រាយបញ្ហាហិរញ្ញវត្ថុកិច្ចសន្យាសាងសង់ រួមទាំងតម្លៃប្រកួតប្រជែង

២. ការបញ្ចប់គម្រោងទាន់ពេលវេលា ដោយក្រុមថ្នាក់ដឹកនាំជាន់ខ្ពស់ និងវិស្វករដែលមានបទពិសោធន៍យូរឆ្នាំ និងមានការយកចិត្តទុកដាក់ខ្ពស់

៣. រៀបចំឱ្យមានការត្រួតពិនិត្យគុណភាព សុវត្ថិភាព និងបរិស្ថានដ៏តឹងរឹង និង

៤. បង្កើនទំនាក់ទំនងជាមួយ អតិថិជនជានិច្ច

## ឆ. ផែនការអនាគត

ក្រុមហ៊ុនមានគោលបំណងរក្សានូវ ទីផ្សារឈានមុខគេផ្នែកការងារ MEP និងបង្កើនការលក់ និងការរួមចំណែកទីផ្សារ ដោយរក្សានូវកេរ្តិ៍ឈ្មោះដ៏ល្អរបស់ខ្លួនតាមរយៈយុទ្ធសាស្រ្តដូចខាងក្រោមៈ

- បង្កើនការរួមចំណែកទីផ្សារដែលផ្តោតទៅលើ គម្រោងការងារ MEP នាបច្ចុប្បន្ន។
- ធ្វើការពង្រឹងសេវាកម្មស្នូលដែលមានស្រាប់របស់ក្រុមហ៊ុន (MEP & Civil Engineering) ជាបន្តបន្ទាប់ និងពង្រីកខ្សែសង្វាក់ផលិតកម្មផ្នែកប្រព័ន្ធ Ducting ដោយការប្រើប្រាស់ផ្ទាល់រហូតដល់រោងចក្រដែលនឹងអាចផ្គត់ផ្គង់ដល់អ្នកម៉ៅការផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។
- ធ្វើឱ្យប្រសើរឡើងនូវភាពមើលឃើញសេវាកម្ម និងភាពជឿជាក់របស់ក្រុមហ៊ុនក្នុងចំណោមសាធារណៈជន ដោយធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិជាលើកដំបូង (IPO) ព្រមទាំងបង្កើនការផ្សព្វផ្សាយបន្ថែមទៀតលើទីផ្សារ សម្រាប់ការរីកចម្រើនរយៈវែងរបស់ក្រុមហ៊ុន។

សរុបមក ក្រុមហ៊ុន ឌី ប៊ី ឌី នឹងរក្សាកេរ្តិ៍ឈ្មោះរបស់ខ្លួនដែលអនុញ្ញាតឱ្យមានការរីកចម្រើនអាជីវកម្ម ដោយផ្តោតលើអ្វីដែលបានធ្វើឱ្យវាទទួលបានជោគជ័យរហូតមកដល់បច្ចុប្បន្ន បញ្ចប់គម្រោងជូនអតិថិជនទាន់ពេលវេលាប្រកបដោយគុណភាពខ្ពស់ក្នុងតម្លៃប្រកួតប្រជែង ជាមួយនឹងសេវាកម្មដ៏ល្អឥតខ្ចោះ។

## ជ. កត្តាហានិភ័យ និងការកាត់បន្ថយ

### - ហានិភ័យនៃការប៉ាន់ស្មានតម្លៃទាប

គម្រោងភាគច្រើនក្រុមហ៊ុន ឌី ប៊ី ឌី ដែលទទួល ត្រូវបានណែនាំតាមរយៈអតិថិជនរបស់ក្រុមហ៊ុន ឌី ឬតាមរយៈការចូលរួមដេញថ្លៃ។ ហានិភ័យដែលនឹងអាចកើតមាននៅពេលដែលឌី ប៊ី ឌី ប៉ាន់ស្មានតម្លៃទាប នៅពេលដេញថ្លៃគម្រោង ដោយសារការប៉ាន់ស្មានតម្លៃទាបពេក លើតម្លៃសម្ភារៈ ឬកម្លាំងពលកម្ម។ មានកត្តាជាច្រើនដែលអាចនាំឱ្យមានការប៉ាន់ប្រមាណតម្លៃទាប រួមមាន កំហុសក្នុងគំនូសព្រាង ភាពខុសគ្នានៃលក្ខណៈបច្ចេកទេស ការប្រែប្រួលតម្លៃសម្ភារៈនៅលើទីផ្សារ។ ការប៉ាន់ប្រមាណតម្លៃទាបជាងតម្លៃជាក់ស្តែងនៃគម្រោងអាចមានផលប៉ះពាល់អវិជ្ជមានលើប្រាក់ចំណេញ។

**វិធានការកាត់បន្ថយ:** ក្រុមហ៊ុនបានបង្កើតស្តង់ដារ និងគោលការណ៍ណែនាំយ៉ាងក្បោះក្បាយសម្រាប់រាល់ការដេញថ្លៃគម្រោងដែលរួមមានបីដំណាក់កាល៖ (១) ការស្ទង់មតិដែលដឹកនាំដោយក្រុមអ្នកស្ទង់មតិ (២) ការប៉ាន់ប្រមាណតម្លៃទៅលើគម្រោង និង (៣) សុពលភាពដែលត្រូវបានត្រួតពិនិត្យដោយអ្នកដេញថ្លៃដែលទទួលការអនុញ្ញាត។ ដំណើរការត្រួតពិនិត្យការដេញថ្លៃ ត្រូវបានធ្វើឡើងដោយអ្នកជំនាញរបស់ក្រុមហ៊ុនក្នុងនោះរួមមានក្រុមអ្នកជំនាញផ្នែកច្បាប់ និងអ្នកជំនាញបច្ចេកទេស ដែលត្រួតពិនិត្យឡើងវិញនូវគំនូសព្រាង និងលក្ខណៈបច្ចេកទេស ព្រមទាំងធ្វើការត្រួតពិនិត្យការអនុវត្តនៅនឹងការដ្ឋាននៃគម្រោងនីមួយៗ។

### - ហានិភ័យនៃកង្វះខាតសម្ភារៈ និងការប្រែប្រួលតម្លៃ

ក្រុមហ៊ុន ឌី ប៊ី ឌី ពឹងផ្អែកយ៉ាងខ្លាំងលើការផ្គត់ផ្គង់ និងទំនិញដែលបញ្ជាទិញពីទីផ្សារក្រៅប្រទេស ដោយសារការកង្វះខាត នៅក្នុងប្រទេសកម្ពុជា។ ជាធម្មតា តម្លៃទំនិញទាំងនោះ មានការប្រែប្រួលប្រហែលពី ៣% ទៅ ៥% ក្នុងមួយឆ្នាំ។ តម្លៃ និងវត្តមានរបស់ទំនិញជារួម អាចរងផលប៉ះពាល់បណ្តាលមកពីកត្តាជាច្រើន ដូចជា តម្រូវការទីផ្សារ និងស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ការប្រែប្រួលអាកាសធាតុ តម្លៃប្រេងឥន្ធនៈ និងស្ថានភាពនយោបាយជាដើម។ ដោយសារលក្ខណៈនៃអាជីវកម្មរបស់ខ្លួន ឌី ប៊ី ឌី ត្រូវបានតម្រូវឱ្យដាក់ឯកសារដេញថ្លៃលើគម្រោងនានា ហើយនិងចុះកិច្ចសន្យាលើតម្លៃដេញថ្លៃ។ ឌី ប៊ី ឌី ដាក់តម្លៃដេញថ្លៃគម្រោងដោយផ្អែកលើការប៉ាន់ស្មានដ៏ល្អបំផុតរបស់ខ្លួន រួមបញ្ចូលទាំងការប៉ាន់ស្មានថ្លៃដើមនៃការផ្គត់ផ្គង់។ ប្រសិនបើថ្លៃដើមនៃការផ្គត់ផ្គង់កើនឡើងបន្ទាប់ពីការដេញថ្លៃត្រូវបានទទួលយក ឌី ប៊ី ឌី មិនអាចស្នើថ្លៃដើមបន្ថែមទៅអតិថិជនបានទេ ហើយក្រុមហ៊ុន អាចនឹងគ្មានជម្រើសណាមួយក្រៅពីទិញទំនិញនៅក្នុងតម្លៃថ្លៃ ដែលជាហេតុនាំឱ្យប្រាក់ចំណេញធ្លាក់ចុះ។ ហានិភ័យក៏អាចកើតមានផងដែរ នៅពេលដែលការផ្គត់ផ្គង់ចាំបាច់សម្រាប់គម្រោង ត្រូវពន្យារពេល ឬមិនមានជាបណ្តោះអាសន្ន

ដែលបណ្តាលឲ្យរយៈពេលបញ្ចប់គម្រោងត្រូវបានពន្យារពេល និងថ្លៃដើមគម្រោងកើនឡើង។ រាល់ការកើនឡើងនៃថ្លៃដើមផ្គត់ផ្គង់ ឬការពន្យារពេលក្នុងការទទួលការផ្គត់ផ្គង់ អាចជះឥទ្ធិពលអវិជ្ជមានដល់អាជីវកម្ម និងផលចំណេញរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ:** ឌី ប៊ី ឌី រក្សាទំនាក់ទំនងយ៉ាងល្អជាមួយអ្នកផ្គត់ផ្គង់នានា និងមាននីតិវិធីដើម្បីកាត់បន្ថយហានិភ័យទាក់ទងនិងការប្រែប្រួលនៃតម្លៃទំនិញ។ នីតិវិធីសំខាន់ គឺការចរចារតម្លៃជាមុនជាមួយនឹងអ្នកផ្គត់ផ្គង់ ដូច្នេះតម្លៃទំនិញត្រូវបានកំណត់ក្នុងអំឡុងពេលនៃគម្រោង។ ជាផ្នែកមួយនៃដំណើរការចរចារ ឌី ប៊ី ឌី បានរួមបញ្ចូលតម្រូវការផ្គត់ផ្គង់នៃគម្រោងដែលកំពុងដំណើរការរបស់ខ្លួនភាគច្រើន ដើម្បីទទួលបានការបញ្ចុះតម្លៃយ៉ាងច្រើន និងបន្ថែមចំណុចខ្លាំងលើការចរចាររបស់ខ្លួន។ លើសពីនេះទៀត ឌី ប៊ី ឌី ព្យាយាមរកការផ្គត់ផ្គង់ចាំបាច់បំផុតមុនពេលចាប់ផ្តើមគម្រោង ដើម្បីកាត់បន្ថយទាំងការប្រែប្រួលតម្លៃ និងហានិភ័យនៃការពន្យារពេលផ្គត់ផ្គង់។ ទោះបីជា ឌី ប៊ី ឌី ត្រូវបានចុះកិច្ចសន្យាក្នុងតម្លៃ ជាមួយរយៈពេលសម្រាប់គម្រោងដែលបានដេញថ្លៃក៏ដោយ ក៏ ឌី ប៊ី ឌី អាចចរចារឡើងវិញជាមួយម្ចាស់គម្រោងទៅលើពេលវេលា និងតម្លៃថ្មី ប្រសិនបើព្រឹត្តិការណ៍ទីផ្សារណាមួយកើតមានឡើង ដែលហួសពីដែនគ្រប់គ្រងរបស់ ឌី ប៊ី ឌី។

**- ហានិភ័យនៃអវត្តមានការងារ**

យោងតាម ឌី ប៊ី ឌី អត្រាអវត្តមានការងារក្នុងវិស័យនេះ គឺប្រហែលពី ១០% ទៅ ១៥% ជារៀងរាល់ថ្ងៃ ហើយអត្រាលាឈប់ពីការងារក្នុងវិស័យនេះ គឺប្រហែលពី ១៥% ទៅ ២០% ជារៀងរាល់ឆ្នាំ។ កង្វះកម្លាំងពលកម្ម អាចបង្កឲ្យមានការពន្យារពេលនៃគម្រោង។កង្វះកម្លាំងពលកម្ម អាចធ្វើឲ្យការចំណាយមិនមានប្រសិទ្ធិភាព នាំឲ្យថ្លៃដើមកើនឡើង និងប្រាក់ចំណេញថយចុះ។

**វិធានការកាត់បន្ថយ:** ខណៈពេលដែល ឌី ប៊ី ឌី មិនអាចគ្រប់គ្រងអវត្តមានការងារមួយចំនួនបាន ឌី ប៊ី ឌី ប្រើបច្ចេកវិទ្យាស្កេនម្រាមដៃដើម្បីធានាថាក្រុមហ៊ុន ចំណាយលើតែកម្មករនិយោជិកដែលមានវត្តមានពិតប្រាកដ។ កត្តានេះក៏អនុញ្ញាតឲ្យ ឌី ប៊ី ឌី អាចត្រួតពិនិត្យពេលវេលាការងារជាក់ស្តែងនៅលើទីតាំងគម្រោងនីមួយៗ។ ប្រសិនបើកម្មករអវត្តមាន ឌី ប៊ី ឌី មានក្រុមការងារត្រួតពិនិត្យ ដើម្បីកំណត់ពីមូលហេតុនៃអវត្តមាន និងកាលបរិច្ឆេទដែលត្រូវត្រលប់មកធ្វើការវិញ។ ឌី ប៊ី ឌី ព្យាយាមរក្សាកម្មករនិយោជិក ដោយតែងតែបើកប្រាក់ខែឲ្យទាន់ពេលវេលា និងធានាថាកម្មករនិយោជិក ពេញចិត្តនឹងលក្ខខណ្ឌការងារ ដើម្បីកាត់បន្ថយអត្រាលាឈប់។ ទោះបីជា ឌី ប៊ី ឌី ចាត់វិធានការសមស្រប ដើម្បីកាត់បន្ថយអវត្តមាន និងអត្រាលាឈប់ពីការងារ ក៏ ឌី ប៊ី ឌី មិនអាចគ្រប់គ្រងបានទាំងស្រុងដែរ។ ដូច្នេះអវត្តមាន និងការលាឈប់ពីការងារ នៅតែជាការគម្រាមកំហែងតិចតួច ដែលអាចព្យាករណ៍បាន ចំពោះប្រតិបត្តិការ និងផលចំណេញរបស់ ឌី ប៊ី ឌី។

**- ហានិភ័យពីការប្រកួតប្រជែង**

ដោយសារវិស័យសំណង់រឹងមាំ និងមានការរីកចម្រើន ចំនួនក្រុមហ៊ុនសំណង់ទាំងបរទេស និងក្នុងស្រុកមានការកើនឡើងយ៉ាងឆាប់រហ័ស។ ឌី ប៊ី ឌី កំពុងប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងនៅក្នុងដំណើរការដេញថ្លៃសម្រាប់គម្រោងរបស់ខ្លួន។ ដៃគូប្រកួតប្រជែងនានាមានដើមទុនច្រើន កំពុងបញ្ចុះតម្លៃក្នុងការដេញថ្លៃដើម្បីទទួលបានចំណែកទីផ្សារ។ កត្តានេះហើយធ្វើឲ្យ ឌី ប៊ី ឌី ត្រូវបង្ខំចិត្តបញ្ចុះតម្លៃក្នុងការដេញថ្លៃដើម្បីទទួលបានគម្រោង។ បរិយាកាសប្រកួតប្រជែងនៅក្នុងវិស័យសំណង់កម្ពុជា អាចជះឥទ្ធិពលមិនល្អលើប្រាក់ចំណេញរបស់ក្រុមហ៊ុន ដោយសារហានិភ័យនៃការបាត់បង់ការដេញថ្លៃ ឬការកាត់បន្ថយប្រាក់ចំណេញលើគម្រោងដែល ឌី ប៊ី ឌី ត្រូវបញ្ចុះតម្លៃក្នុងការដេញថ្លៃ។

**វិធានការកាត់បន្ថយ:** ដោយសារបទពិសោធន៍ដ៏ទូលំទូលាយក្នុងវិស័យសំណង់កម្ពុជា ឌី ប៊ី ឌី អាចជ្រើសរើសគម្រោងដើម្បីដេញថ្លៃបានស្របតាមជំនាញរបស់ក្រុមហ៊ុន។ កត្តានេះ អនុញ្ញាតឲ្យ ឌី ប៊ី ឌី គ្រប់គ្រងថ្លៃដើមគម្រោង និងដាក់តម្លៃដេញថ្លៃសមរម្យដើម្បីឲ្យក្រុមហ៊ុននៅតែទទួលបានផលចំណេញ។ លើសពីនេះទៀត កេរ្តិ៍ឈ្មោះដ៏រឹងមាំ និងបទពិសោធន៍ជាង ២៥ឆ្នាំ ជួយឲ្យ ឌី ប៊ី ឌី ឈ្នះការដេញថ្លៃគម្រោង ទោះបីជាការដេញថ្លៃ មិនទាបពេកជាងក្រុមហ៊ុនដទៃក៏ដោយ។

**- ហានិភ័យពីទាក់ទងនឹងអាកាសធាតុ**

ប្រទេសកម្ពុជា ស្ថិតក្នុងរដូវវស្សាចាប់ពីខែឧសភា រហូតដល់ខែតុលាជារៀងរាល់ឆ្នាំ។ ក្នុងអំឡុងពេលមានភ្លៀងធ្លាក់ខ្លាំង អាចបង្ករជាទឹកជំនន់ ដែលភាគច្រើនជះឥទ្ធិពលដល់ការដឹកជញ្ជូនឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់ ប៉ុន្តែក៏អាចបង្កការជន់លិច និងពន្យារពេលនៅតាមគម្រោងនីមួយៗផងដែរ។ ទឹកជំនន់ប្រភេទណា ក៏អាចបង្កឱ្យមានការពន្យារពេលនៃការបញ្ចប់គម្រោង ដែលនាំឱ្យការចំណាយកើនឡើង និងប្រាក់ចំណេញថយចុះ។

**វិធានការកាត់បន្ថយ:** ឌី ប៊ី ឌី ព្យាយាមសម្របពេលគម្រោងសាងសង់ ឱ្យទាន់រដូវប្រាំងនៅកម្ពុជា។ ផែនការគម្រោង ត្រូវបានគ្រោងទុកយ៉ាងល្អ ដើម្បីការពារទឹកជំនន់ដែលអាចកើតមានក្នុងរដូវវស្សា។ ទោះបីជាមានការរៀបចំផែនការជាក់លាក់ក៏ដោយ រាល់សកម្មភាពទាំងអស់ មិនតែងតែអាចធ្វើឡើងស្របតាមអាកាសធាតុដែលបានរំពឹងទុកនោះទេ។ ដូច្នេះ ការពន្យារពេលខ្លះដោយសារកត្តាអាកាសធាតុ និងទឹកជំនន់ គឺមិនអាចជៀសវាងបានទាំងស្រុង ហើយអាចជះឥទ្ធិពលអវិជ្ជមានដល់ប្រសិទ្ធិភាពប្រតិបត្តិការ និងផលចំណេញ។

**- ហានិភ័យគ្រោះថ្នាក់**

ហានិភ័យគ្រោះថ្នាក់ គឺមានអត្រាខ្ពស់ក្នុងវិស័យសំណង់។ កម្មករនិយោជិត តម្រូវឱ្យធ្វើការជាមួយឧបករណ៍ធុនធ្ងន់ កម្ពស់ខ្ពស់ លក្ខខណ្ឌទីតាំងពិបាក និងសម្ភារៈគ្រោះថ្នាក់។ កង្វះបទប្បញ្ញត្តិតឹងរឹងក្នុងប្រទេសកម្ពុជា មានន័យថាភាគច្រើននៃកម្មករនិយោជិតនៅការដ្ឋាន មិនទទួលបានការអប់រំនៃហានិភ័យផ្សេងៗ និងវិធានការដើម្បីការពារឱ្យបានត្រឹមត្រូវ។ លើសពីនេះទៀត កង្វះខាតកម្លាំងពលកម្មជំនាញ មានន័យថាកម្មករនិយោជិកជារឿយៗ ខ្វះបទពិសោធន៍គ្រប់គ្រាន់ក្នុងការធ្វើការឱ្យបាត្រឹមត្រូវជាមួយគ្រឿងម៉ាស៊ីនធុនធ្ងន់ សម្ភារៈគ្រោះថ្នាក់ និងលក្ខខណ្ឌភូមិសាស្ត្រនៅការដ្ឋានមិនអំណោយផល។ សូម្បីតែនៅក្នុងលក្ខខណ្ឌល្អបំផុតយ៉ាងណាក៏ដោយ ក៏វិស័យសំណង់ នៅតែមានហានិភ័យគ្រោះថ្នាក់ខ្ពស់ បើធៀបនឹងវិស័យដ៏ទៃទៀត។ នៅប្រទេសកម្ពុជា គ្រោះថ្នាក់នៅនឹងកន្លែងសាងសង់ កើតមានឡើងជាប្រចាំ។ គ្រោះថ្នាក់នេះ អាចជះឥទ្ធិពលអវិជ្ជមានដល់ប្រតិបត្តិការរយៈពេលគម្រោង និងផលចំណេញរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ:** ឌី ប៊ី ឌី ធ្វើការត្រួតពិនិត្យទីតាំង ដើម្បីធានាបាននូវលក្ខខណ្ឌល្អ ក្នុងការកាត់បន្ថយគ្រោះថ្នាក់។ ក្រុមហ៊ុនក៏បានបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួន អំពីការអនុវត្តល្អ និងបទប្បញ្ញត្តិសុវត្ថិភាព។ ម៉្យាងវិញទៀត ឌី ប៊ី ឌី ព្យាយាមគោរពតាមស្តង់ដារអន្តរជាតិ ISO នៃសុខភាព និងសុវត្ថិភាព ហើយកំពុងស្ថិតក្នុងដំណើរការដាក់ពាក្យសុំវិញ្ញាបនបត្រ។ ឌី ប៊ី ឌី បានទទួលវិញ្ញាបនបត្រសុវត្ថិភាពជាច្រើន ពីអតិថិជនបន្ទាប់ពីគម្រោងបានបញ្ចប់។

**- ហានិភ័យនៃកង្វះខាតណាមួយក្នុងគម្រោង**

នៅពេលដែលគម្រោងសាងសង់ត្រូវបានបញ្ចប់ ឌី ប៊ី ឌី ទទួលខុសត្រូវក្នុងការកែតម្រូវកង្វះខាតណាមួយក្នុងគម្រោង ក្នុងរយៈពេល ១២ខែ។ ទោះបីជាក្រុមហ៊ុន ប្រើជំនាញ និងបទពិសោធន៍របស់ខ្លួន ដើម្បីបញ្ចប់គម្រោងប្រកបដោយគុណភាពខ្ពស់ កង្វះខាត គឺជាផ្នែកមួយដែលអាចកើតមានក្នុងអាជីវកម្ម។ ទំនួលខុសត្រូវក្នុងការកែតម្រូវកង្វះខាតណាមួយ អាចនាំឱ្យមានការចំណាយដែលមិនបានគ្រោងទុកមុន និងអាចជះឥទ្ធិពលអវិជ្ជមានដល់លំហូរសាច់ប្រាក់ កេរ្តិ៍ឈ្មោះ និងប្រាក់ចំណេញរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ:** ឌី ប៊ី ឌី រក្សាកម្លាំងពលកម្ម រួមទាំងវិស្វករដែលពោពេញដោយបទពិសោធន៍ខ្ពស់ អ្នកសាងសង់ និងអ្នកគ្រប់គ្រងគម្រោង។ កម្លាំងពលកម្មប្រកបដោយជំនាញរបស់ ឌី ប៊ី ឌី មានន័យថាកង្វះខាតដែលនឹងកើតឡើង អាចនឹងមានភាគរយតិច។ ទោះបីជាកង្វះខាត មិនអាចត្រូវបានជៀសវាងទាំងស្រុងក៏ដោយ ឌី ប៊ី ឌី ជឿជាក់ថាកង្វះខាតចម្បងៗដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អាជីវកម្ម ឬទីតាំងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នៅមានកម្រិតទាប។

**- ហានិភ័យនៃការពន្យារពេលនៃគម្រោងសាងសង់**

ការពន្យារពេលនៃគម្រោង អាចកើតឡើងដោយសារតែបញ្ហាម្ចាស់គម្រោង ឬ ឌី ប៊ី ឌី។ មូលហេតុនៃការពន្យារពេលពីម្ចាស់គម្រោង រួមមាន ការផ្លាស់ប្ដូរផែនការសាងសង់ និងការតម្លើង ឬកង្វះដើមទុន ជាដើម។ ប្រសិនបើការពន្យារពេល បណ្ដាលមកពីម្ចាស់គម្រោង ឌី ប៊ី ឌី ប្រឈមនឹងហានិភ័យនៃការចំណាយបន្ថែម ដូចជាថ្លៃដើមពលកម្ម ថ្លៃដើមទឹកភ្លើងជាដើម។ ប្រសិនបើការពន្យារពេលបណ្ដាលមកពី ឌី ប៊ី ឌី នោះក្រុមហ៊ុនប្រឈមនឹងការផាកពិន័យពីម្ចាស់គម្រោង។

**វិធានការកាត់បន្ថយ:** ផលប៉ះពាល់អវិជ្ជមាននៃការពន្យារពេលដែលបណ្ដាលមកពីម្ចាស់គម្រោង អាចត្រូវបានបន្ថយតាមរយៈការកាត់បន្ថយថ្លៃពលកម្ម ដែលការកាត់បន្ថយនេះ មិនចដល់ការងារបច្ចុប្បន្ន។ ចំណែកឯការពន្យារពេលដែលបណ្ដាលមកពី ឌី ប៊ី ឌី គឺមិនកើតមានញឹកញាប់នោះទេ ពីព្រោះ ឌី ប៊ី ឌី ពឹងផ្អែកលើអ្នកគ្រប់គ្រងគម្រោងដែលមានបទពិសោធន៍ក្នុងការគ្រប់គ្រងបុគ្គលិក និងអ្នកម៉ៅការបន្ត ដើម្បីសម្រេចគម្រោងឱ្យបានទាន់ពេលវេលា។ អ្នកគ្រប់គ្រងគម្រោង ត្រួតពិនិត្យគម្រោងនីមួយៗ និងធ្វើរបាយការណ៍ប្រចាំខែដាក់ជូនថ្នាក់លើ ដោយកំណត់បញ្ហាចម្បងៗ រួមនឹងការធ្វើផែនការ និងសកម្មភាពត្រឹមត្រូវ។

**- ហានិភ័យនៃការបាត់បង់បុគ្គលិកសំខាន់ៗ**

ដើម្បីរក្សាបាននូវគុណភាព ប្រសិទ្ធិភាព និងកេរ្តិ៍ឈ្មោះល្អ ឌី ប៊ី ឌី ពឹងផ្អែកលើជំនាញរបស់បុគ្គលិកជាពិសេសវិស្វករ អ្នកគ្រប់គ្រងគម្រោង និងអ្នកគ្រប់គ្រងការដ្ឋាន។ បុគ្គលិកជំនាញក្នុងមុខតំណែងទាំងនេះ នៅមានកម្រិតណាស់នៅក្នុងប្រទេសកម្ពុជា ដូច្នេះវាជាកត្តាសំខាន់ដែល ឌី ប៊ី ឌី អាចរក្សាបាននូវបុគ្គលិកទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារលក្ខណៈប្រកួតប្រជែងនៃវិស័យសំណង់នៅកម្ពុជា ហានិភ័យនៃការកង្វះខាត គឺជាការគម្រាមកំហែងឥតឈប់ឈរ។ ការបាត់បង់បុគ្គលិកសំខាន់ៗ អាចបណ្ដាលឱ្យមានការពន្យារពេលនៃរយៈពេលគម្រោង ការកើនឡើងថ្លៃដើមគម្រោង ឬការថយចុះគុណភាពគម្រោងដែលកត្តាណាមួយក្នុងចំណោមកត្តាគម្រាមកំហែងទាំងនេះ អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អាជីវកម្ម កេរ្តិ៍ឈ្មោះ ចំណូល និងប្រាក់ចំណេញរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ:** កង្វះខាតនៃកម្លាំងពលកម្មមួយចំនួន មិនអាចជៀសផុតបានទេ ប៉ុន្តែ ឌី ប៊ី ឌី ព្យាយាមកាត់បន្ថយផលប៉ះពាល់នៃកង្វះខាត ដោយការបង្កើនសមត្ថភាពរបស់បុគ្គលិកខ្លួនជានិច្ច តាមរយៈកម្មវិធីបណ្ដុះបណ្ដាលនានា។ បុគ្គលិកមានជំនាញខ្ពស់ ចែករំលែកជំនាញរបស់ពួកគេ ជាមួយបុគ្គលិកដែលមានបទពិសោធន៍តិច។ ការអនុវត្តនេះ ជួយឱ្យ ឌី ប៊ី ឌី មានភាពងាយស្រួលក្នុងការស្វែងរកបុគ្គលិកជំនួសផ្ទៃក្នុង ប្រសិនបើមានកង្វះខាតបុគ្គលិកជំនាញ។ ឌី ប៊ី ឌី ក៏បានជ្រើសរើសបុគ្គលិកមានជំនាញ និងទេពកោសល្យ ពីសាកលវិទ្យាល័យ និងដៃគូប្រកួតប្រជែងផងដែរ។ ដើម្បីរក្សាបុគ្គលិកដែលមានស្រាប់ និងជ្រើសរើសបុគ្គលិកថ្មី ឌី ប៊ី ឌី ផ្ដល់នូវគុណប្រយោជន៍យ៉ាងច្រើនដល់បុគ្គលិក ក្នុងគោលបំណងបង្កើនការពេញចិត្តការងារ ដែលរួមមាន ផែនការអភិវឌ្ឍអាជីព ប្រាក់រង្វាន់ប្រចាំឆ្នាំ និងប្រាក់ខែដែលប្រកួតប្រជែងក្នុងទីផ្សារ។

**- ហានិភ័យនៃទុនបង្វិល**

នៅពេលដែល ឌី ប៊ី ឌី ចុះកិច្ចសន្យាលើកគម្រោងមួយ ជាទូទៅ ក្រុមហ៊ុន ទទួលខុសត្រូវចំពោះរាល់ការចំណាយជាមុន ដែលចំណាយទាំងនោះអាចមានច្រើន។ ជាធម្មតា កិច្ចសន្យា មិនចែងពីការទូទាត់ជាមុននោះទេ ហើយការទូទាត់ចាបន្តបន្ទាប់ ត្រូវបានធ្វើឡើងចារៀងរាល់ខែ ដោយផ្អែកលើដំណើរការនៃគម្រោង។ លើសពីនេះទៀត ឌី ប៊ី ឌី ត្រូវតែមានប្រាក់តម្កល់លើការអនុវត្តគម្រោងនីមួយៗដែលមានតម្លៃ ១០ភាគរយនៃចំនួនទឹកប្រាក់នៃកិច្ចសន្យា។ ប្រាក់តម្កល់លើការអនុវត្ត គឺជាទម្រង់នៃប្រាក់បញ្ញើនៅធនាគារ ដែលមិនអាចយកមកប្រើប្រាស់បានរហូតដល់ពេលដែលគ្រោងត្រូវបានបញ្ចប់។ គោលបំណងនៃប្រាក់តម្កល់នេះ គឺដើម្បីធានាដល់ម្ចាស់គ្រោងថា ឌី ប៊ី ឌី មានសុវត្ថិភាពផ្នែកហិរញ្ញវត្ថុ និងមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការចំណាយលើគម្រោង កត្តាទាំងនេះ បានជះឥទ្ធិពលដល់ទុនបង្វិលរបស់ ឌី ប៊ី ឌី។ នៅក្នុងវិស័យសំណង់នេះ ទុនបង្វិលគ្រប់គ្រាន់ ត្រូវបានចាត់ទុកថាក្នុងចន្លោះ ២៥% ទៅ ៣០% នៃតម្លៃសរុបរបស់កិច្ចសន្យាដែលកំពុងដំណើរការទាំងអស់។ ជាធម្មតា ទុនបង្វិល ត្រូវបានយកទៅប្រើប្រាស់ដើម្បីទូទាត់ថ្លៃវត្ថុធាតុដើម អ្នកផ្គត់ផ្គង់ និងថ្លៃពលកម្ម។ ទឹកប្រាក់ទាំងនោះ បានមកពីទុនបង្វិលរបស់ក្រុមហ៊ុន

ដែលមានស្រាប់ រួមជាមួយនឹងឥណទានពីធនាគារ។ អាជីវកម្មរបស់ ឌី ប៊ី ឌី គឺចាំបាច់តម្រូវឲ្យមានទុនបង្វិលគ្រប់គ្រាន់ ដូច្នេះ រាល់ការទូទាត់ប្រាក់ពីអតិថិជន ឬការពន្យារពេលទូទាត់ អាចមានផលប៉ះពាល់អវិជ្ជមានដល់ទុនបង្វិលរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ:** ដើម្បីកាត់បន្ថយផលប៉ះពាល់មួយចំនួននៃទុនបង្វិល ឌី ប៊ី ឌី បន្តការចរចារដើម្បីទទួលបានទឹកប្រាក់ជាមុន លើគម្រោងដែលបានទទួលបាន។ ឌី ប៊ី ឌី ក៏បានបម្រុងទុកសាច់ប្រាក់ក្នុងដៃមួយចំនួនធំ សម្រាប់ផ្គត់ផ្គង់ប្រតិបត្តិការផងដែរ។ ដើម្បីជៀសវាងហានិភ័យនៃការមិនបង់ប្រាក់ ឬការទូទាត់យឺតយ៉ាវពីអតិថិជន ឌី ប៊ី ឌី ពិនិត្យមើលស្ថានភាពហិរញ្ញវត្ថុរបស់ អតិថិជន មុនពេលធ្វើការដេញថ្លៃ។ ជាចុងក្រោយ ឌី ប៊ី ឌី មានក្រុមការងារសម្រាប់ប្រមូលសាច់ប្រាក់ និងទិញលក់ ដែលត្រួត ពិនិត្យ និងតាមដានលើស្ថានភាពសាច់ប្រាក់ដែលត្រូវទទួលទាំងអស់។

**- ហានិភ័យអត្រាការប្រាក់**

ឌី ប៊ី ឌី ពឹងផ្អែកលើប្រាក់កម្ចីធនាគារ និងបណ្ណាញឥណទាន ដើម្បីផ្តល់មូលនិធិដល់គម្រោងរបស់ក្រុមហ៊ុន។ ប្រសិនបើអត្រាការ ប្រាក់ក្នុងទីផ្សារកើនឡើង ក្រុមហ៊ុន អាចត្រូវបង់ការប្រាក់កាន់តែច្រើន ដែលនាំឲ្យជះឥទ្ធិពលអវិជ្ជមានដល់ប្រាក់ចំណេញ។

**វិធានការកាត់បន្ថយ:** ឌី ប៊ី ឌី មិនប្រឈមនឹងហានិភ័យអត្រាការប្រាក់នោះទេ ដោយសារតែក្រុមហ៊ុន មិនមានទ្រព្យសកម្ម ហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលមានអត្រាការប្រាក់រយៈពេលខ្លីនោះទេ។

# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន

## ១. លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន

បន្ទាប់ពីមានការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រុមហ៊ុនបានទទួលរងនូវផលវិបាកមួយចំនួន ទៅលើការផ្គត់ផ្គង់សម្ភារៈគម្រោង ដែលកត្តានេះបណ្តាលមកពីអ្នកផ្គត់ផ្គង់ត្រូវការពេលវេលាយូរសម្រាប់ផលិតកម្ម ហើយតម្លៃទំនិញ និងការដឹកជញ្ជូនខ្លះក៏មានការកើនឡើងផងដែរ។ លើសពីនេះទៅទៀត ក្រុមហ៊ុនក៏ប្រឈមនឹងការកើនឡើងនៃចំណាយទៅលើកម្លាំងពលកម្ម ដោយសារតែការធ្វើការថែមម៉ោង ក្រោយពីមានការបិទខ្ទប់ ។

ទោះបីជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនអាចទទួលបានប្រាក់ចំណេញចំនួន ១.៦៧៨.៧៩១ ពាន់រៀល ធៀបនឹងប្រាក់ចំណេញចំនួន ១.២៤៣.០០៤ ពាន់រៀលនៃឆ្នាំ២០២០។

## ២. រចនាសម្ព័ន្ធចំណូល

| រចនាសម្ព័ន្ធចំណូល (ពាន់រៀល) | ២០២១ | | ២០២០ | | ២០១៩ | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ចំណូលពីគម្រោងសាងសង់ និងការជុសជុលថែទាំ | ៧១.៤៦១.៦៩៨ | ៩៧,៧៩% | ៥៣.២៩២.៥៣៤ | ៩៧,០៩% | ៣២.៩៨៤.២៩៧ | ៩៣,៨៩% |
| ចំណូលពីការលក់សម្ភារៈ | ១.៦១៦.៧៨២ | ២,២១% | ១.៥៩៦.៨៨៣ | ២,៩១% | ២.១៤៤.៧២៨ | ៦,១១% |

ឌី ប៊ី ឌី មានប្រភពចំណូលពីរ ដោយប្រាក់ចំណូលទីមួយ បានមកពីគម្រោងសាងសង់ ដែលជាប្រភពចម្បង ក្នុងនោះរួមបញ្ចូលនូវគម្រោងថ្មី និងការងារជួសជុល និងការថែទាំ។ ប្រភពចំណូលទីពីរ បានមកពីការលក់សម្ភារៈគម្រោង ដែលវាជាផ្នែកតូចមួយរបស់ចំណូលសរុប។ ទោះបីជាយ៉ាងណាក៏ដោយ ប្រាក់ចំណូលពីការលក់សម្ភារៈគម្រោង នឹងមានការកើនឡើងបន្ទាប់ពីក្រុមហ៊ុនពង្រីកនូវផលិតកម្មបំពង់របស់ខ្លួន។ ឌី ប៊ី ឌី នឹងធ្វើការលក់ផលិតផលនេះ ដែលសព្វថ្ងៃនេះក្រុមហ៊ុនផលិតសម្រាប់តែផ្គត់ផ្គង់គម្រោងសាងសង់របស់ខ្លួនប៉ុណ្ណោះ។

# ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

## ក. រចនាសម្ព័ន្ធក្រុមហ៊ុន



ក. ក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយអភិបាល | កាលបរិច្ឆេទបញ្ចប់អណត្តិ |
|---|---|---|---|---|
| ១ | លោក នាង វិធី | ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង | ១២-តុលា-២០២០ | ១២-តុលា-២០២៣ |
| ២ | លោកស្រី លឹម មុយលី | អភិបាលប្រតិបត្តិ និងនាយកហិរញ្ញវត្ថុ | ១២-តុលា-២០២០ | ១២-តុលា-២០២៣ |
| ៣ | លោក ថៃ វ៉ាន់ថា | អភិបាលមិនប្រតិបត្តិ | ១២-តុលា-២០២០ | ១២-តុលា-២០២៣ |
| ៤ | លោក ហ៊ុយ វ៉ាថារ៉ូ | អភិបាលឯករាជ្យ | ១២-តុលា-២០២០ | ១២-តុលា-២០២៣ |

ខ. បុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | នាង វិធី | ប្រុស | ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង |
| ២ | លឹម មុយលី | ស្រី | អភិបាលប្រតិបត្តិ និងនាយកហិរញ្ញវត្ថុ |
| ៣ | នង បំណង | ប្រុស | ប្រធានគ្រប់គ្រងទូទៅ |
| ៤ | គុយ កៅ | ប្រុស | ប្រធានគ្រប់គ្រងគម្រោងជាន់ខ្ពស់ |
| ៥ | GERRY P. ARDENA | ប្រុស | ប្រធានគ្រប់គ្រងគម្រោងជាន់ខ្ពស់ |
| ៦ | សួ សុខ | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ៧ | ខន រតនៈ | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ៨ | ម៉ាយ ចន្ទា | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ៩ | អ៊ុង គឹមហាន | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ១០ | ស្រ៊ិន ចាន់សារ៉ាង | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ១១ | សាន់ បញ្ញា | ប្រុស | ប្រធានគ្រប់គ្រងគម្រោង |
| ១២ | សៀក សុខន | ប្រុស | ប្រធានគ្រប់គ្រងផ្នែកថែទាំ និងសេវាកម្មអតិថិជន |
| ១៣ | ពា ធារ៉ា | ប្រុស | ប្រធានគ្រប់គ្រងការឌីហ្សាញ |
| ១៤ | អ៊ុក វល័ក្ខ | ប្រុស | ប្រធានគណនេយ្យ |
| ១៥ | វ៉េត វណ្ណី | ប្រុស | ប្រធានគ្រប់គ្រងផលិតកម្ម |
| ១៦ | យឹម តូញ៉ា | ប្រុស | ប្រធានគ្រប់គ្រងលទ្ធកម្ម |

*ចំណាំ៖ ព័ត៌មានលម្អិតនៃអភិបាលកិច្ចសាជីវកម្មត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ*

# ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក

## ក. ព័ត៌មានអំពីមូលបត្រ

| | |
|---|---|
| ឈ្មោះមូលបត្រកម្មសិទ្ធិ: | ភាគហ៊ុនប្រភេទ "ក" (ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត) |
| និមត្តិសញ្ញាមូលបត្រកម្មសិទ្ធិ: | DBDE |
| ចំណាត់ថ្នាក់មូលបត្រកម្មសិទ្ធិ: | ភាគហ៊ុនប្រភេទ "ក" (ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត) |
| តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ: | ១.០០០រៀល |
| តម្លៃបោះផ្សាយលក់: | ២.៣៨០ រៀល |
| មូលបត្រកម្មសិទ្ធិសម្រាប់បោះផ្សាយលក់: | ៦.៤៦១.៥៣៨ ភាគហ៊ុន |
| មូលធនីយកម្មទីផ្សារ: | ៤៣.៩៣៨.៤៦០.៤៤០ រៀល |
| ផ្សារមូលបត្រ: | ផ្សារមូលបត្រកម្ពុជា |
| កាលបរិច្ឆេទចុះបញ្ជី ជាផ្លូវការ | ថ្ងៃទី ០៦ ខែកញ្ញា ២០២១ |

## ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| ភាគហ៊ុនប្រភេទ "ក" (ភាគហ៊ុនមានសិទ្ធិបោះឆ្នោត) | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (រៀល) | អតិបតិមា | មិនមាន | | | | | | | | ២.៤៤០ | ២.២៦០ | ២.២៦០ | ២.៣៦០ |
| | មធ្យម | មិនមាន | | | | | | | | ២.៣៤៥ | ២.២៤០ | ២.២១៥ | ២.៣៦០ |
| | អប្បបរិមា | មិនមាន | | | | | | | | ២.២៥០ | ២.២២០ | ២.១៦០ | ២.២៦០ |
| បរិមាណជួញដូរ | អតិបតិមា | មិនមាន | | | | | | | | ៣៥១.៣៤១ | ៥៩.៣៥៨ | ៤៧.៣១២ | ៤៨.៦៩៦ |
| | មធ្យម | មិនមាន | | | | | | | | ៤៩.៥១៤ | ១៥.៦៤៩ | ១២.០០៧ | ១២.៤៥២ |
| | អប្បបរិមា | មិនមាន | | | | | | | | ៣.៩៧៧ | ១.២៨៦ | ២.៤០២ | ១.១៩៤ |

## គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | លោក នាង វិធី | ខ្មែរ | ៨.៤០០.០០០ | ៤៥,៥០% |

## ឃ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន (ចាប់ពី ៥% ឡើងទៅ)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | លោកស្រី លឹម មុយលី | ខ្មែរ | ៣.៦០០.០០០ | ១៩,៥០% |
| ២ | ROYAL GROUP TRUSTEE CO., LTD. | ខ្មែរ | ៣.៤០០.០០០ | ១៨,៤២% |

## ង. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ

| ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|
| ចំណេញសុទ្ធ | ១.២៤៣.០០៤ | ៤.៤៥៨.៤៥៩ | ៤.៥៩៧.២២០ |
| ភាគលាភជាសាច់ប្រាក់សរុប | - | ៤០៥.២០០ | - |
| ភាគលាភជាមូលបត្រកម្មសិទ្ធិ | - | - | - |
| ភាគលាភផ្សេងទៀត | - | - | - |
| អនុបាតនៃការបែងចែកភាគលាភ | - | ៩,០៩% | - |
| ទិន្នផលភាគលាភ (%) | - | ៧០,៤៤% | - |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | - | ១៤២,១៨ | - |

# ផ្នែកទី៥: របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទើបតែចុះបញ្ជីនៅ ផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី ០៦ ខែកញ្ញា ២០២១។ ដូច្នេះហើយ ក្រុមហ៊ុនមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការដំណើរការមុខងារសវនកម្មផ្ទៃក្នុងរបស់ខ្លួននៅឆ្នាំ២០២១ នៅឡើយទេ។

ទោះយ៉ាងណាក៏ដោយ នៅក្រោមវិសាលភាពនៃសវនកម្ម របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានធ្វើសវនកម្មចាប់តាំងពីចុងការិយបរិច្ឆេទនៃឆ្នាំ២០២០។ សវនករឯករាជ្យបានពិនិត្យ និងលើកបញ្ហាមួយចំនួនទាក់ទងនឹងសវនកម្មផ្ទៃក្នុង ហើយបញ្ហាសំខាន់ៗមួយចំនួនដែលលើកឡើងដោយសវនករឯករាជ្យត្រូវបានពិភាក្សាជាមួយថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាល ហើយត្រូវបានទទួលយក និងកែលម្អជាបណ្តើរៗដោយក្រុមហ៊ុនក្នុងការគ្រប់គ្រងប្រព័ន្ធផ្ទៃក្នុងរបស់ខ្លួន។

ក្រុមហ៊ុនបាននិងកំពុងរៀបចំនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងធនធានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ប្រតិបត្តិការសម្រាប់ផ្នែកនេះប្រកបដោយប្រសិទ្ធភាព។ របាយការណ៍សវនកម្មផ្ទៃក្នុងដោយសវនករផ្ទៃក្នុងនឹងត្រូវបានទទួលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២២ នាពេលខាងមុខ។

# ផ្នែកទី៦: របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមមើលឧបសម្ព័ន្ធសម្រាប់របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មនៃឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១

# ផ្នែកទី៧: ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធនិងទំនាស់ផលប្រយោជន៍

ភាគីពាក់ព័ន្ធគឺជាបុគ្គល ឬអង្គភាពដែលទាក់ទងនឹងក្រុមហ៊ុន ហើយប្រតិបត្តិការភាគីពាក់ព័ន្ធគឺជាការផ្ទេរទំនិញ ឬសេវាកម្ម ធនធាន កាតព្វកិច្ច ផ្សេងទៀតរវាងក្រុមហ៊ុន។

ខាងក្រោមនេះគឺជាប្រតិបត្តិការសម្ភារៈ និងជម្លោះផលប្រយោជន៍រវាងក្រុមហ៊ុន និងភាគីពាក់ព័ន្ធៈ

ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥% ឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ
សូមមើលរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ឆ្នាំ ២០២១ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ សម្រាប់ព័ត៌មានលម្អិតដូចដែលបានបង្ហាញក្នុងគណត់សម្គាល់ ២៦ "សមតុល្យ និងប្រតិបត្តិការនឹងភាគីពាក់ព័ន្ធ"

ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់
សូមមើលរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ឆ្នាំ ២០២១ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ សម្រាប់ព័ត៌មានលម្អិតដូចដែលបានបង្ហាញក្នុងគណត់សម្គាល់ ២៦ "សមតុល្យ និងប្រតិបត្តិការនឹងភាគីពាក់ព័ន្ធ"

គ. ប្រតិបត្តិការសំខាន់ជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម
មិនមាន

ឃ. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥% ឡើងទៅ
មិនមាន

ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ
មិនមាន

ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល
មិនមាន

ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ
មិនមាន

ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ
សូមមើលរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ឆ្នាំ ២០២១ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ សម្រាប់ព័ត៌មានលម្អិតដូចដែលបានបង្ហាញក្នុងគណត់សម្គាល់ ២៦ "សមតុល្យ និងប្រតិបត្តិការនឹងភាគីពាក់ព័ន្ធ"

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. កាលវិភាគចំណូល

នៅចុងការិបរិច្ឆេទនៃឆ្នាំ ២០២១ ក្រុមហ៊ុនទទួលបានប្រាក់ចំណូលចំនួន ៧៣.០៧៨.៤៨០ ពាន់រៀល ដែលកើនឡើង ៣៣,១៤% បើធៀបនឹងប្រាក់ចំណូលចំនួន ៥៤.៨៨៩.៤១៧ ពាន់រៀល នៅក្នុងឆ្នាំ ២០២០។

### ២. កាលវិភាគចំណូលតាមផ្នែក

ក្រុមហ៊ុនមានតារាងចំណូលដូចខាងក្រោមៈ

| រចនាសម្ព័ន្ធចំណូល (ពាន់រៀល) | ឆ្នាំ២០២១ | | ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ចំណូលពីគម្រោងសាងសង់ | ៧១.៤៦១.៦៩៨ | ៩៧,៧៩% | ៥៣.២៩២.៥៣៤ | ៩៧,០៩% |
| ចំណូលពីការលក់សម្ភារៈ | ១.៦១៦.៧៨២ | ២,២១% | ១.៥៩៦.៨៨៣ | ២,៩១% |
| សរុប | ៧៣.០៧៨.៤៨០ | ១០០% | ៥៤.៨៨៩.៤១៧ | ១០០% |

### ៣. ការវិភាគគម្លាតចំណេញដុល

នៅចុងការិបរិច្ឆេទនៃឆ្នាំ២០២១ ឌី ប៊ី ឌី ទទួលបានប្រាក់ចំណេញសរុបចំនួន ១០.៣៩៣.០០០ ពាន់រៀល ដែលកើនឡើង ១២,៨៤% បើធៀបនឹងប្រាក់ចំណេញសរុបចំនួន ៩.២១០.១៦៣ ពាន់រៀល នៅក្នុងឆ្នាំ២០២០។

### ៤. ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធ

នៅចុងការិបរិច្ឆេទនៃឆ្នាំ២០២១ នេះ ឌី ប៊ី ឌី ទទួលបានប្រាក់ចំណេញមុនបង់ពន្ធចំនួន ២.៤១០.០៣០ ពាន់រៀល ដែលកើនឡើង ៣២,៨៧% បើធៀបនឹងប្រាក់ចំណេញមុនបង់ពន្ធចំនួន ១.៨១៣.៧៨៨ ពាន់រៀល នៅក្នុងឆ្នាំ២០២០។

### ៥. ការវិភាគចំណេញ/(ខាត)ក្នុងការិយបរិច្ឆេទ

នៅចុងការិបរិច្ឆេទនៃឆ្នាំ២០២១ នេះ ឌី ប៊ី ឌី ទទួលបានប្រាក់ចំណេញក្នុងឆ្នាំចំនួន ១.៦៧៨.៧៩១ ពាន់រៀល ដែលកើនឡើង ៣៥,០៦% បើធៀបនឹងប្រាក់ចំណេញក្នុងឆ្នាំចំនួន ១.២៤៣.០០៤ ពាន់រៀល ក្នុងឆ្នាំ២០២០។

### ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិបរិច្ឆេទ

នៅចុងការិបរិច្ឆេទនៃឆ្នាំ២០២១ នេះ, ឌី ប៊ី ឌី បានទទួលបានប្រាក់ចំណូលសរុបប្រចាំឆ្នាំស្មើនឹង ១.៨៤៥.១០៩ ពាន់រៀល ដែលកើនឡើង ៦៨,៣០% បើធៀបនឹង ១.០៩៦.៣២៤ ពាន់រៀល ក្នុងឆ្នាំ២០២០។

### ៧. ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

នៅចុងការិបរិច្ឆេទនៃឆ្នាំ២០២១ នេះ ប្រាក់ចំណូលរបស់ក្រុមហ៊ុន ឌី ប៊ី ឌី កើនឡើង ៣៣,១៤% បើធៀបនឹងឆ្នាំ២០២០។ ប៉ុន្តែតម្លៃនៃទំនិញដែលបានលក់បានកើនឡើង ៣៧,១៣% លើសបន្តិចពីអត្រានៃការកើនឡើងនៃប្រាក់ចំណូល ដោយសារតែការកើនឡើងនៃ

តម្លៃទំនិញមួយចំនួន ការដឹកជញ្ជូន និងកម្លាំងពលកម្មដែលបណ្តាលមកពីការផ្ទុះឡើងនៃជំងឺកូវីត-១៩ និងនិងការបិទខ្ទប់ ធ្វើឱ្យប្រាក់ចំណេញសុទ្ធរបស់យើងមានកម្រិតទាបបន្តិចបើធៀបនឹងឆ្នាំមុន។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ឱកាសក្នុងវិស័យសំណង់មានការថយចុះ គម្រោងចំនួន ៤.៣០៣ ត្រូវបានអនុម័តក្នុងឆ្នាំ២០២១ ដែលស្មើនឹង ៥,៣៣ ពាន់លានដុល្លាអាមេរិក ថយចុះ ៣១,២១% បើធៀបនឹងឆ្នាំ២០២០ ដែលមានគម្រោងចំនួន ៤.៨៤១ ត្រូវបានអនុម័តស្មើនឹង ៧,៧៥ ពាន់លានដុល្លាអាមេរិក។ ឱកាសកើនឡើងនៃឧស្សាហកម្មសំណង់មាន ៦.៧៦០ គម្រោងដែលបានអនុម័តក្នុងឆ្នាំ២០២២ ស្មើនឹង ១៥,៥២ ពាន់លានដុល្លាអាមេរិក។ ឌី បី ឌី គឺជាក្រុមហ៊ុនសំណង់ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើការផ្តល់សេវាកម្ម MEP ដែលមានដូចជា (១)ផ្នែកមេកានិច និងអគ្គិសនី (២)ប្រព័ន្ធទឹក និងពន្លត់អគ្គិភ័យ (៣)កម្តៅ ខ្យល់ចេញចូល និងប្រព័ន្ធម៉ាស៊ីនត្រជាក់ និង (៤) ការថែទាំអគារ ដូច្នេះវាគឺជាឱកាសដ៏ល្អសម្រាប់ ឌី បី ឌី នៅក្នុងទីផ្សារកំណើននេះ ។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ក្រុមហ៊ុន ឌី បី ឌី បានរួមបញ្ចូលការឡើងអតិផរណាដែលបានរំពឹងទុកនៅក្នុងសំណើរដែលដាក់ដេញថ្លៃគម្រោង។ ប្រសិនបើតម្លៃនៃវត្ថុធាតុដើមប្រែប្រួលស្របតាមអត្រាអតិផរណា វានឹងមិនមានផលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ។

### ៣. ការវិភាគលើពន្ធ

បច្ចុប្បន្នក្រុមហ៊ុន ឌី បី ឌី កំពុងស្ថិតនៅក្នុងការធ្វើសវនកម្មមិនពេញលេញពីអគ្គនាយកដ្ឋានពន្ធដារ សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែមិនា ឆ្នាំ២០២១ ហើយមិនមានកត្តាណាមួយដែលនឹងជះផលប៉ះពាល់ដល់ប្រាក់ចំណេញក្នុងឆ្នាំនេះនោះទេ ដោយសារភាពចាំបាច់នៃពន្ធភាគច្រើនសម្រាប់រយៈពេលសវនកម្មនេះត្រូវបានផ្តល់រួចហើយក្នុងឆ្នាំ ២០២០។

ក្រុមហ៊ុនបានទទួលនូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូល ៥០% សម្រាប់រយៈពេល៣ឆ្នាំ ដោយគិតចាប់ពីឆ្នាំ ២០២២ ដល់ ២០២៤។

### ៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

នៅក្នុងអំឡុងចុងការិបរិច្ឆេទនៃឆ្នាំ២០២១ នេះ ក្រុមហ៊ុនមិនមានប្រាក់ចំណូលដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ ប៉ុន្តែក្រុមហ៊ុនមានថ្លៃចំណាយលើក្រុមហ៊ុនធានាទិញមូលបត្រសម្រាប់ដំណើរការបោះផ្សាយលក់មូលបត្រជាលើកដំបូងរបស់ក្រុមហ៊ុន ឌី បី ឌី ចំនួន ១៨៨.៧៦៧,៩១ដុល្លាអាមេរិក។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នៅក្នុងឆ្នាំ២០២១ ឌី បី ឌី បានទទួលប្រាក់ចំណូលច្រើនជាងមុនពីការសាងសង់ បើធៀបទៅនឹងឆ្នាំ២០២០។ ប្រាក់ចំណូលពីការសាងសង់អាស្រ័យលើការងារដែលបានបំពេញរួចរាល់ ហើយក្នុងឆ្នាំ ២០២១ នេះ គម្រោងដ៏ធំរបស់ក្រុមហ៊ុន ដូចជា គម្រោង Chip Mong Mega Mall 271 គម្រោង Tribe Hotel និងគម្រោង Chip Mong Mall 598 ត្រូវបានបញ្ចប់មួយផ្នែកធំ។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណបរទេស និងអត្រាការប្រាក់

ក្រុមហ៊ុន ឌី បី ឌី មិនមានទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុជារូបិយប័ណ្ណបរទេសផ្សេងទៀតទេ លើកលែងតែមានទឹកប្រាក់តូចមួយចំនួនសម្រាប់គណនីអ្នកផ្គត់ផ្គង់ ដែលត្រូវបង់ជារូបិយប័ណ្ណថៃបាត (THB) និង អឺរ៉ូ (EUR) ។ រាល់កម្ចីទាំងអស់របស់ មានអត្រាថេរ ហើយឌី បី ឌី ក៏មិនមានការជួញដូរទំនិញដែរ ដូច្នេះ ឌី បី ឌី មិនមានផលប៉ះពាល់ខ្លាំងពីការប្រែប្រួលនៃការប្តូររូបិយប័ណ្ណបរទេស អត្រាការប្រាក់ទេ និងតម្លៃទំនិញទេ។

## ង. ផលប៉ះពាល់នៃអតិផរណា

ឌី បី ឌី បានរួមបញ្ចូលការឡើងអតិផរណាដែលបានរំពឹងទុកនៅក្នុងសំណើរដែលដាក់ដេញថ្លៃគម្រោង។ ប្រសិនបើតម្លៃនៃវត្ថុធាតុដើមប្រែប្រួលស្របតាមអត្រាអតិផរណា វានឹងមិនមានផលប៉ះពាល់ខ្លាំងដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យអចលនទ្រព្យ និងសំណង់គឺជាកត្តាចម្បងមួយជំរុញកំណើនសេដ្ឋកិច្ច។ យោងតាមរបាយការណ៍របស់ CBRE ទស្សនវិស័យទីផ្សារអចលនទ្រព្យកម្ពុជាឆ្នាំ ២០១៩ ឧស្សាហកម្មសំណង់បានកើនឡើង ១៨,១% រីឯនៅក្នុងឆ្នាំ ២០១៨ ចំនួនខុនដូកើនឡើងប្រហែល ១២០%។ ខណៈពេលដែលកត្តាកំណើនសេដ្ឋកិច្ចចម្រុះចូលទៅក្នុងដំណើរការដ៏រឹងមាំនៃឧស្សាហកម្មសំណង់ ការវិនិយោគផ្ទាល់ពីបរទេស (FDI) គឺជាកត្តាជំរុញដ៏សំខាន់មួយនៃឧស្សាហកម្មនេះ។ ក្នុងឆ្នាំ២០១៩ FDI នៅកម្ពុជាមានចំនួន ១០,៦% នៃទិន្នផលក្នុងស្រុកសរុប (GDP) សរុប។ ក្នុងឆ្នាំ២០១៨ ការវិនិយោគផ្ទាល់ពីបរទេសបានឈានដល់កម្រិតខ្ពស់បំផុតដោយកើនឡើង ១០,៧% ឬ ៣០០ លានដុល្លា ពី ២,៨ ពាន់លានដុល្លា ក្នុងឆ្នាំ២០១៧ ដល់ ៣,១ ពាន់លានដុល្លា ក្នុងឆ្នាំ២០១៨ (ធនាគារពិភពលោក)។ ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ក្នុងស្រុក ការកែតម្រូវទីផ្សារអចលនទ្រព្យបន្ទាប់ពីការសាងសង់អូសបន្លាយពេលយូរ និងការរីកដុះដាលនៃអចលនទ្រព្យ ការផ្តល់ឥណទានកើនឡើងដល់វិស័យសំណង់/អចលនទ្រព្យ/កម្ចីទិញផ្ទះ (ដែលថ្មីៗនេះពឹងផ្អែកខ្លាំងលើការវិនិយោគរបស់ចិន) និងឥណទាន គឺជាចំណុចខ្សោយនៃឧស្សាហកម្មបច្ចុប្បន្ន។

យោងតាមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានឱ្យដឹងថា ក្នុងឆ្នាំ២០២១ មានគម្រោងសាងសង់ចំនួន ៤.៣០៣ ត្រូវបានអនុម័តដោយទុនវិនិយោគចំនួន ៥,៣៣ ពាន់លានដុល្លាអាមេរិក ថយចុះ ៣១,២១% បើធៀបនឹងឆ្នាំ២០២០ មានគម្រោងសាងសង់ចំនួន ៤.៨៤១ ដែលមានទុនវិនិយោគចំនួន ៧,៧៥ ពាន់លានដុល្លាអាមេរិក។

# ហត្ថលេខារបស់អភិបាល

កាលបរិច្ឆេទ: ១២ មេសា ២០២២

បានអាន និងឯកភាព:

------------------------------

ឈ្មោះ: **នាង វិធី**

តំណែង: **ប្រធានក្រុមប្រឹក្សាភិបាល**

កាលបរិច្ឆេទ: ១២ មេសា ២០២២

បានអាន និងឯកភាព:

------------------------------

ឈ្មោះ: **ថៃ វ៉ាន់ថា**

តំណែង: **អភិបាលមិនប្រតិបត្តិ**

កាលបរិច្ឆេទ: ១២ មេសា ២០២២

បានអាន និងឯកភាព:

------------------------------

ឈ្មោះ: **លឹម មុយលី**

តំណែង: **អភិបាលប្រតិបត្តិ**

កាលបរិច្ឆេទ: ១២ មេសា ២០២២

បានអាន និងឯកភាព:

------------------------------

ឈ្មោះ: **ហ៊ុយ វ៉ាថារ៉ូ**

តំណែង: **អភិបាលឯករាជ្យ**

# ឧបសម្ព័ន្ធនៃរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

# ឆ្នាំ២០២១

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
# និង
# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច

## ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ពីមុនត្រូវបានគេស្គាល់ជា ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីរីង ខូអិលធីឌី)

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

# មាតិកា


| | ទំព័រ |
|---|---|
| **របាយការណ៍របស់ក្រុមប្រឹក្សាភិបាល** | **១ - ៣** |
| **របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច៖** | |
| របាយការណ៍របស់សវនករឯករាជ្យ | ៤ - ៨ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៩ - ១០ |
| របាយការណ៍ចំណូលលម្អិត | ១១ |
| របាយការណ៍បម្រែបម្រួលមូលធន | ១២ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១៣ - ១៤ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុនានា | ១៥ - ៤៨ |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ពីមុនមកគេស្គាល់ថាជា ឌី ប៊ី ឌី អ៊ិនជីនារីង ខូអិលធីឌី) (ហៅកាត់ថា "ក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ (ហៅកាត់ថា "ការិយបរិច្ឆេទ")។

## ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ ក្រោមវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ ០០០០៤០២៩ នៅក្រសួងពាណិជ្ជកម្ម។ ដោយអនុលោមតាមលក្ខន្តិកៈក្រុមហ៊ុន ដែលអនុញ្ញាតអោយដំណើរការអាជីវកម្មរយៈពេល៩៩ឆ្នាំ គិតចាប់ផ្ដើមពីកាលបរិច្ឆេទចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ("MoC") នៃព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបានប្ដូរឈ្មោះពី ឌី ប៊ី ឌី អ៊ិនជីនារីង ខូអិលធីឌី ទៅជា ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បន្ទាប់ទទួលបានការអនុម័តពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១ ក្រុមហ៊ុនបានចុះបញ្ជីដោយជោគជ័យជាមួយផ្សារមូលប័ត្រកម្ពុជា ("CSX")។ ចំនួនហ៊ុនថ្មីដែលបានបោះផ្សាយមាន ៦.៤៦១.៥៣៨ ហ៊ុនជាមួយតម្លៃចារឹក ១.០០០ រៀល (០.២៥ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន ក្នុងតម្លៃលក់ចេញ ២.៣៨០ រៀល (០.៥៨ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន។ ក្រុមហ៊ុនទទួលទឹកប្រាក់ពីការបោះផ្សាយលក់ភាគហ៊ុនជាសាធារណៈលើកដំបូង ("IPO") ក្នុងទំហំទឹកប្រាក់ចំនួន ៣.៧៧៣.៥៣៩ ដុល្លារអាមេរិក ជាលទ្ធផលក្នុងបុព្វលាភភាគហ៊ុនចំនួន ២.១៥៨.១៥៤ ដុល្លារអាមេរិក (៨.៧៧៩.៣៧០.០០០ រៀល)។ នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនទាន់ធ្វើការអនុម័តទៅលើការវិសោធនកម្មលើលក្ខខន្តិកៈក្រុមហ៊ុន ("MAA") ដែលទាក់ទងនឹងការបង្កើនដើមទុនពី IPO។

ការិយាល័យចុះបញ្ជី និងទីតាំងអាជីវកម្មគោលរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅដីឡូតិ៍លេខ៦៨ ផ្លូវ៥៩៨ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ប្រអប់សំបុត្រ ១៧៨ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ក្រុមហ៊ុនមាននិយោជិត ៩៦៦ នាក់ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ ១.០៤៣ នាក់)។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺ ធ្វើប្រតិបត្តិការជាអ្នកម៉ៅការផ្នែកមេកានិក និងអគ្គិសនី អ្នកម៉ៅការប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ ប្រព័ន្ធម៉ាស៊ីនត្រជាក់ក្នុងបន្ទប់ HVAC និងអ្នកម៉ៅការថែទាំអាគារផ្សេងៗ។ មិនមានការផ្លាស់ប្ដូរលើសកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទឡើយ។

## លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងស្ថានភាពអាជីវកម្មរបស់ក្រុមហ៊ុននាកាលបរិច្ឆេទនោះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ។

ក្រុមប្រឹក្សាពុំបានផ្តល់អនុសាសន៍ឱ្យធ្វើការទូទាត់ភាគលាភសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ (ឆ្នាំ២០២០៖ គ្មាន)។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅក្នុងអំឡុងការិយបរិច្ឆេទ និងរហូតដល់កាលបរិច្ឆេទនៃការរបាយការណ៍នេះមានដូចខាងក្រោម៖

| **ឈ្មោះ** | **មុខតំណែង** | **កាលបរិច្ឆេទនៃការតែងតាំង** |
|---|---|---|
| លោក នាង វិធី | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ |
| លោកស្រី លឹម មុយលី | អភិបាល | ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ |
| លោក ថៃ វ៉ាន់ថា | អភិបាល | ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ |
| លោក ហ៊ុយ វ៉ាថារ៉ូ | អភិបាលឯករាជ្យ | ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានធ្វើសវនកម្ម ដោយក្រុមហ៊ុនស្នងការគណនេយ្យ ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត។

## ភាគហ៊ុនរបស់ក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុន

អនុលោមតាមលក្ខន្តិកៈក្រុមហ៊ុន ភាគហ៊ុនរបស់ក្រុមប្រឹក្សាភិបាលកាន់តំណែងនាការិយបរិច្ឆេទដែលបានបញ្ចប់ ជាភាគហ៊ុនធម្មតារបស់ក្រុមហ៊ុន និងសាជីវកម្មពាក់ព័ន្ធក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | **% កម្មសិទ្ធិ** | **ចំនួនហ៊ុន** | % កម្មសិទ្ធិ | ចំនួនហ៊ុន |
| លោក នាង វិធី | ៤៥.៥០% | ៨.៤០០.០០០ | ៧០% | ៨.៤០០.០០០ |
| លោកស្រី លឹម មុយលី | ១៩.៥០% | ៣.៦០០.០០០ | ៣០% | ៣.៦០០.០០០ |
| | ៦៥.០០% | ១២.០០០.០០០ | ១០០% | ១២.០០០.០០០ |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានទំនួលខុសត្រូវក្នុងការអះអាងថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ បង្ហាញនូវភាពត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

i. អនុវត្តលើគោលនយោបាយគណនេយ្យដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

ii. អនុវត្តតាមការតម្រូវនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវក្រុមប្រឹក្សាភិបាលត្រូវធានាឱ្យបានថាការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

iii. រក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព

iv. រៀបចំរបាយការន៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋានបន្តនិរន្តរភាព លើកលែងតែវាមិនសមស្របក្នុងការសន្មតថាក្រុមហ៊ុនអាចនឹងបន្តប្រតិបត្តិការអាជីវកម្មរបស់ខ្លួនបាននាពេលអនាគត និង

v. ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព និងចូលរួមលើរាល់សេចក្ដីសម្រេចសំខាន់ៗទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន និងឬ/ត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឱ្យសមស្របដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុបណ្ដោះអាសន្នដែលភ្ជាប់មកជាមួយ រួមមានរបាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ ព្រមជាមួយនឹងកំណត់សម្គាល់នានា ត្រូវបានបង្ហាញនូវទិដ្ឋភាពពិតជាសារវន្ត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

ជំនួសឱ្យក្រុមប្រឹក្សាភិបាល

**លោក នាង វិធី**
**ប្រធានក្រុមប្រឹក្សាភិបាល**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២


DBD Engineering Plc. #68, St.598, SK. Phnom Penh Thmey, K. Sensok, Phnom Penh, CAMBODIA
Tel: (855)78 700 598, E-mail: services@dbdengineering.com, www.dbdengineering.com

Grant Thornton

# របាយការណ៍របស់សវនករឯករាជ្យ

**ហ្រ្គេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
**លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០**
www.grantthornton.com.kh

**ជូនចំពោះភាគហ៊ុននិករបស់**
**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (ពីមុនគេស្គាល់ថាជាក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ខូអិលធីឌី) (ហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ព្រមជាមួយកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់បន្ថែមផ្សេងៗ ទៀត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិតជាសារវន្ត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ។

## មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.ស.អ.ក")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុន ដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌ របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) ("IESBA Code") រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

## បញ្ហាសវនកម្មសំខាន់ៗ

បញ្ហាសវនកម្មសំខាន់ៗ គឺជាបញ្ហាទាំងឡាយដែលកើតមាននៅក្នុងការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំ មានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។ បញ្ហាទាំងនេះត្រូវបានដោះស្រាយក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនជារួម ក្នុងការបញ្ចេញមតិយោបល់សវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំមិនធ្វើការបញ្ចេញមតិយោបល់ដាច់ឡែកទាក់ទងនឹងបញ្ហាទាំងនេះឡើយ។

Grant Thornton

ខាងក្រោមនេះជាបញ្ហាសវនកម្មសំខាន់ៗដែលបានកំណត់អត្តសញ្ញាណក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន៖

| បញ្ហាសវនកម្មសំខាន់ៗ | ការដោះស្រាយបញ្ហាសវនកម្មសំខាន់ៗរបស់យើងខ្ញុំ |
|---|---|
| **ការទទួលស្គាល់ចំណូល និងថ្លៃដើមពីការសាងសង់ និងសេវាកម្មថែទាំ និងការលក់ទំនិញ**<br><br>ការទទួលស្គាល់ចំណូល និងថ្លៃដើមពីការសាងសង់ និងសេវាកម្មថែទាំ និងការលក់ទំនិញ ត្រូវបានទទួលស្គាល់ដោយអនុលោមតាមគោលនយោបាយគណនេយ្យ និងការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ ដូចដែលបានរៀបរាប់លម្អិតក្នុងកំណត់សម្គាល់ ៤.១២ និង ៥ ទៅលើរបាយការណ៍ហិរញ្ញវត្ថុនានា។<br><br>យើងខ្ញុំផ្តោតសំខាន់លើបញ្ហាទាំងនេះ ដោយសារការវិនិច្ឆ័យ និងការប៉ាន់ស្មានរបស់គណៈគ្រប់គ្រងសំខាន់ៗ បានរួមចំណែកក្នុងការកំណត់ដូចខាងក្រោម៖<br><br>(i) តម្លៃប្រតិបត្តិការលើកិច្ចសន្យាជាមួយអតិថិជនដែលរួមបញ្ចូលទាំងសមាសធាតុហិរញ្ញវត្ថុសំខាន់ៗ<br>(ii) រយៈពេលដែលចំណូលក្នុងកិច្ចសន្យាត្រូវបានទទួលស្គាល់<br>(iii) តម្លៃសមស្របដែលពាក់ព័ន្ធក្នុងការផ្តល់សេវាកម្ម និងការបែងចែកការទូទាត់ដែលបានទទួល ឬដែលត្រូវទទួលពីការបំពេញកាតព្វកិច្ច និងវិសាលភាពថ្លៃដើមកិច្ចសន្យាដែលបានកើតឡើងរហូតដល់កាលបរិច្ឆេទនោះ។ | **ក្នុងការផ្តោតសំខាន់លើការដោះស្រាយបញ្ហានេះ យើងខ្ញុំបានអនុវត្តនីតិវិធីមួយចំនួនក្នុងចំណោមនីតិវិធីផ្សេងៗដូចខាងក្រោម៖**<br><br>- លក្ខខណ្ឌដែលបានប្រើប្រាស់មានចែងក្នុងកិច្ចសន្យាជាមួយអតិថិជន និងអ្នកម៉ៅការ/អ្នកផ្គត់ផ្គង់ ដើម្បីកំណត់លើកិច្ចសន្យាសំខាន់ៗ ដាច់ដោយឡែក និងបានវាយតម្លៃលើទំនាក់ទំនងលើចំណូល និងថ្លៃដើមដែលបានទទួលស្គាល់<br>- បានវាយតម្លៃលើភាពសមស្រប និងភាពស៊ីសង្វាក់គ្នាក្នុងការសន្មតសំខាន់ៗដែលបានប្រើប្រាស់ដោយគណៈគ្រប់គ្រងក្នុងការកំណត់តម្លៃប្រតិបត្តិការលើកិច្ចសន្យាជាមួយអតិថិជនដែលរួមមានសមាសធាតុហិរញ្ញវត្ថុសំខាន់ៗ តម្លៃសមស្របរបស់សេវាកម្មក្នុងការបញ្ជូន និងមូលដ្ឋានក្នុងការបែងចែកលើការទូទាត់ដែលបានទទួល និង/ឬត្រូវទទួលក្នុងសេវាកម្មនីមួយ និង<br>- បានវាយតម្លៃលើថ្លៃដើមជាក់ស្តែងដែលបានកើតឡើង និងថ្លៃដើមបង្គរតាមរយៈការពិនិត្យលើភស្តុតាងដូចជាដំណើរការទាមទារសំណងរបស់អ្នកម៉ៅការ និងវិក័យបត្ររបស់អ្នកផ្គត់ផ្គង់ក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ និង/ឬ ឆ្នាំហិរញ្ញវត្ថុបន្ទាប់។ |

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗទាំងនោះរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ។ ហើយយើងខ្ញុំមិនផ្តល់ការធានាក្នុងទម្រង់បែបណាមួយឡើយ។

Grant Thornton

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្ត ឬទេ។

ប្រសិនបើ ផ្អែកតាមការងារដែលយើងធ្វើសវនកម្ម យើងខ្ញុំសន្និដ្ឋានថាមានកំហុសជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗ ទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលនៅលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលក្រុមប្រឹក្សាភិបាលកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើសមត្ថភាពក្រុមហ៊ុនក្នុងការបន្តប្រតិបត្តិដោយផ្អែកលើមូលដ្ឋាននិរន្តរភាពការលាតត្រដាងប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យលុះត្រាតែក្រុមប្រឹក្សាភិបាលមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

## ការទទួលខុសត្រូវរបស់សវនករនៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs") នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលកើតមានឡើងនោះឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើអោយប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា("CISAs") យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គង រៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

Grant Thornton

- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្ម ដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។

- ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។

- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់ក្រុមប្រឹក្សាភិបាលលើមូលដ្ឋាននិរន្តរភាពគណនេយ្យផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់ក្រុមហ៊ុន។ ប្រសិនបើយើងសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវ នឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានាថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងគណៈគ្រប់គ្រងទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបបគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់ជូនគណៈគ្រប់គ្រង នូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលនូវបញ្ហាទាំងអស់ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន។

Grant Thornton

បញ្ហាដែលយើងខ្ញុំបានជម្រាបជូនក្រុមប្រឹក្សាភិបាល គឺជាបញ្ហាដែលយើងខ្ញុំកំណត់ថាមានសារៈសំខាន់បំផុត នៅក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ហើយបញ្ហានេះគឺជាបញ្ហាសំខាន់ក្នុងការធ្វើសវនកម្ម។ យើងខ្ញុំបង្ហាញបញ្ហានេះ នៅក្នុងរបាយការណ៍សវនកម្មលើកលែងតែច្បាប់ ឬបទប្បញ្ញត្តិ រារាំងនូវការលាតត្រដាងជាសាធារណៈអំពីបញ្ហានេះក្នុងការធ្វើសវនកម្ម ឬក៏ក្នុងកាលៈទេសៈដ៏កម្របំផុត នៅពេលដែលយើងខ្ញុំរកឃើញថាបញ្ហានោះ មិនគួរត្រូវបានបង្ហាញក្នុងរបាយការណ៍ របស់យើងខ្ញុំ ដោយសារតែផលអវិជ្ជមាន អាចមានច្រើនជាងអត្ថប្រយោជន៍ជាសាធារណៈ ដែលកើតចេញពីការជូនដំណឹងនេះ។

Grant Thornton

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ពាន់រៀល (កំណត់សម្គាល់ ៤.២) | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | **២.៦៤៣.០៦២** | **១០.៧៦៧.៨៣៥** | ២.៦០០.០១៥ | ១០.៥១៧.០៦១ |
| ទ្រព្យសកម្មអរូបី - សុទ្ធ | ៧ | **៣៣.៩៨៦** | **១៣៨.៤៥៩** | ៣៧.៤៥៦ | ១៥១.៥១០ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម - សុទ្ធ | ៨ | **៣២.៧៤៥** | **១៣៣.៤០៣** | ៧០.៤០២ | ២៨៤.៧៧៦ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | ៩ | **២០.០៥០** | **៨១.៦៨៤** | ៥៩.០៥០ | ២៣៨.៨៥៧ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **២.៧២៩.៨៤៣** | **១១.១២១.៣៨១** | ២.៧៦៦.៩២៣ | ១១.១៩២.២០៤ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| ទ្រព្យសកម្មកិច្ចសន្យា | ១៥ | **៣.៧៩១.៣៦៦** | **១៥.៤៤៦.០២៥** | ៣.១៥០.៨៣០ | ១២.៧៤៥.១០៧ |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | ១៤ | **៩៤៦.៩៦២** | **៣.៨៥៧.៩២៣** | ៤៥៧.៤៧៦ | ១.៨៥០.៤៩០ |
| សមតុល្យត្រូវទទួលពីម្ចាស់ភាគហ៊ុន | ២៦ | **១៣៤.៤២១** | **៥៤៧.៦៣១** | - | - |
| សន្និធិ - សុទ្ធ | ១៣ | **២.១៦៧.២៥៨** | **៨.៨២៩.៤០៩** | ១.៦៣៣.៨១៦ | ៦.៦០៨.៧៨៦ |
| គណនីពាណិជ្ជត្រូវទទួល | ១២ | **៦.២៧៣.០៥៧** | **២៥.៥៥៦.៤៣៤** | ១.៤៨៧.២១៩ | ៦.០១៥.៨០១ |
| ប្រាក់តម្កល់ដើម្បីធានា | ១១ | **៦៥.០០០** | **២៦៤.៨១០** | ២១០.៥៤៥ | ៨៥១.៦៥៥ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១០ | **២២៥.១១៩** | **៩១៧.១៣៥** | ២៨៣.១២៤ | ១.១៤៥.២៣៧ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **១៣.៦០៣.១៨៣** | **៥៥.៤១៩.៣៦៧** | ៧.២២៣.០១០ | ២៩.២១៧.០៧៦ |
| **ទ្រព្យសកម្មសរុប** | | **១៦.៣៣៣.០២៦** | **៦៦.៥៤០.៧៤៨** | ៩.៩៨៩.៩៣៣ | ៤០.៤០៩.២៨០ |
| **មូលធន** | | | | | |
| ដើមទុន | ១៦ | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | ៣.០០០.០០០ | ១២.២២៥.៣០១ |
| បុព្វលាភដើមទុន | ១៦.១ | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | - | - |
| ប្រាក់ចំណេញរក្សាទុក | | **២.២៨១.៦៦៤** | **៩.៤៤១.៨៨៧** | ១.៨៦៨.៩៨២ | ៧.៧៦៣.០៩៦ |
| រូបិយប័ណ្ណប្តូរបម្រុងទុក | | - | **(១២៧.០៤៧)** | - | (២៩៣.៣៦៥) |
| **មូលធនសរុប** | | **៩.០៥៥.២០៣** | **៣៦.៨៩០.៨៩៧** | ៤.៨៦៨.៩៨២ | ១៩.៦៩៥.០៣២ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី - រយៈពេលវែងសុទ្ធ | ១៧ | **៨១១.៣២០** | **៣.៣០៥.៣១៨** | ១.១៨១.៨២៤ | ៤.៧៨០.៤៧៨ |
| បំណុលភតិសន្យា - រយៈពេលវែងសុទ្ធ | ៨ | - | - | ៤៨.៥១០ | ១៩៦.២២៣ |
| **បំណុលរយៈពេលវែងសរុប** | | **៨១១.៣២០** | **៣.៣០៥.៣១៨** | ១.២៣០.៣៣៤ | ៤.៩៧៦.៧០១ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ត)

| | កំណត់សម្គាល់ | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** **ដុល្លារអាមេរិក** | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **បំណុលរយៈពេលខ្លី** | | | | | |
| ប្រាក់កម្ចី | ១៧ | **២.៥១៩.០១១** | **១០.២៦២.៤៥១** | ៩៦៧.២០៧ | ៣.៩១២.៣៥២ |
| គណទានវិបារូបន៍ | ១៨ | **១.៨៧១.១១២** | **៧.៦២២.៩១០** | ១.៧២៤.៥៩២ | ៦.៩៧៥.៩៧៥ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ១៩ | **១.៨៣១.២១៥** | **៧.៤៦០.៣៧០** | ៦៩៧.១៦៨ | ២.៨២០.០៤៦ |
| សមតុល្យត្រូវសងទៅម្ចាស់ភាគហ៊ុន | ២៦ | - | - | ៥.៦៤២ | ២២.៨២២ |
| បំណុលភតិសន្យា | ៨ | **៤៨.៥០៩** | **១៩៧.៦២៦** | ៦០.០៩០ | ២៤៣.០៦៤ |
| បំណុលកិច្ចសន្យា | ១៥ | **១៦១.៨៨០** | **៦៥៩.៤៩៩** | ៤០៧.៩៥៣ | ១.៦៥០.១៧០ |
| បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | ២៥.៣ | **៣៤.៧៧៦** | **១៤១.៦៧៧** | ២៧.៩៦៥ | ១១៣.១១៨ |
| **បំណុលរយៈពេលខ្លីសរុប** | | **៦.៤៦៦.៥០៣** | **២៦.៣៤៤.៥៣៣** | ៣.៨៩០.៦១៧ | ១៥.៧៣៧.៥៤៧ |
| **បំណុលសរុប** | | **៧.២៧៧.៨២៣** | **២៩.៦៤៩.៨៥១** | ៥.១២០.៩៥១ | ២០.៧១៤.២៤៨ |
| **មូលធន និងបំណុលសរុប** | | **១៦.៣៣៣.០២៦** | **៦៦.៥៤០.៧៤៨** | ៩.៩៨៩.៩៣៣ | ៤០.៤០៩.២៨០ |

# របាយការណ៍ចំណូលលម្អិត

| | កំណត់សម្គាល់ | **សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ចំណូល | ២០ | **១៧.៩៦៤.២២៨** | **៧៣.០៧៨.៤៨០** | ១៣.៤៦៣.១៨៨ | ៥៤.៨៨៩.៤១៧ |
| ថ្លៃដើមទំនិញ និងសេវាកម្ម | ២១ | **(១៥.៤០៩.៤១០)** | **(៦២.៦៨៥.៤៨០)** | (១១.២០៤.១៣៤) | (៤៥.៦៧៩.២៥៤) |
| **ចំណេញដុល** | | **២.៥៥៤.៨១៨** | **១០.៣៩៣.០០០** | ២.២៥៩.០៥៤ | ៩.២១០.១៦៣ |
| ចំណូលផ្សេងៗ - សុទ្ធ | ២៣ | **២៨.០៦៣** | **១១៤.១៦០** | ៥៣.៦៣១ | ២១៨.៦៥៤ |
| ចំណាយប្រតិបត្តិការ | ២២ | **(១.៤៨៣.៥៧៥)** | **(៦.០៣៥.១៨៣)** | (១.៤៩៨.៣២៧) | (៦.១០៨.៦៧៩) |
| បន្ទុកហិរញ្ញប្បទាន | ២៤ | **(៥០៦.៨៧០)** | **(២.០៦១.៩៤៧)** | (៣៦៩.៤៧៥) | (១.៥០៦.៣៥០) |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | | **៥៩២.៤៣៦** | **២.៤១០.០៣០** | ៤៤៤.៨៨៣ | ១.៨១៣.៧៨៨ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៥.១ | **(១៧៩.៧៥៤)** | **(៧៣១.២៣៩)** | (១៤០.០០១) | (៥៧០.៧៨៤) |
| **ចំណេញក្នុងការិយបរិច្ឆេទ** | | **៤១២.៦៨២** | **១.៦៧៨.៧៩១** | ៣០៤.៨៨២ | ១.២៤៣.០០៤ |
| (ចំណេញ)/ខាតលម្អិតផ្សេងៗ | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **១៦៦.៣១៨** | - | (១៤៦.៦៨០) |
| **ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | | **៤១២.៦៨២** | **១.៨៤៥.១០៩** | ៣០៤.៨៨២ | ១.០៩៦.៣២៤ |

# របាយការណ៍បម្រែបម្រួលមូលធន

| | ដើមទុន | | បុព្វលាភដើមទុន | | ប្រាក់ចំណេញរក្សាទុក | | រូបិយប័ណ្ណប្តូរបម្រុងទុក | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ៣.០០០.០០០ | ១២.២២៥.៣០១ | - | - | ១.៨៦៨.៩៨២ | ៧.៧៦៣.០៩៦ | (២៩៣.៣៦៥) | ៤.៨៦៨.៩៨២ | ១៩.៦៩៥.០៣២ |
| ការបន្ថែមដើមទុន | ១.៦១៥.៣៨៥ | ៦.៥៧១.៣៨៦ | ២.១៥៨.១៥៤ | ៨.៧៧៩.៣៧០ | - | - | - | ៣.៧៧៣.៥៣៩ | ១៥.៣៥០.៧៥៦ |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | ៤១២.៦៨២ | ១.៦៧៨.៧៩១ | - | ៤១២.៦៨២ | ១.៦៧៨.៧៩១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | ១៦៦.៣១៨ | - | ១៦៦.៣១៨ |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | **២.១៥៨.១៥៤** | **៨.៧៧៩.៣៧០** | **២.២៨១.៦៦៤** | **៩.៤៤១.៨៨៧** | **(១២៧.០៤៧)** | **៩.០៥៥.២០៣** | **៣៦.៨៩០.៨៩៧** |
| | | | | | | | | | |
| សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ១៤២.៥០០ | ៥៧៥.២៧៣ | - | - | ៤.៤២១.៦០០ | ១៨.១៧០.១២០ | (១៤៦.៦៨៥) | ៤.៥៦៤.១០០ | ១៨.៥៩៨.៧០៨ |
| ការបន្ថែមដើមទុន | ២.៨៥៧.៥០០ | ១១.៦៥០.០២៨ | - | - | (២.៨៥៧.៥០០) | (១១.៦៥០.០២៨) | - | - | - |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | ៣០៤.៨៨២ | ១.២៤៣.០០៤ | - | ៣០៤.៨៨២ | ១.២៤៣.០០៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | (១៤៦.៦៨០) | - | (១៤៦.៦៨០) |
| សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ៣.០០០.០០០ | ១២.២២៥.៣០១ | - | - | ១.៨៦៨.៩៨២ | ៧.៧៦៣.០៩៦ | (២៩៣.៣៦៥) | ៤.៨៦៨.៩៨២ | ១៩.៦៩៥.០៣២ |

# របាយការណ៍លំហូរសាច់ប្រាក់

| | កំណត់សម្គាល់ | **សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | **៥៩២.៤៣៦** | **២.៤១០.០៣០** | ៤៤៤.៨៨៣ | ១.៨១៣.៧៨៨ |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់លើទ្រព្យរូបី និងរំលស់លើទ្រព្យអរូបី | ៦. ៧ និង ៨ | **១៧៨.៩១៥** | **៧២៧.៨២៦** | ១៦៣.៨៥៤ | ៦៦៨.០៣៣ |
| បន្ទុកហិរញ្ញប្បទាន | ២៤ | **៥០៦.៨៧០** | **២.០៦១.៩៤៧** | ៣៦៩.៤៧៥ | ១.៥០៦.៣៥០ |
| ខាតលើការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មរូបី | ២៣ | **១.៨២០** | **៧.៤០៤** | ៩១៤ | ៣.៧២៦ |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **១.២៨០.០៤១** | **៥.២០៧.២០៧** | ៩៧៩.១២៦ | ៣.៩៩១.៨៩៧ |
| **បម្រែបម្រួលទុបបង្វិល** | | | | | |
| **បម្រែបម្រួលសុទ្ធក្នុង៖** | | | | | |
| ទ្រព្យសកម្មកិច្ចសន្យា | | **(៦៤០.៥៣៦)** | **(២.៦០៥.៧០០)** | (៧៤៣.៨៨២) | (៣.០៣២.៨០៧) |
| ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ | | **(៤៨៩.៤៨៥)** | **(១.៩៩១.២២៥)** | ២២៣.១១៩ | ៩០៩.៦៥៦ |
| សមតុល្យត្រូវទទួលពីម្ចាស់ភាគហ៊ុន | | **(១៣៤.៤២១)** | **(៥៤៦.៨២៥)** | - | - |
| សន្និធិ - សុទ្ធ | | **(៥៣៣.៤៤២)** | **(២.១៧០.០៤២)** | (៤០០.៣០៩) | (១.៦៣២.០៦០) |
| ប្រាក់តម្កល់ធានា | | **១៤៥.៥៤៥** | **៥៩២.០៧៧** | ៨៦២.៦០២ | ៣.៥១៦.៨២៨ |
| គណនីពាណិជ្ជត្រូវទទួល | | **(៤.៧៨៥.៨៣៨)** | **(១៩.៤៦៨.៧៨៩)** | ៤៣២.៧២២ | ១.៧៦៤.២០៨ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | | **៣៩.០០០** | **១៥៨.៦៥២** | (២៤.០៥០) | (៩៨.០៥២) |
| ឥណទានវិបារូបវ៍ | | **១៤៦.៥២០** | **៥៩៦.០៤៣** | ២៦០.៦៨៦ | ១.០៦២.៨១៧ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | | **១.១៣៤.០៤៧** | **៤.៦១៣.៣០៣** | (៦៥៦.២៧៩) | (២.៦៧៥.៦៤៩) |
| បំណុលកិច្ចសន្យា | | **(២៤៦.០៧៣)** | **(១.០០១.០២៥)** | ២៦១.៨៥២ | ១.០៦៧.៥៧១ |
| សមតុល្យត្រូវសងទៅម្ចាស់ភាគហ៊ុន | | **(៥.៦៤២)** | **(២២.៩៥២)** | (២៧.៤៣៣) | (១១១.៨៤៤) |
| **សាច់ប្រាក់(ប្រើក្នុង)/បានពីសកម្មភាពប្រតិបត្តិការ** | | **(៤.០៩០.២៨៤)** | **(១៦.៦៣៩.២៧៦)** | ១.១៦៨.១៥៤ | ៤.៧៦២.៥៦៥ |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | ២៥.៣ | **(១៧២.៩៤៣)** | **(៧០៣.៥៣២)** | (១១២.០៣៦) | (៤៥៦.៧៧១) |
| **សាច់ប្រាក់សុទ្ធ(ប្រើក្នុង)/បានពីសកម្មភាពប្រតិបត្តិការ** | | **(៤.២៦៣.២២៧)** | **(១៧.៣៤២.៨០៨)** | ១.០៥៦.១១៨ | ៤.៣០៥.៧៩៤ |
| | | | | | |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | ៦ និង ៧ | **(១៨២.៨០៦)** | **(៧៤៣.៦៥៥)** | (១៧៧.៨០៥) | (៧២៤.៩១១) |
| ចំណូលពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | | **១៥០** | **៦១០** | ៨១ | ៣៣១ |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | **(១៨២.៦៥៦)** | **(៧៤៣.០៤៥)** | (១៧៧.៧២៤) | (៧២៤.៥៨០) |

# របាយការណ៍លំហូរសាច់ប្រាក់(ត)

| | កំណត់សម្គាល់ | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ពាន់រៀល (កំណត់សម្គាល់ ៤.២) | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដុល្លារអាមេរិក | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការបន្ថែមដើមទុន | ១៦ | **៣.៧៧៣.៥៣៩** | **១៥.៣៥០.៧៥៧** | - | - |
| ការទូទាត់បំណុលភតិសន្យា | ៨ | **(៦៧.២០១)** | **(២៧៣.៣៧៤)** | (៦៧.២០០) | (២៧៣.៩៧៥) |
| ការទូទាត់ប្រាក់កម្ចី | ១៧ | **(៧.៣០៥.៥២១)** | **(២៩.៧១៨.៨៥៩)** | (៦៦២.៩៨២) | (២.៧០២.៩៧៨) |
| ការដកប្រាក់កម្ចី | ១៧ | **៨.៤៨៦.៨២១** | **៣៤.៥២៤.៣៨៨** | ៤៧៥.៥៤៣ | ១.៩៣៨.៧៨៩ |
| ការទូទាត់ការប្រាក់ | ១៧ | **(៤៩៩.៧៦០)** | **(២.០៣៣.០២៤)** | (៣៥៦.៨៩៨) | (១.៤៥៥.០៧៣) |
| **សាច់ប្រាក់សុទ្ធបានពី/(ប្រើក្នុង) សកម្មភាព ហិរញ្ញប្បទាន** | | **៤.៣៨៧.៨៧៨** | **១៧.៨៤៩.៨៨៨** | (៦១១.៥៣៧) | (២.៤៩៣.២៣៧) |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធក្នុងអំឡុងការិយបរិច្ឆេទ** | | **(៥៨.០០៥)** | **(២៣៥.៩៦៥)** | ២៦៦.៨៥៧ | ១.០៨៧.៩៧៧ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមការិយបរិច្ឆេទ | | **២៨៣.១២៤** | **១.១៤៥.២៣៧** | ១៦.២៦៧ | ៦៦.២៨៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **៧.៨៦៣** | - | (៩.០២៨) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងការិយបរិច្ឆេទ** | ១០ | **២២៥.១១៩** | **៩១៧.១៣៥** | ២៨៣.១២៤ | ១.១៤៥.២៣៧ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

## ១. ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ ក្រោមវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ ០០០០៤០២៩ នៅក្រសួងពាណិជ្ជកម្ម។ ដោយអនុលោមតាមលក្ខន្តិកៈក្រុមហ៊ុន ដែលអនុញ្ញាតអោយដំណើរការអាជីវកម្មរយៈពេល៩៩ឆ្នាំ គិតចាប់ផ្តើមពីកាលបរិច្ឆេទចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ("MoC") នៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជី និងទីតាំងអាជីវកម្មគោលរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅដីឡូត៍លេខ៦៨ ផ្លូវ៥៩៨ ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ប្រអប់សំបុត្រ ១៧៨ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបានប្តូរឈ្មោះពី ឌី ប៊ី ឌី អ៊ិនជីនារីង ខូអិលធីឌី ទៅជា ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បន្ទាប់ទទួលបានការអនុម័តពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺ ធ្វើប្រតិបត្តិការជាអ្នកម៉ៅការផ្នែកមេកានិក និងអគ្គិសនី អ្នកម៉ៅការប្រព័ន្ធទឹក និងពន្លត់អគ្គីភ័យ ប្រព័ន្ធម៉ាស៊ីនត្រជាក់ក្នុងបន្ទប់ HVAC និងអ្នកម៉ៅការថែទាំអាគារផ្សេងៗ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ក្រុមហ៊ុនមាននិយោជិត ៩៦៦ នាក់ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ ១.០៤៣ នាក់)។

## ២. មូលដ្ឋាននៃការរៀបចំ និងរបាយការណ៍អនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា("ស.រ.ទ.ហ.អ.ក")

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

និយ័តករគណនេយ្យ និងសវនកម្មនៃកម្ពុជា ដោយយោងតាមសេចក្តីប្រកាសដែលបានធ្វើការកែប្រែ (សារាចរ) លេខ ០៦៨-សហវ-ប្រក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ដែលបានចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ត្រូវបានសម្រេចឱ្យអនុវត្តទាំងស្រុងទៅលើស្តង់ដារទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ("IFRS") ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ("IASB") ដោយមិនមានការធ្វើនិយ័តកម្មឡើយ។ ស្តង់ដារទាំងនេះត្រូវបានស្គាល់ថាជា ស.រ.ទ.ហ.អ.ក។

## ៣. ស្តង់ដារ និងការបកស្រាយថ្មី ឬដែលបានកែសម្រួលឡើងវិញ

### ៣.១. ស្តង់ដារ វិសោធនកម្ម និងការបកស្រាយទៅនឹងស្តង់ដារមានស្រាប់ដែលមិនទាន់មានប្រសិទ្ធភាព ប៉ុន្តែត្រូវបានអនុវត្តជាមុនដោយក្រុមហ៊ុន

នាកាលបរិច្ឆេទនៃសេចក្តីអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ មានលក្ខខណ្ឌថ្មីៗមួយចំនួន ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព ស្តង់ដារ និងវិសោធនកម្មទៅលើស្តង់ដារដែលមានស្រាប់ និងការបកស្រាយដែលបានចេញផ្សាយដោយ IASB។

ស្តង់ដារ និងវិសោធនកម្មផ្សេងៗដែលមិនទាន់មានប្រសិទ្ធភាពនៅឡើយ និងមិនទាន់បានអនុវត្តជាមុនដោយក្រុមហ៊ុនរួមមាន៖

- ស.រ.ទ.ហ.អ.ក ១៧ កិច្ចសន្យាធានារ៉ាប់រង
- ឯកសារយោងទាក់ទងនឹងក្របខណ្ឌទស្សនទាន
- ការជំនួសលើការកែប្រែលើទម្រង់ IBOR (វិសោធនកម្មលើ IFRS១៦ IFRS៩ និង IAS៣៩)
- ការហាមឃាត់ពីការកាត់ចំណូលពីសមាសធាតុដែលកើតមានលើទ្រព្យសម្បត្តិ និងបរិក្ខារ (វិសោធនកម្មលើ IAS ១៦)
- ចំណាយក្នុងការវាយតម្លៃលើកិច្ចសន្យាស្មុគស្មាញ (វិសោធនកម្មលើ IAS ៣៧)
- ការធ្វើចំណាត់ថ្នាក់លើបំណុល (វិសោធនកម្មលើ IAS ១)

ការធ្វើវិសោធនកម្មទាំងនេះ មិនត្រូវបានរំពឹងទុកថានឹងបង្ករឱ្យមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងកាលបរិច្ឆេទនៃការអនុវត្តដំបូង ហើយដូចនេះហើយមិនតម្រូវឱ្យមានកាលលាតត្រដាងណាមួយឡើយ។

## ៤. សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ

### ៤.១. មូលដ្ឋាននៃការរៀបចំរបាយការណ៍

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក USD ត្រូវបានរៀបចំឡើងក្រោមវិធីសាស្ត្រសន្មតថ្លៃដើម និងធ្វើឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

### ៤.២. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ប៉ុន្តែដោយសារមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមរបស់ក្រុមហ៊ុនជាដុល្លារអាមេរិក("USD") គណៈគ្រប់គ្រងបានកំណត់យករូបិយប័ណ្ណដុល្លារអាមេរិក ជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងនៃក្នុងការវាស់វែង និងការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងស្ថានភាពរបស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយវត្ថុបរទេស ក្រៅពីប្រាក់ដុល្លារអាមេរិក USD គឺត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក USD ក្នុងអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលជារូបិយវត្ថុ កំណត់ដោយ រូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក USD នាកាលបរិច្ឆេទរបាយការណ៍ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ("USD") តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ លម្អៀងពីការប្តូររូបិយប័ណ្ណ គឺត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត។

ការប្តូរចំនួនទឹកប្រាក់ពីដុល្លារអាមេរិក ទៅជាខ្មែររៀល បានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺក្នុងគោលបំណងដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មនៃកម្ពុជា ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ និងបានប្តូរដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការដែលបានបង្ហាញជាប្រាក់រៀលដោយយោងទៅតាមអត្រាប្តូរប្រាក់ក្នុង ១ដុល្លារអាមេរិកដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ("NBC")៖

| | **ឆ្នាំ២០២១** | ឆ្នាំ២០២០ |
|---|---|---|
| អត្រាប្តូរប្រាក់ជាមធ្យម* | **៤.០៦៨*** | ៤.០៧៧* |
| អត្រាប្តូរប្រាក់ចុងគ្រា | **៤.០៧៤** | ៤.០៩៥ |

*អត្រាប្តូរប្រាក់ជាមធ្យម គឺត្រូវបានកំណត់ដោយប្រើអត្រាប្តូរប្រាក់ជាមធ្យមប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា

អត្រាប្តូរប្រាក់ដោយដែលបានរៀបរាប់នេះ មិនត្រូវបានធ្វើសវនកម្មឡើយ និងមិនមែនជាមូលដ្ឋានសម្រាប់ការបកស្រាយថាចំនួនទឹកប្រាក់ជាប្រាក់ដុល្លារអាមេរិក នឹងអាចប្តូរទៅជាប្រាក់រៀលនៅថ្ងៃអនាគត ក្រោមអត្រាប្តូរប្រាក់ដដែល ឬអត្រាប្តូរប្រាក់ផ្សេងទៀតឡើយ។

## ៤.៣. ឧបករណ៍ហិរញ្ញវត្ថុ

### ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ និងចំណុលហិរញ្ញវត្ថុ គឺត្រូវបានទទួលស្គាល់ នៅពេលដែលក្រុមហ៊ុនបានក្លាយទៅជាភាគីនៃកិច្ចសន្យាសំវិធានធននៃឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលសិទ្ធិទៅលើលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានផុតកាលកំណត់ ឬនៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុ និងរាល់ហានិភ័យបន្ទាប់បន្សំទាំងអស់ និងអត្ថប្រយោជន៍ទាំងអស់ត្រូវបានផ្ទេរចេញ។

បំណុលហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលកាតព្វកិច្ច កិច្ចសន្យាបានបញ្ចប់ បានលុបចោល ឬផុតកាលកំណត់។

### ចំណាត់ថ្នាក់ និងការវាស់វែងដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ហើយត្រូវបានកែតម្រូវតាមថ្លៃប្រតិបត្តិការ (ប្រសិនបើមាន)។

ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមែនជាឧបករណ៍ជម្លៀសហានិភ័យ ត្រូវបានចាត់ថ្នាក់ជាប្រភេទដូចខាងក្រោម៖

- រំលស់បានរំលស់ថ្លៃដើម
- តម្លៃទីផ្សារសមស្របតាមរយៈប្រាក់ចំណេញ ឬខាត (FVTPL) ឬ
- តម្លៃទីផ្សារសមស្របតាមរយៈប្រាក់ចំណូលលម្អិតផ្សេងៗ (FVOCI)

ក្នុងការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានកំណត់តាមលក្ខខណ្ឌទាំងពីរខាងក្រោម៖

- គំរូអាជីវកម្មរបស់អង្គភាពសម្រាប់គ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ
- លក្ខណៈនៃលំហូរសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ។

រាល់ចំណូល និងចំណាយដែលទាក់ទងទៅជាមួយទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាតដែលបានបង្ហាញក្នុងគណនីចំណូលការប្រាក់ ឬចំណាយការប្រាក់។

### ការវាយតម្លៃជាបន្តបន្ទាប់នៃទ្រព្យសកម្មហិរញ្ញវត្ថុ

*ទ្រព្យសកម្មហិរញ្ញវត្ថុតាមថ្លៃដើមបានរំលស់*

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើទ្រព្យសកម្មនោះមានលក្ខណៈដូចខាងក្រោម (និងមិនត្រូវបានកំណត់ជា FVTPL)៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានរក្សាក្រោមគំរូអាជីវកម្មក្នុងគោលបំណងគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុនិងប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុធ្វើឱ្យមានការកើនឡើងនូវលំហូរសាច់ប្រាក់ដែលទាក់ទងនឹងការទូទាត់សងលើប្រាក់ដើម និងការប្រាក់សុទ្ធ

បន្ទាប់ពីការកត់ត្រាដំបូង ឧបករណ៍ទាំងនោះត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ គណៈគ្រប់គ្រងមិនធ្វើអប្បហារតម្លៃឡើយ ប្រសិនបើវិធីសាស្ត្រនេះមិនផ្តល់លទ្ធផលជាសារវន្ត។ សាច់ប្រាក់ និងសមតុល្យធនាគារ គណនីត្រូវទទួលផ្សេងៗ សមតុល្យត្រូវទទួលពីក្រុមហ៊ុនមេរបស់ក្រុមហ៊ុន ដែលស្ថិតក្នុងចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុនេះ។

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវវាស់វែងតាមថ្លៃដើមរំលស់ រួមមានសាច់ប្រាក់ និងសាច់ប្រាក់សមមូល គណនីពាណិជ្ជកម្មដែលត្រូវទទួល គណនីសន្សំមានកាលកំណត់ និងទ្រព្យសកម្មរយៈពេលវែងផ្សេងៗ។

គណនីពាណិជ្ជកម្មដែលត្រូវទទួលគឺ មិនទទួលបានការប្រាក់ ហើយជាទូទៅត្រូវទូទាត់ក្នុងកំឡុងពេលមួយខែ បន្ទាប់ពីចេញវិក័យបត្រចុងខែ រហូតដល់គម្រោងត្រូវបានបញ្ចប់។

*ទ្រព្យសកម្មហិរញ្ញវត្ថុនៃតម្លៃទីផ្សារសមស្របតាមរយៈចំណេញ ឬខាត (FVTPL)*

ទ្រព្យសកម្មហិរញ្ញវត្ថុដែលប្រើប្រាស់អាជីវកម្មក្រៅពី "កាន់កាប់សម្រាប់ការប្រមូល" ឬ "កាន់កាប់សម្រាប់ការប្រមូលនិងលក់" និងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលលំហូរសាច់ប្រាក់តាមកិច្ចសន្យាមិនមែនជាការទូទាត់តែមួយគត់នៃប្រាក់ដើម និងការប្រាក់ គឺត្រូវបានគណនាតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត។ ពុំមានឧបករណ៍ហិរញ្ញវត្ថុណាមួយរបស់ក្រុមហ៊ុនស្ថិតក្នុងប្រភេទនេះទេ។

*ទ្រព្យសកម្មហិរញ្ញវត្ថុនៃតម្លៃទីផ្សារសមស្របតាមរយៈចំណូលលម្អិតផ្សេងៗ (FVOCI)*

គណនេយ្យក្រុមហ៊ុនសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុទៅតាម FVOCI ប្រសិនបើទ្រព្យសកម្មនោះ ស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- ទ្រព្យសកម្មនោះត្រូវបានកាន់កាប់នៅក្នុងគំរូអាជីវកម្មក្នុងគោលបំណងប្រមូលលំហូរសាច់ប្រាក់ដែលពាក់ព័ន្ធនឹងលក់
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់ការកើនឡើងនូវលំហូរសាច់ប្រាក់ ចំពោះតែការទូទាត់សងនៃប្រាក់ដើម និងការប្រាក់ទៅលើចំនួនដើមដែលនៅសល់។

ចំណេញ ឬខាតបង់ដែលទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងៗ នឹងត្រូវបានកែសម្រួលឡើងវិញនៅពេលមានការឈប់ទទួលស្គាល់ទ្រព្យសកម្ម។ ពុំមានឧបករណ៍ហិរញ្ញវត្ថុណាមួយរបស់ក្រុមហ៊ុន ស្ថិតក្នុងប្រភេទនេះទេ។

**ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ**

ស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិ ៩ ឱនភាព តម្រូវអោយប្រើប្រាស់ព័ត៌មាននៅពេលខាងមុខ ដើម្បីទទួលស្គាល់ការខាតបង់ឥណទានដែលបានរំពឹងទុក "ការខាតបង់ឥណទានដែលរំពឹងទុក" (ECL)។ ក្រុមហ៊ុនពិចារណាលើព័ត៌មានទូលំទូលាយ នៅពេលវាយតម្លៃហានិភ័យឥណទាន និងការខាតបង់ឥណទានដែលរំពឹងទុករួមទាំងព្រឹត្តិការណ៍ពីមុន បច្ចុប្បន្ន និងការព្យាករណ៍ដ៏សមហេតុផល និងអាចជឿជាក់បាន ដែលប៉ះពាល់ដល់លទ្ធភាពនៃការប្រមូលនៃលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុទាំងនោះ។

ដើម្បីអនុវត្តវិធីសាស្ត្រនេះ ការវែកញែកត្រូវបានធ្វើឡើងរវាង៖

- ឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានធ្លាក់ចុះយ៉ាងខ្លាំងនូវគុណភាពឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង ឬដែលមាន ហានិភ័យឥណទានទាប (ដំណាក់កាលទី១)
- ឧបករណ៍ហិរញ្ញវត្ថុដែលបានធ្លាក់ចុះយ៉ាងខ្លាំងនូវគុណភាពឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង និងពុំមានហានិភ័យឥណទានទាប (ដំណាក់កាលទី២)

ដំណាក់កាលទី៣ គ្របដណ្តប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានភស្តុតាងជាក់ស្តែងនៃឱនភាពនាកាលបរិច្ឆេទនៃ របាយការណ៍។ ទោះបីជាយ៉ាងណា ពុំមានទ្រព្យសកម្មហិរញ្ញវត្ថុរបស់ធនាគារណាមួយ ស្ថិតក្នុងប្រភេទនេះទេ។

ឥណទានខាតបង់ដែលរំពឹងទុកសម្រាប់រយៈពេល១២ខែ ត្រូវបានគេទទួលស្គាល់សម្រាប់ប្រភេទទី១ ដែល "ឥណទានខាតបង់ដែលរំពឹងទុកសម្រាប់មួយវដ្ដជីវិត" ត្រូវបានទទួលស្គាល់សម្រាប់ប្រភេទទី២។

ការវាស់វែងលើការខាតបង់ឥណទានដែលរំពឹងទុក ត្រូវបានកំណត់ដោយការប៉ាន់ប្រមាណផលចំណេញសមស្រប នៃការខាតបង់ឥណទានលើវដ្ដជីវិតនៃឧបករណ៍ហិរញ្ញវត្ថុដែលរំពឹងទុក។

### គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ និងទ្រព្យសកម្មកិច្ចសន្យា

ក្រុមហ៊ុនប្រើប្រាស់វិធីសាស្ត្រគណនេយ្យសាមញ្ញសម្រាប់គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ក៏ដូចជាទ្រព្យសកម្មកិច្ចសន្យា និងធ្វើការកត់ត្រាការខាតបង់នៃប្រាក់ឧបត្ថម ជាការខាតបង់ឥណទានដែលបានរំពឹងទុក។ ទាំងនេះគឺជាការខាតបង់ដែលរំពឹងទុកនៅក្នុងលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដោយពិចារណាលើសក្ដានុពលនៃការខ្វះខាតនៅចំណុចណាមួយក្នុងកំឡុងពេលនៃឧបករណ៍ហិរញ្ញវត្ថុ។ ក្រុមហ៊ុនប្រើបទពិសោធន៍ប្រវត្តិសាស្ត្រសូចនាករខាងក្រៅ និងព័ត៌មានឆ្ពោះទៅមុខដើម្បីគណនាការខាតបង់ឥណទានដែលរំពឹងទុកដោយប្រើអត្រាខាតបង់ជាប្រវត្តិសាស្ត្រ។

### ការចាត់ថ្នាក់ និងការវាស់វែងនៃបំណុលហិរញ្ញវត្ថុ

គណនីសម្រាប់បំណុលហិរញ្ញវត្ថុ គឺនៅដដែលបើប្រៀបធៀប ស.រ.ទ.ហ.អ.ក ៩ ទៅនឹង CIAS ៣៩ បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺមិនត្រូវទទួលរងឥទ្ធិពលពីការអនុម័តនៃ ស.រ.ទ.ហ.អ.ក ៩។ ទោះជាយ៉ាងណា ភាពពេញលេញ នៃគោលនយោបាយគណនេយ្យត្រូវបានបង្ហាញដូចខាងក្រោម។

បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមបញ្ចូលទាំងប្រាក់កម្ចី សមតុល្យជំពាក់ភាគីពាក់ព័ន្ធ និងគណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងទៀត។

បំណុលហិរញ្ញវត្ថុត្រូវបានវាស់ដំបូងតាមរយៈតម្លៃសមរម្យ ហើយនៅពេលដែលអាចអនុវត្តបានត្រូវបានកែតំរូវសម្រាប់ថ្លៃដើមប្រតិបត្តិការលើកលែងតែក្រុមហ៊ុនបានកំណត់នូវ បំណុលហិរញ្ញវត្ថុក្នុងតម្លៃសមរម្យតាមរយៈប្រាក់ចំណេញ ឬខាត។

បន្ទាប់មកទៀត បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងនៅចំណាយរំលស់បង្គរ ប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពលើកលែងតែឧបករណ៍ហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលត្រូវបានកំណត់ FVTPL ដែលត្រូវបានអនុវត្តជាបន្តបន្ទាប់ដោយតម្លៃសមរម្យជាមួយនឹងប្រាក់ចំណេញ ឬការខាតបង់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការន៍ចំណូលលម្អិត (ក្រៅពីឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានកំណត់ និងមានប្រសិទ្ធភាពដូចជាឧបករណ៍ការពារហានិភ័យ)។

រាល់ការគិតថ្លៃទាក់ទងនឹងការប្រាក់ហើយប្រសិនបើអាចទៅរួច ការផ្លាស់ប្ដូរតម្លៃឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ចំណូលលម្អិត ត្រូវបានរាប់បញ្ចូលទាំងថ្លៃដើមហិរញ្ញវត្ថុ ឬប្រាក់ចំណូលហិរញ្ញវត្ថុ។

### ៤.៤. សាច់ប្រាក់ និងសមតុល្យនៅក្នុងធនាគារ

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យនៅក្នុងធនាគារផ្សេងៗ ដែលបំលែងជាសាច់ប្រាក់ឆាប់រហ័ស នឹងរួចរាល់ក្នុងការផ្លាស់ប្ដូរទៅជាចំនួនទឹកប្រាក់ជាក់លាក់ណាមួយ ដែល ងាយប្រឈមនឹងហានិភ័យនៃការផ្លាស់ប្ដូរតម្លៃ។

### ៤.៥. មូលធន ទុនបម្រុង និងប្រាក់ចំណេញរក្សាទុក

ដើមទុនតំណាងឱ្យតម្លៃចារឹកនៃតម្លៃដើមរបស់ភាគហ៊ុនដែលបានចេញផ្សាយ។ ប្រាក់ចំណេញរក្សាទុករួមមាន ប្រាក់ចំណេញ ឬខាតនាពេលបច្ចុប្បន្ន និងការិយបរិច្ឆេទឆ្នាំចាស់។

### ៤.៦. សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានកាតព្វកិច្ចស្របច្បាប់ ឬប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងមក ដែលវាទំនងជាមានលំហូរចេញនៃប្រភពសេដ្ឋកិច្ចរបស់ក្រុមហ៊ុន និងសមតុល្យទឹកប្រាក់ដែលអាចប៉ាន់ស្មានបានជាក់ស្តែង។ ការកំណត់លំហូរចេញនៃពេលវេលា ឬសមតុល្យទឹកប្រាក់ នៅតែអាចមានភាពមិនច្បាស់លាស់។ កាតព្វកិច្ចបច្ចុប្បន្នកើតឡើងតាំងពីវត្តមាននៃការសន្យាផ្លូវច្បាប់ ឬការទាមទារផ្សេងទៀតដែលកើតចេញពីព្រឹត្តិការណ៍កន្លងមក ឧទាហរណ៍ការធានារ៉ាប់រងផលិតផល ច្បាប់ដោះស្រាយជម្លោះ ឬកាតព្វកិច្ចពាក់ព័ន្ធនឹងកិច្ចសន្យាដែលអស់ថ្លៃដើមច្រើន។

សំវិធានធន ត្រូវបានវាស់វែងដោយការប៉ាន់ស្មានលើការចំណាយដែលចាំបាច់ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ដោយយោងទៅតាមភស្តុតាងដែលអាចជឿទុកចិត្តបាន នៅចុងការិយបរិច្ឆេទនៃរបាយការណ៍រួមទាំង ហានិភ័យ និងភាពមិនជាក់លាក់ ដែលទាក់ទងទៅនឹងកាតព្វកិច្ចបច្ចុប្បន្ន។ នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នា ដែលអាចនឹងតម្រូវឱ្យមានលំហូរចេញនៃសាច់ប្រាក់ ដើម្បីបំពេញនូវកាតព្វកិច្ច ត្រូវបានកំណត់ដោយ ការពិចារណាទៅលើចំណាត់ថ្នាក់នីមួយៗ នៃកាតព្វកិច្ចនោះជារួម។ សំវិធានធន ត្រូវធ្វើអប្បហារមកជាតម្លៃបច្ចុប្បន្ន ប្រសិនបើតម្លៃនោះមានភាពជាសារវន្ត។

សំណងណាមួយដែលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនជឿជាក់ថានឹងអាចមានសិទ្ធិប្រមូលបានពីតតិយជន នឹងត្រូវបានគេទទួលស្គាល់ជាទ្រព្យសម្បត្តិដាច់ដោយឡែកមួយ។ ទោះជាយ៉ាងណា ទ្រព្យសម្បត្តិនេះមិនអាចលើសពីសមតុល្យដែលពាក់ព័ន្ធទៅនឹងសំវិធានធននោះទេ។ រាល់សំវិធានធនត្រូវបានពិនិត្យឡើងវិញនៅរាល់ចុងការិយបរិច្ឆេទរបាយការណ៍ និងបានកែសម្រួលដើម្បីសមស្របនឹងការប៉ាន់ស្មានថ្មីដែលល្អបំផុត។

ក្នុងករណីទាំងនោះ ពេលដែលមានភាពអាចទៅរួចនៃលំហូរចេញធនធានសេដ្ឋកិច្ច ដែលជាលទ្ធផលនៃកាតព្វកិច្ចបច្ចុប្បន្ន គឺត្រូវបានចាត់ទុកថាមិនទំនង ឬខុសគ្នាខ្លាំង ដូច្នេះពុំមានបំណុលត្រូវបានទទួលស្គាល់។

លំហូរចូលដែលអាចកើតមាននៃអត្ថប្រយោជន៍សេដ្ឋកិច្ចទៅកាន់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន ដែលមិនគ្រប់លក្ខខណ្ឌក្នុងការទទួលស្គាល់ទ្រព្យសកម្ម ត្រូវចាត់ទុកជាទ្រព្យសកម្មយថាហេតុ។

### ៤.៧. ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ គឺត្រូវបានកាត់កង ហើយចំនួនទឹកប្រាក់សុទ្ធដែលបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេល និងត្រឹមពេលដែលមានសិទ្ធិក្នុងការអនុវត្តស្របច្បាប់ក្នុងការបង្កើត និងចេតនាក្នុងការដោះបំណុលលើមូលដ្ឋានសុទ្ធ ឬដើម្បីដោះទ្រព្យសម្បត្តិពីការបញ្ចាំ និងទូទាត់បមនុលក្នុងពេលតែមួយ។ ចំណូល និងចំណាយ គឺត្រូវបានបង្ហាញតាមមូលដ្ឋានសុទ្ធ លុះត្រាតែមានការអនុញ្ញាត្តិតាម ស.រ.ទ.ហ.អ.ក ឬសម្រាប់ចំណេញ ឬខាតដែលកើតឡើងពីប្រតិបត្តិការស្រដៀងគ្នា។

### ៤.៨. ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើមដោយដកចេញរំលស់បង្គរ និងការខាតបង់លើឱនភាពតម្លៃនៃទ្រព្យសម្បត្តិប្រសិនបើមាន។ នៅពេលដែលទ្រព្យសម្បត្តិ និងបរិក្ខារមានសមាសធាតុសំខាន់ៗ មានអាយុកាល មានប្រយោជន៍ផ្សេងៗ សមាសធាតុត្រូវបានចាត់ទុកថាជារបស់ដាច់ដោយឡែកពីគ្នានៃទ្រព្យសម្បត្តិ និងបរិក្ខារ។

ការចំណាយបន្តបន្ទាប់ ត្រូវរួមបញ្ចូលទៅក្នុងតម្លៃយោងរបស់ទ្រព្យសកម្មទាំងនោះ ឬទទួលស្គាល់ជាទ្រព្យសកម្មមួយផ្សេងទៀត នៅពេលដែលទ្រព្យសកម្មនោះមានអត្ថប្រយោជន៍សេដ្ឋកិច្ចដែលអាចជឿទុកចិត្តបាន នាពេលអនាគតដល់ក្រុមហ៊ុន ហើយតម្លៃនោះអាចវាស់វែងបានត្រឹមត្រូវ។ តម្លៃយោងរបស់ផ្នែកណាមួយនៃទ្រព្យសកម្មដែលបានផ្លាស់ប្តូរ នឹងត្រូវបានលុបចេញពីបញ្ជី។ តម្លៃសេវាកម្មប្រចាំថ្ងៃរបស់ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលលម្អិត នៅពេលដែលចំណាយបានកើតឡើង។ ថ្លៃដើមក៏ត្រូវរួមបញ្ចូលទាំងតម្លៃបឋមទៅលើការរុះរើ ការផ្លាស់ទីតាំងទ្រព្យសកម្ម និងការរៀបចំទីតាំងឡើងវិញ ដែលអាចនឹងកើតមានឡើងនាពេលអនាគត នៅពេលទិញទ្រព្យសកម្មទាំងនោះប្រសិនបើចាំបាច់។

រំលស់ត្រូវបានគណនាដោយធ្វើការលុបចោលនូវថ្លៃដើមនៃសមាសធាតុនៃទ្រព្យសម្បត្តិ និងបរិក្ខារ ដែលមានតម្លៃសំណល់ និងរំលស់ផ្អែកលើការរំលស់ថេរលើអាយុកាលរបស់ទ្រព្យសម្បត្តិដែលមានដូចខាងក្រោម៖

ដោយសារមិនមានការកំណត់អាយុកាលប្រើប្រាស់លើដីដែលត្រូវបានកំណត់ សមតុល្យយោងដែលទាក់ទងមិនត្រូវបានធ្វើរំលស់ឡើយ៖

| | **អាយុកាលប្រើប្រាស់** |
|---|---|
| គ្រឿងម៉ាស៊ីន | ២ឆ្នាំ ទៅ ៥ឆ្នាំ |
| រថយន្ត | ៣ឆ្នាំ ទៅ ៥ឆ្នាំ |
| បរិក្ខារការិយាល័យ | ២ឆ្នាំ ទៅ ៤ឆ្នាំ |
| គ្រឿងសង្ហារឹម | ២ឆ្នាំ ទៅ ៣ឆ្នាំ |
| ការកែលម្អដី | ២ឆ្នាំ ទៅ ៣ឆ្នាំ |
| សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម | ១០ឆ្នាំ |

នាចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ តម្លៃយោងនៃទ្រព្យសម្បត្តិ និងឧបករណ៍បរិក្ខារត្រូវបានវាយតម្លៃសម្រាប់ឱនភាពនៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈ បង្ហាញថាតម្លៃយោងរបស់វាមិនអាចប្រមូលមកវិញបាន។ បញ្ជីកាថយចុះត្រូវបានធ្វើឡើងប្រសិនបើតម្លៃយោងលើសពីចំនួនដែលអាចប្រមូលបាន។

ទ្រព្យសកម្មដែលកំពុងសាងសង់ត្រូវបានវាស់វែងតាមថ្លៃដើម។ នេះរួមបញ្ចូលទាំងការចំណាយលើការសាងសង់ទ្រព្យសម្បត្តិ និងបរិក្ខារ ការចំណាយប្រាក់កម្ចីត្រូវបានបង្កឡើងដោយផ្ទាល់ចំពោះទ្រព្យសម្បត្តិបែបនេះក្នុងកំឡុងពេលសាងសង់ និងការគិតថ្លៃដើមផ្សេងទៀត។ ទ្រព្យសកម្មដែលកំពុងសាងសង់មិនត្រូវបានធ្វើរំលស់ទេរហូតដល់ពេលដែលទ្រព្យសកម្មពាក់ព័ន្ធត្រូវបានបញ្ចប់ និងរួចរាល់សម្រាប់ការប្រើប្រាស់ក្នុងប្រតិបត្តិការ។

ចំណេញ ឬខាតដែលកើតឡើងពីការដល់អាយុកាលនៃការប្រើប្រាស់ ឬតម្លៃជំរះបញ្ជីទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកំណត់ថាជាភាពខុសគ្នារវាងតម្លៃជំរះបញ្ជីសុទ្ធ នឹងតម្លៃយោងនៃទ្រព្យសកម្ម និងត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតនៅកាលបរិច្ឆេទនៃអាយុកាលនៃទ្រព្យសកម្ម ឬកាលបរិច្ឆេទនៃការជំរះបញ្ជីនៃទ្រព្យសកម្មនោះ។

ការរំលស់ពេញលេញនៃទ្រព្យសម្បត្តិ និងបរិក្ខារដែលបានវាយតម្លៃទាបត្រូវបានរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតទាល់តែវាត្រូវបានគេបោះចោល ឬលុបចោល។

តម្លៃសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់ត្រូវបានពិនិត្យឡើងវិញនៅការីយបរិច្ឆេទហិរញ្ញវត្ថុនីមួយៗ ដើម្បីធានាថាចំនួនទឹកប្រាក់វិធីសាស្ត្រ និងរយៈពេលនៃការរំលស់ គឺស្របទៅនឹងការប៉ាន់ស្មានពីមុន និងគំរូនៃការប្រើប្រាស់ផលប្រយោជន៍ផ្អែកសេដ្ឋកិច្ចនាពេលអនាគតដែលបានបញ្ចូលនៅក្នុងទ្រព្យសម្បត្តិ និងបរិក្ខារ។ ប្រសិនបើការរំពឹងទុកខុសគ្នាពីការប៉ាន់ស្មានពីមុនការផ្លាស់ប្តូរត្រូវបានរាប់បញ្ចូលដូចជាការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ។

តម្លៃយោងនៃទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានទទួលស្គាល់ដោយការជំរះបញ្ជី ឬនៅពេលដែលគ្មានការរំពឹងថានឹងទទួលបានផលប្រយោជន៍ផ្អែកសេដ្ឋកិច្ចពីការប្រើប្រាស់ ឬការជំរះបញ្ជី។ ភាពខុសគ្នារវាងប្រាក់ចំណេញសុទ្ធនៃជំរះទ្រព្យសម្បត្តិប្រសិនបើមាន និងតម្លៃយោងត្រូវបានរាប់បញ្ចូលទាំងចំណេញ ឬខាត។

### ៤.៩. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលតំណាងឱ្យកម្មវិធីកុំព្យូទ័រ ដែលត្រូវបានកត់ត្រាតាមវិធីសាស្ត្រថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើតម្លៃឱនភាព។ ថ្លៃដើមរួមបញ្ចូលទាំងការចំណាយផ្សេងៗ ដែលបានពាក់ព័ន្ធដោយផ្ទាល់ទៅនឹង កម្មវិធីកុំព្យូទ័រ ដើម្បីធ្វើអោយកម្មវិធីកុំព្យូទ័រប្រើប្រាស់បាន។ កម្មវិធីកុំព្យូទ័រ មិនត្រូវបានរំលស់មុនពេលវារួចរាល់សម្រាប់ការប្រើប្រាស់នោះទេ។

### ៤.១០. ការធ្វើតេស្តឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ដើម្បីធ្វើការវាយតម្លៃលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានចាត់ជាក្រុមក្នុងកម្រិតទាបបំផុត ដែលមានលំហូរសាច់ប្រាក់ឯករាជ្យមួយផ្នែកធំ (ឯកតាបង្កើតសាច់ប្រាក់)។ ជាលទ្ធផលទ្រព្យសកម្មមួយចំនួនត្រូវបានវាយតម្លៃលើឱនភាពនៃតម្លៃដាច់ដោយឡែក និងមួយចំនួនទៀតវាយតម្លៃជាកម្រិតឯកត្តាបង្កើតសាច់ប្រាក់។ ការខាតបង់លើឱនភាពនៃតម្លៃ នឹងត្រូវបានទទួលស្គាល់នូវចំនួនដែលលើសរវាងទ្រព្យសកម្ម ឬតម្លៃយោងនៃឯកតាបង្កើត សាច់ប្រាក់ និងចំនួនដែលអាចស្រង់មកវិញបាន ហើយតម្លៃដែលអាចស្រង់មកវិញ គឺជាតម្លៃមួយណាដែលខ្ពស់ជាង រវាងតម្លៃទីផ្សារសមស្រប ដកការចំណាយដែលពាក់ព័ន្ធក្នុងការលក់ និងតម្លៃនាអំឡុងពេលប្រើប្រាស់។

ដើម្បីកំណត់តម្លៃប្រើប្រាស់គណៈគ្រប់គ្រងត្រូវធ្វើការប៉ាន់ប្រមាណតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគត នៃក្រុមនីមួយៗ ដោយកំណត់អត្រាការប្រាក់ដ៏សមរម្យ ដើម្បីគណនាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ទាំងនោះ។ ទិន្នន័យប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃលើឱនភាពនៃតម្លៃ មានការទាក់ទងដោយផ្ទាល់ទៅនឹងគម្រោងផែនការរបស់ក្រុមហ៊ុន និងដែលបានអនុម័ត និងធ្វើនិយ័តកម្មប្រសិនបើចាំបាច់ដើម្បីដកផលប៉ះពាល់ពីការរៀបចំ និងធ្វើឱ្យប្រសើរឡើងវិញនៃទ្រព្យសកម្មនោះនាពេលអនាគត។ អត្រាអប្បហារត្រូវបានកំណត់ឡើងសម្រាប់ក្រុមទ្រព្យសកម្មនីមួយៗ ដើម្បីឆ្លុះបញ្ចាំងពីប្រវត្តិសង្ខេបនៃហានិភ័យរបស់ទ្រព្យសកម្មនីមួយៗ ដូចដែលបានវាយតម្លៃដោយគណៈគ្រប់គ្រង។

### ៤.១១. ភតិសន្យាជួល

*ក្រុមហ៊ុនក្នុងនាមជាភាគីអ្នកជួល*

ភតិសន្យាជួល គឺត្រូវបានស្គាល់ថាជា "កិច្ចសន្យា ឬជាផ្នែកមួយនៃកិច្ចសន្យា ដែលឆ្លុះបញ្ចាំងអំពីសិទ្ធិលើការប្រើប្រាស់នៃទ្រព្យសកម្មមួយ (ទ្រព្យសកម្មមូលដ្ឋាន) សម្រាប់ការិយបរិច្ឆេទនៃរយៈពេលជាថ្នូរក្នុងការពិចារណា។

ដើម្បីអនុវត្តនិយមន័យនេះ ក្រុមហ៊ុនត្រូវធ្វើការវាយតម្លៃថាតើ កិច្ចសន្យាឆ្លើយតបនឹងការវាយតម្លៃសំខាន់ៗ ចំនួនបីដែលមានដូចជា៖

i) កិច្ចសន្យាមានធាតុនៃទ្រព្យសកម្ម នឹងត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចសន្យា ឬបញ្ជាក់ដោយប្រយោលដែលទ្រព្យសកម្មនោះត្រូវបានផ្ដល់ជូនក្រុមហ៊ុនសម្រាប់ប្រើប្រាស់។

ii) ក្រុមហ៊ុនមានសិទ្ធិទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើនពីការប្រើប្រាស់ទ្រព្យសកម្មដែលបានកំណត់ ក្នុងអំឡុងពេលប្រើប្រាស់ដោយពិចារណាលើសិទ្ធិរបស់ខ្លួនក្នុងវិសាលភាពដែលបានកំណត់នៃកិច្ចសន្យា។

iii) ក្រុមហ៊ុនមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងរយៈពេលនៃការប្រើប្រាស់។ ក្រុមហ៊ុនវាយតម្លៃថាតើក្រុម-ហ៊ុនមានសិទ្ធិ "របៀបណា និងសម្រាប់គោលបំណងអ្វី" ដែលទ្រព្យសម្បត្តិត្រូវបានប្រើប្រាស់ក្នុងរយៈពេលនៃការប្រើប្រាស់។

*ការវាស់វែង និងការទទួលស្គាល់ ភតិសន្យាជួល ក្នុងនាមជាអ្នកជួល*

កាលបរិច្ឆេទនៃការជួលភតិសន្យា ក្រុមហ៊ុនទទួលស្គាល់សិទ្ធិប្រើប្រាស់នៃទ្រព្យសកម្ម និងបំណុលបំណុលភតិសន្យាលើរបាយការណ៍ហិរញ្ញវត្ថុ។ សិទ្ធិប្រើប្រាស់នៃទ្រព្យសកម្ម ត្រូវបានវាស់វែងតាមថ្លៃដើម ដែលត្រូវបានបង្កើតឡើងដោយការវាស់វែងដំបូងនៃបំណុលភតិសន្យាថ្លៃដើមដំបូងណាមួយដែលកើតឡើងដោយក្រុមហ៊ុន ការប៉ាន់ស្មានលើការចំនាយនៃការរុះរើ និងដកហូតទ្រព្យសម្បត្តិនៅចុងបញ្ចប់នៃភតិសន្យាជួល ហើយរាល់ការទូទាត់ទៅលើភតិសន្យាជួលណាមួយដែលបានធ្វើឡើងមុនថ្ងៃចាប់ផ្ដើមនៃការជួល (ប្រាក់លើកទឹកចិត្តដែលទទួលបានសុទ្ធ) ។

ការរំលស់របស់ក្រុមហ៊ុនទៅលើ ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ ត្រូវបានធ្វើឡើងតាមមូលដ្ឋានរំលស់ថេរ គិតចាប់ពីថ្ងៃចាប់ផ្ដើមនៃភតិសន្យាជួលរហូតដល់ពេលបញ្ចប់នៃអាយុកាលនៃការប្រើប្រាស់នៃ សិទ្ធិលើការប្រើប្រាស់ទ្រព្យសកម្ម ឬចុងបញ្ចប់នៃកិច្ចសន្យាជួល។ ក្រុមហ៊ុនក៏ធ្វើការវាយតម្លៃទៅលើឱនភាពនៃទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ នៅពេលដែលមានសូចនាករទាំងនោះកើតមានឡើង។

នាកាលបរិច្ឆេទចាប់ផ្ដើមនៃភតិសន្យាជួល ក្រុមហ៊ុនវាស់វែងលើបំណុលភតិសន្យាទៅតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ថ្លៃជួលដែលមិនបានបង់នៅកាលបរិច្ឆេទនោះ ដោយត្រូវបញ្ចុះតម្លៃដោយប្រើអត្រាការប្រាក់ជាក់ស្ដែងក្នុងការជួលប្រសិន បើអត្រានោះអាចមាន ឬ អត្រាការប្រាក់កម្ចីកើនឡើងរបស់ក្រុមហ៊ុន។

ការទូទាត់ភតិសន្យា ដែលបានរួមបញ្ចូលនៅក្នុងការវាស់វែងនៃបំណុលភតិសន្យា ត្រូវបានធ្វើឡើងដោយការទូទាត់ថេរ (រាប់បញ្ចូលទាំងវត្ថុថេរ) ការទូទាត់អថេរផ្អែកលើសន្ទស្សន៍ ឬអត្រាចំនួនដែលរំពឹងថានឹងត្រូវបង់ក្រោមការធានាតម្លៃនៅសល់ និងការទូទាត់ដែលកើតឡើងពីជំរើសជាក់លាក់ ត្រូវបានអនុវត្ត។

បន្ទាប់ពីការវាស់វែងដំបូង នោះបំណុលភតិសន្យានឹងត្រូវបានកាត់បន្ថយសម្រាប់ការទូទាត់ និងបង្កើនទៅលើការប្រាក់។ វាត្រូវបានវាស់វែងឡើងវិញដើម្បីឆ្លុះបញ្ចាំងពីការវាយតំលៃឡើងវិញ ឬការកែប្រែ ឬប្រសិនបើមានការផ្លាស់ប្តូរការទូទាត់ថេរក្នុងរូបធាតុ។

នៅពេលដែលបំណុលភតិសន្យា ត្រូវបានវាស់វែងសារឡើងវិញ ការកែតម្រូវត្រូវអោយត្រូវគ្នាត្រូវបានឆ្លុះបញ្ចាំងពី ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ ឬចំណេញ និងខាត ប្រសិនបើទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ត្រូវបានកាត់បន្ថយរហូតដល់សូន្យ។

ក្រុមហ៊ុនបានជ្រើសរើសយកគណនីជួលរយៈពេលខ្លី និងការជួលទ្រព្យសម្បត្តិដែលមានតម្លៃទាបដោយប្រើការអនុវត្តន៍ជាក់ស្តែង។ ជំនួសឱ្យទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ និងបំណុលភតិសន្យាជួល ការទូទាត់ទាក់ទងនឹងរបស់ទាំងនេះត្រូវបានទទួលស្គាល់ថាជាការចំណាយ នៅក្នុងរបាយការណ៍ចំណូលលម្អិត តាមមូលដ្ឋានរំលស់ថេរនៃថេរវេលានៃភតិសន្យានោះ។

### ៤.១២. ការទទួលស្គាល់ចំណូល

ប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅពេល ដែលកាតព្វកិច្ចក្នុងកិច្ចសន្យាជាមួយអតិថិជនត្រូវបានបំពេញដោយពេញលេញ គឺនៅពេលដែល " សិទ្ធក្នុងការគ្រប់គ្រង" នៃទំនិញ ឬសេវាកម្មដែលផ្អែកលើការអនុវត្តកាតព្វកិច្ចជាក់លាក់ត្រូវបានផ្ទេរទៅឱ្យអតិថិជន។

កាតព្វកិច្ចនៃកិច្ចសន្យា គឺជាការសន្យាក្នុងការផ្ទេរទំនិញឬសេវាកម្មយ៉ាងជាក់លាក់ណាមួយ (ឬប្រភេទនៃទំនិញ ឬសេវាកម្មដែលមានលក្ខណៈដូចគ្នា និងមានទំរង់នៃការផ្ទេរដូចគ្នា) ដល់អតិថិជនដែលត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចសន្យា និងបញ្ជាក់នៅក្នុង ការអនុវត្តអាជីវកម្មជាទូទៅរបស់ក្រុមហ៊ុន។

ដើម្បីកំណត់ថាតើត្រូវទទួលស្គាល់ប្រាក់ចំណូលក្រុមហ៊ុនអនុវត្តតាមនីតិវិធី ៥ ជំហាន៖

ក. កំណត់កិច្ចសន្យាជាមួយអតិថិជន
ខ. កំណត់កាតព្វកិច្ចដែលត្រូវអនុវត្ត
គ. កំណត់តម្លៃនៃប្រតិបត្តិការ
ឃ. ការបែងចែកតម្លៃនៃប្រតិបត្តិការទៅតាមកាតព្វកិច្ចនៃកិច្ចសន្យា
ង. ការទទួលស្គាល់ប្រាក់ចំណូលក្នុងពេល ឬការបំពេញកាតព្វកិច្ចក្នុងកិច្ចសន្យា

ប្រាក់ចំណូលត្រូវបានវាស់វែងតាមចំនួនទឹកប្រាក់ ដែលក្រុមហ៊ុនរំពឹងថានឹងទទួលបាន ដែលស្មើរនឹងតម្លៃនៃការផ្ទេរទំនិញ ឬសេវាកម្មដែលបានសន្យាជូនអតិថិជន ដោយមិនរាប់បញ្ចូលចំនួនទឹកប្រាក់ដែលប្រមូលបានក្នុងនាមភាគីទីបី ដូចជាពន្ធលើការលក់ ឬពន្ធលើទំនិញ និងសេវាកម្ម។ ប្រសិនបើចំនួនទឹកប្រាក់នឹងទទួលស្គាល់ខុសគ្នា ដោយសារតែការបញ្ចុះតម្លៃ បង្វិលប្រាក់សងវិញ ប្រាក់លើកទឹកចិត្ត ការដាក់ទណ្ឌកម្ម ឬកម្មវត្ថុស្រដៀងគ្នាផ្សេងទៀត ក្រុមហ៊ុននឹងធ្វើការប៉ាន់ស្មានចំនួនទឹកប្រាក់ដែលនឹងទទួលស្គាល់ ដោយផ្អែកលើតម្លៃដែលរំពឹងទុក ឬតំលៃដែលសមរម្យបំផុត។ ប្រសិនបើកិច្ចសន្យាជាមួយអតិថិជនមានកាតព្វកិច្ចអនុវត្តលើសពីមួយទឹកប្រាក់ដែលត្រូវពិចារណាក្នុងការទទួលស្គាល់ជាចំណូល ត្រូវបែងចែកទៅតាមការអនុវត្តនៃកិច្ចសន្យានីមួយៗ។

ការគ្រប់គ្រងទំនិញ ឬសេវាកម្មដែលបានសន្យាអាចត្រូវបានផ្ទេរក្នុងរយៈពេល ឬពេលវេលជាក់លាក់។ ការគ្រប់គ្រងទំនិញ ឬសេវាកម្មត្រូវបានផ្ទេរក្នុងរយៈពេល ហើយប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្នុងរយៈពេលប្រសិនបើ៖

- អតិថិជនទទួលបាននិងប្រើប្រាស់អត្ថប្រយោជន៍ក្នុងពេលដំណាលគ្នាដែលក្រុមហ៊ុនអនុវត្ត
- ក្រុមហ៊ុនបានអនុវត្តកាតពត្វកិច្ចក្នុងកិច្ចសន្យា ទៅលើទ្រព្យសកម្ម របស់អតិថិជន ឬ
- ការអនុវត្តន៍កាតព្វកិច្ចរបស់ក្រុមហ៊ុនមិនបង្កើតទ្រព្យក្នុងគោលបំណងការប្រើប្រាស់ជំនួសទេ ហើយក្រុមហ៊ុនមានសិទ្ធិទទួលបានការទូទាត់សម្រាប់ប្រតិបត្តិការដែលបានបញ្ចប់រហូតមកដល់បច្ចុប្បន្ន។

ប្រាក់ចំណូលសម្រាប់អនុវត្តកាតព្វកិច្ច ដែលមិនពេញចិត្តតាមពេលវេលា ត្រូវបានទទួលស្គាល់នៅពេលដែលអតិថិជនទទួលបានការត្រួតពិនិត្យទំនិញ ឬសេវាកម្មដែលបានសន្យា។

ក្រុមហ៊ុនទទួលស្គាល់ប្រាក់ចំណូលពីសេវាកម្មសាងសង់ តាមពេលវេលាប្រសិនបើវាបង្កើតទ្រព្យសម្បត្តិដែលគ្មានការប្រើប្រាស់ជំនួសក្រុមហ៊ុន ហើយក្រុមហ៊ុនមានសិទ្ធិទទួលបានការទូទាត់ទៅលើសេវាកម្មសាងសង់គិតត្រឹមការសាងសង់ត្រូវបានបញ្ចប់។ ប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្នុងរយៈពេលកិច្ចសន្យា ដោយយោងទៅលើវឌ្ឍនភាពឆ្ពោះទៅរកការពេញចិត្តនៃកាតព្វកិច្ចអនុវត្ត។

វឌ្ឍនភាពឆ្ពោះទៅរកការពេញចិត្ត នៃកាតព្វកិច្ចអនុវត្តត្រូវបានវាស់ដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែង ឬធាតុចូលរបស់ក្រុមហ៊ុនចំពោះការបំពេញកាតព្វកិច្ចនៃកិច្ចសន្យា (ឧទាហរណ៍ ការយោងទៅលើការចំណាយលើការសាងសង់ទ្រព្យសម្បត្តិដែលបានកើតឡើងគិតជាភាគរយនៃការប៉ាន់ស្មានចំណាយសរុប នៃការសាងសង់កិច្ចសន្យា) ។

នៅពេលដែលប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅក្នុង របាយការណ៍ចំណូលលម្អិត លើសពីវិក័យប័ត្រដែលចេញឱ្យដល់អ្នកទិញ សមតុល្យត្រូវបានបង្ហាញជាទ្រព្យសកម្មកិច្ចសន្យា។ នៅពេលដែលវិក័យប័ត្រដែលចេញឱ្យអ្នកទិញ លើសពីប្រាក់ចំណូលដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត សមតុល្យ ត្រូវបានបង្ហាញជាបំណុលកិច្ចសន្យា។

ប្រាក់ចំណូលពីការលក់ទំនិញ ត្រូវបានទទួលស្គាល់នៅពេលដែលទំនិញត្រូវបានប្រគល់ជូនអ្នកទិញរួចរាល់ ហើយសិទ្ធិនៃការគ្រប់គ្រងក៏ត្រូវបានផ្ទេររួចរាល់ដែរ។

***ចំណូលផ្សេងៗ***

ប្រាក់ចំណូលផ្សេងទៀតត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត នាការិយបរិច្ឆេទដែលទទួលបាន។

### ៤.១៣. ការទទួលស្គាល់ចំណាយ

ចំណាយត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលលម្អិត នៅពេលដែលមានការថយចុះនៃអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលទាក់ទងនិងការថយចុះទ្រព្យសកម្ម ឬការកើនឡើងនៃបំណុលដែលបានកើតឡើងដែលអាចត្រូវបានវាស់វែងយ៉ាងត្រឹមត្រូវ។ ចំណាយត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលលម្អិតក្នុងករណី៖

ក. លើមូលដ្ឋានដែលទាក់ទងគ្នាដោយផ្ទាល់រវាងថ្លៃដើមដែលបានកើតឡើង និងចំណូលពីសមាសធាតុគណនីជាក់លាក់នៃគណនីចំណូល

ខ. លើមូលដ្ឋាននីតិវិធីបែងចែកជាប្រព័ន្ធ និងភាពសមស្រប នៅពេលដែលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចត្រូវបានរំពឹងទុកថានឹងកើតមានឡើងក្នុងកាលបរិច្ឆេទគណនេយ្យមួយចំនួន និងទាក់ទងជាមួយចំណូលដែលអាចកំណត់បានយ៉ាងទូលំទូលាយ ឬកំណត់បានដោយប្រយោល ឬ

គ. ទទួលស្គាល់ភ្លាមៗនៅពេលដែលចំណាយ មិនបង្កើតឱ្យមាននូវអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ឬនៅពេលណា ហើយក្នុងកម្រិតដែលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬលែងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលស្គាល់ជាទ្រព្យសកម្មនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ចំណាយក្នុងរបាយការណ៍ចំណូលលម្អិត ត្រូវបានបង្ហាញដោយប្រើប្រាស់វិធីសាស្ត្រមុខងារចំណាយ។ ថ្លៃដើមទំនិញ និងសេវាកម្មតំណាងឱ្យចំណាយកម្លាំងពលកម្មផ្ទាល់ សន្និធិ និងចំណាយបន្ទាប់បន្សំផ្សេងៗទៀតដែលទាក់ទងដោយផ្ទាល់ក្នុងការស្វែងរកប្រាក់ចំណូល។ ចំណាយប្រតិបត្តិការ គឺជាចំណាយដែលទាក់ទងនឹងចំណាយទូទៅ ចំណាយរដ្ឋបាល និងសកម្មភាពភាពអាជីវកម្មផ្សេងៗទៀតរបស់ ក្រុមហ៊ុន។

### ៤.១៤. ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតដែលរួមបញ្ចូលទាំងផលបូកនៃពន្ធពន្យារ ហើយពន្ធបច្ចុប្បន្នមិនត្រូវបានទទួលស្គាល់ក្នុងគណនីចំណូលលម្អិតផ្សេងៗ ឬទទួលស្គាល់ដោយផ្ទាល់ក្នុងគណនីមូលធន។

ពន្ធប្រាក់ចំណូលលើទ្រព្យសកម្ម និង/ឬបំណុល រួមមានកាតព្វកិច្ច ឬការទាមទារពីអាជ្ញាធរសារពើពន្ធដែលទាក់ទងនឹងចុងការិយបរិច្ឆេទនៃរបាយការណ៍បច្ចុប្បន្ន ឬពីពេលកន្លងមក ដែលមិនបានទូទាត់នាការិយបរិច្ឆេទនៃរបាយការណ៍នោះ។ ពន្ធបច្ចុប្បន្ន គឺបំណុលលើប្រាក់ចំណេញជាប់ពន្ធ ដែលខុសពីប្រាក់ចំណេញ ឬខាតក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការគណនាពន្ធបច្ចុប្បន្ន គឺផ្អែកលើអត្រាពន្ធ និងច្បាប់ពន្ធដែលត្រូវបានអនុម័ត ឬត្រូវបានអនុម័តនៅពេលបន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍។

ពន្ធលើប្រាក់ចំណូលពន្យារ ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្រ្តសមតុល្យបំណុល លើភាពខុសគ្នាជាបណ្តោះអាសន្នរវាងសមតុល្យយោងរបស់ទ្រព្យសកម្ម និងបំណុល ព្រមទាំងមូលដ្ឋានពន្ធរបស់វា។

ពន្ធពន្យារលើទ្រព្យសកម្ម និងបំណុលត្រូវបានគណនាដោយមិនគិតអប្បហារ នៅអត្រាពន្ធដែលរំពឹងថានឹងអនុវត្តទៅតាម រយៈពេលនៃការទទួលស្គាល់របស់ពួកគេ ដោយសារអត្រាពន្ធទាំងនោះត្រូវបានអនុម័ត ឬអនុម័តនៅពេលបន្ទាប់នៅចុងការិយបរិច្ឆេទនៃរបាយការណ៍។

ពន្ធពន្យារលើទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ដើម្បីពង្រីកវិសាលភាពដែលប្រហែលជា មានការខាតបង់ ឬភាពខុសគ្នាបណ្តោះអាសន្នដែលកាត់កងបាន នឹងអាចប្រើប្រាស់បានដើម្បីកាត់កងនឹងប្រាក់ចំណូលជាប់ពន្ធនាពេលអនាគត។ ការវាយតម្លៃនេះ គឺផ្អែកលើការព្យាករណ៍របស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនទៅលើលទ្ធផលប្រតិបត្តិការនាពេលអនាគត ដែលត្រូវបានកែតម្រូវសម្រាប់ប្រាក់ចំណូល និងការចំណាយដែលមិនជាប់ពន្ធ និងការកំណត់ជាក់លាក់លើការប្រើប្រាស់ពន្ធខាតដែលមិនបានប្រើណាមួយ និងពន្ធត្រូវបង់។ ពន្ធពន្យារលើបំណុល តែងតែត្រូវបានទទួលស្គាល់ទាំងអស់។

ពន្ធពន្យារលើទ្រព្យសកម្ម និងបំណុលអាចកាត់កង បានតែនៅពេលសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមានសិទ្ធិ និងគោលបំណងក្នុងការទូទាត់ពន្ធបច្ចុប្បន្នលើទ្រព្យសកម្ម និងបំណុលពីអាជ្ញាធរពន្ធដារតែមួយ។

ការផ្លាស់ប្តូរពន្ធពន្យារលើទ្រព្យសកម្ម និងបំណុលត្រូវបានទទួលស្គាល់ជាផ្នែកនៃពន្ធលើប្រាក់ចំណូល ឬចំណាយនៅក្នុងរបាយការណ៍ចំណូលលម្អិត លើកលែងតែនៅពេលដែលពន្ធទាំងនោះ មានការទាក់ទងនឹងផ្នែកទាំងអស់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត (ដូចជាការវាយតម្លៃដី) ឬមូលធនក្នុងករណីណាមួយ ពេលពន្ធពន្យារដែលទាក់ទង ក៏ត្រូវទទួលស្គាល់នៅក្នុងគណនីចំណូលលម្អិតផ្សេងទៀត ឬគណនីមូលធន។

## ៤.១៥. ភាគីពាក់ព័ន្ធ

ភាគីពាក់ព័ន្ធ គឺជាបុគ្គល ឬអង្គភាពដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុន។ ប្រតិបត្តិការភាគីពាក់ព័ន្ធ គឺជាការផ្ទេរធនធាន សេវាកម្ម ឬកាតព្វកិច្ចរវាងក្រុមហ៊ុន និងភាគីពាក់ព័ន្ធរបស់ខ្លួនទោះបីជាបានគិតថ្លៃ ឬមិនបានគិតថ្លៃ។ បន្ថែមពីនេះទៀត៖

ក. បុគ្គល ឬមនុស្សដែលជិតស្និទ្ធិជាមួយបុគ្គលនៃគ្រួសារនោះ គឺមានការពាក់ព័ន្ធជាមួយក្រុមហ៊ុនប្រសិនបើបុគ្គលនោះ
   i. មានសិទ្ធិគ្រប់គ្រង ឬចូលរួមក្នុងការគ្រប់គ្រងលើក្រុមហ៊ុន
   ii. មានឥទ្ធិពលខ្លាំងលើក្រុមហ៊ុន ឬ
   iii. គឺជាសមាជិកនៃគណៈគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុនផ្ទាល់ឬ ជាសមាជិកនៃគណៈគ្រប់គ្រងរបស់ក្រុមហ៊ុនមេ។

ខ. អង្គភាពដែលចាត់ចូលជាភាគីពាក់ព័ន្ធ របស់ក្រុមហ៊ុន លុះត្រាតែអង្គភាពនោះមានលក្ខណៈដូចខាងក្រោម៖
   i. អង្គភាព និងក្រុមហ៊ុនគឺជាសមាជិកនៃសម្ព័ន្ធក្រុមហ៊ុនតែមួយ
   ii. អង្គភាពមួយដែលបានចូលរួម ឬការបណ្តាក់ទុនរួមគ្នារបស់អង្គភាពផ្សេងៗទៀត។
   iii. អង្គភាពទាំងពីរ គឺជាការបណ្តាក់ទុនរួមគ្នានៃភាគីទីបីដូចគ្នា។
   iv. អង្គភាពមួយ គឺជាការបណ្តាក់ទុនរួមគ្នានៃភាគីទីបី ហើយអង្គភាពផ្សេងទៀតគឺជាសហការីនៃអង្គភាពទីបី។
   v. អង្គភាព គឺជាផែនការទទួលបានអត្ថប្រយោជន៏ការងារ សម្រាប់អត្ថប្រយោជន៏របស់នយោជិករបស់ក្រុមហ៊ុន។
   vi. អង្គភាពត្រូវបានគ្រប់គ្រង ឬការរួមគ្នាគ្រប់គ្រងដោយមនុស្សម្នាក់ដែលបានកំណត់នៅក្នុងចំណុច ក. ខាងលើ។

vii. បុគ្គលមួយដែលបានកំណត់ខាងលើ ក.i ដែលមានឥទ្ធិពលគួរអោយកត់សម្គាល់លើអង្គភាព ឬជាសមាជិកនៃ បុគ្គលគ្រប់គ្រងសំខាន់នៃក្រុមហ៊ុនកាន់កាប់ចុងក្រោយ ឬអង្គភាព។
viii. អង្គភាព ឬសមាជិកណាមួយនៃសម្ព័ន្ធដែលជាផ្នែកមួយ ផ្តល់សេវាកម្មគ្រប់គ្រងបុគ្គលិកសំខាន់ៗ ដល់ក្រុមហ៊ុន។

## ៥. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ក្នុងការអនុវត្តលើគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន គណៈគ្រប់គ្រងត្រូវបានតម្រូវឱ្យធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតពីសមតុល្យយោងរបស់ទ្រព្យសកម្ម និងបំណុលដែលមិនទាន់កើតមានពីប្រភពផ្សេងៗ។ ការប៉ាន់ស្មាន និងការសន្មតដែលទាក់ទង គឺផ្អែកលើបទពិសោធន៍នាពេលកន្លងមក និងកត្តាផ្សេងទៀតដែលត្រូវបានកំណត់ថាពាក់ព័ន្ធ។ លទ្ធផលជាក់ស្តែងអាចនឹងខុសគ្នាពីការប៉ាន់ស្មានទាំងនេះ។

ការប៉ាន់ស្មាន និងការសន្មតដែលកើតមានគឺត្រូវបានត្រួតពិនិត្យឡើងវិញលើមូលដ្ឋានបន្តនិរន្តរភាព។ ការត្រួតពិនិត្យឡើងវិញនៃការប៉ាន់ស្មានគណនេយ្យ ត្រូវបានទទួលស្គាល់ក្នុងកាលបរិច្ឆេទដែលការប៉ាន់ស្មានត្រូវបានកែប្រែ ប្រសិនបើការកែតម្រូវប៉ះពាល់តែក្នុងកាលបរិច្ឆេទ ឬក្នុងកាលបរិច្ឆេទនៃការកែប្រែ និងកាលបរិច្ឆេទនាពេលអនាគត ប្រសិនបើការកែប្រែប៉ះពាល់ទាំងក្នុងកាលបរិច្ឆេទបច្ចុប្បន្ន និងកាលបរិច្ឆេទពេលអនាគត។

### ក. ការប៉ាន់ស្មាន និងការសន្មតគណនេយ្យសំខាន់ៗ

ខាងក្រោមនេះ គឺជាការសន្មតសំខាន់ៗទាក់ទងនឹងអនាគត និងប្រភពសំខាន់ៗផ្សេងទៀតនៃភាពមិនច្បាស់លាស់នៃការប៉ាន់ស្មាននៅចុងការិយច្ឆេទនៃរបាយការណ៍នីមួយៗ ដែលមានហានិភ័យខ្ពស់ដែលបណ្តាលមកពីនិយ័តកម្មជាសារវន្តនៃតម្លៃយោងរបស់ធនធាន និងបំណុលនៅក្នុងការិយបរិច្ឆេទនៃរបាយការណ៍ក្រោយទៀត។

*ចំណូលកិច្ចសន្យា*

ការទទួលស្គាល់ចំណូលកិច្ចសន្យា និងគណនីត្រូវទទួលផ្សេងទៀតដែលបានប៉ាន់ស្មាន របស់អ្នកគ្រប់គ្រងលើលទ្ធផលនៃកិច្ចសន្យានីមួយៗ និងដំណាក់កាលនៃការបញ្ចប់។ នេះរាប់បញ្ចូលទាំងការវាយតម្លៃនៃប្រាក់ចំណេញនៃកិច្ចសន្យាសាងសង់ដែលកំពុងបន្ត និងការការរាំងស្ទះចាស់។ ចំពោះកិច្ចសន្យាដែលស្មុគស្មាញជាងនេះជាពិសេសការចំណាយដើម្បីបញ្ចប់ និងប្រាក់ចំណេញក្នុងកិច្ចសន្យា គឺអាស្រ័យលើភាពមិនច្បាស់លាស់នៃការប៉ាន់ស្មាន។

*ការប៉ាន់ស្មានការខាតបង់លើសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុក*

ក្រុមហ៊ុនវាស់វែងលើការខាតបង់ឥណទានដែលបានរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុតាមរយៈការឆ្លុះបញ្ចាំងពីភាពមិនលម្អៀង និងចំនួនទឹកប្រាក់ជាមធ្យមដែលត្រូវបានកំណត់តាមរយៈការវាយតម្លៃក្នុងកម្រិតនៃលទ្ធផលដែលអាចកើតមាន តម្លៃសាច់ប្រាក់តាមពេលវេលា និងព័ត៌មានអំពីព្រឹត្តិការណ៍កន្លងមក លក្ខខណ្ឌបច្ចុប្បន្ន និងការព្យាករណ៍ពីលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត។ នៅពេលដែលវាស់វែង ECL ក្រុមហ៊ុនប្រើប្រាស់ព័ត៌មាននាពេលអនាគតដែលសមហេតុផល និងមានប្រយោជន៍ ដោយផ្អែកលើការសន្មតពីការប្រែប្រួលនាពេលអនាគតនៃភាពខុសគ្នានៃអ្នកដំណើរការសេដ្ឋកិច្ច និងពីរបៀបដែលអ្នកដំណើរការនេះនឹងប៉ះពាល់ដល់កត្តាផ្សេងទៀត។

*ការប៉ាន់ស្មានតម្លៃលក់សុទ្ធរបស់សន្និធិ*

តម្លៃលក់សុទ្ធរបស់សន្និធិតំណាងឱ្យតម្លៃលក់ដែលបានប៉ាន់ស្មានរបស់សន្និធិដករាល់ថ្លៃដើមក្នុងការទិញដែលបានប៉ាន់ស្មានទុក និងថ្លៃដើមដែលអាចកើតមានក្នុងការលក់។ ក្រុមហ៊ុនកំណត់តម្លៃលក់ដែលបានប៉ាន់ស្មានទុកដោយផ្អែកលើប្រតិបត្តិការលក់ជាក់ស្តែងនៃផលិតផលស្រដៀងគ្នាព្រមជាមួយនឹងការកែតម្រូវដែលឆ្លុះបញ្ចាំងពីការប្រែប្រួលលក្ខខណ្ឌសេដ្ឋកិច្ចចាប់ពីកាលបរិច្ឆេទដែលប្រតិបត្តិការបានកើតឡើង។ ក្រុមហ៊ុនធ្វើការកត់ត្រាលើសំវិធានធននៃថ្លៃដើមដែលលើសពីតម្លៃលក់ជាក់ស្តែងនៃសន្និធិ។ អំឡុងពេលដែលក្រុមហ៊ុនជឿជាក់ថាការប៉ាន់ស្មានគឺសមហេតុផល និងសមស្រប ភាពខុសគ្នាគួរឱ្យកត់សម្គាល់ក្នុងបទពិសោធន៍ជាក់ស្តែង ឬការកែប្រែគួរឱ្យកត់សម្គាល់ក្នុងការប៉ាន់ស្មានដែលអាចប៉ះពាល់ជាសារវន្តទៅលើគណនីចំណេញ ឬខាត និងមូលធន។

*ការប៉ាន់ស្មានលើអាយុកាលប្រើប្រាស់លើទ្រព្យសកម្ម*
អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មរបស់ក្រុមហ៊ុនជាមួយអាយុកាលជាក់លាក់ត្រូវបានប៉ាន់ស្មានទុកដោយផ្អែកលើកាលបរិច្ឆេទហួសកាលកំណត់ដែលទ្រព្យសកម្មត្រូវបានរំពឹងទុកថាអាចយកមកប្រើប្រាស់បាន។ អាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មានទុកនៃទ្រព្យសម្បត្តិ និងបរិក្ខាររបស់ក្រុមហ៊ុនត្រូវបានត្រួតពិនិត្យឡើងវិញជាប្រចាំ និងត្រូវបានធ្វើបច្ចុប្បន្នភាពប្រសិនបើការរំពឹងទុកខុសគ្នាពីការប៉ាន់ស្មានកន្លងមកដោយផ្អែកលើរូបរាង បច្ចេកទេស ឬកាលហួសសម័យផ្នែកពាណិជ្ជកម្ម និងច្បាប់ ឬការកំណត់ផ្សេងទៀតលើការប្រើប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុន។

បន្ថែមពីនេះទៀត ការប៉ាន់ស្មានលើអាយុកាលប្រើប្រាស់គឺផ្អែកលើការប្រមូលផ្តុំការវាយតម្លៃរបស់ក្រុមហ៊ុនទៅលើការអនុវត្តរបស់សហគ្រាស ការវាយតម្លៃបច្ចេកទេសផ្ទៃក្នុង និងបទពិសោធន៍ជាទ្រព្យសកម្មស្រដៀងគ្នា។ វាអាចទៅរួច ទោះបីជាយ៉ាងណា លទ្ធផលនៃប្រតិបត្តិការនាពេលអនាគតទាំងនេះអាចមានផលប៉ះពាល់ជាសារវន្តដោយការប្រែប្រួលក្នុងការប៉ាន់ស្មានដោយសារការផ្លាស់ប្តូរកត្តារទាំងអស់ដែលបានរៀបរាប់ខាងលើ។ ចំនួនទឹកប្រាក់ និងកាលកំណត់នៃចំណាយដែលបានកត់ត្រារាល់កាលបរិច្ឆេទដែលនឹងប៉ះពាល់ដោយសារការផ្លាស់ប្តូរក្នុងកត្តា និងកាលៈទេសៈទាំងនេះ។ ការកាត់បន្ថយលើអាយុកាលនៃការប្រើប្រាស់ដែលបានប៉ាន់ស្មានទុករបស់ទ្រព្យសម្បត្តិ និងបរិក្ខារដែលនឹងត្រូវបានទទួលស្គាល់ក្នុងគណនីចំណាយប្រតិបត្តិការ និងថយចុះក្នុងគណនីទ្រព្យសកម្មរយៈពេលវែង។

*ភតិសន្យាជួល- ការប៉ាន់ស្មាននៃការកើនឡើងនៃអត្រាប្រាក់កម្ចី*
ក្រុមហ៊ុនមិនអាចកំណត់បាននូវអត្រាការប្រាក់ជាក់ស្តែងដែលមាននៅក្នុងភតិសន្យាឡើយ ដូច្នេះវាប្រើអត្រាប្រាក់កម្ចីកើនឡើងរបស់ខ្លួន (IBR) ដើម្បីវាស់វែងបំណុលភតិសន្យាជួល។ IBR គឺជាអត្រាការប្រាក់ដែលធនាគារត្រូវចំណាយដើម្បីខ្ចីក្នុងរយៈពេលស្រដៀងគ្នានេះ ហើយដោយមានសន្តិសុខប្រហាក់ប្រហែល មូលនិធិចាំបាច់ដើម្បីទទួលបានទ្រព្យសម្បត្តិដែលមានតំលៃប្រហាក់ប្រហែល នឹងទ្រព្យសម្បត្តិប្រើប្រាស់ត្រឹមត្រូវក្នុងបរិស្ថានសេដ្ឋកិច្ចស្រដៀងគ្នា។ ធនាគារប៉ាន់ស្មាន IBR ដោយប្រើប្រាស់អត្រាការប្រាក់ខ្ចីជាមធ្យមនៅកម្ពុជា។

*ការប៉ាន់ស្មានថ្លៃដើមនៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម*
ការកំណត់ថ្លៃដើមនៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម រួមបញ្ចូលទាំងចំនួនទឹកប្រាក់នៃបំណុលភតិសន្យាដែលបានទទួលស្គាល់ និងថ្លៃដើមដែលបានប៉ាន់ស្មានទុកថានឹងកើតមានក្នុងការរុះរើ ឬដកចេញនូវទ្រព្យសកម្មគោល ឬការកែលម្អឡើងវិញឱ្យតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យា។

*ឱនភាពនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*
ក្រុមហ៊ុនធ្វើការអនុវត្តលើការត្រួតពិនិត្យលើឱនភាពនៃតម្លៃនៅពេលដែលមានសូចនាករបង្ហាញពីឱនភាពជាក់លាក់។

ការកំណត់លើតម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសម្បត្តិកំពុងសាងសង់ដែលតម្រូវឱ្យមានការកំណត់លំហូរសាច់ប្រាក់ដែលរំពឹងទុកថានឹងទទួលបានពីការប្រើប្រាស់បន្ត និងការបែងចែកទ្រព្យសកម្មចុងក្រោយ តម្រូវឱ្យក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងសន្មតថាដែលអាចប៉ះពាល់ជាសារវន្តដល់របាយការណ៍ហិរញ្ញវត្ថុ។ ព្រឹត្តិការណ៍នាពេលអនាគតអាចឱ្យក្រុមហ៊ុនអាចសន្និដ្ឋានបានទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសម្បត្តិកំពុងសាងសង់គឺមានឱនភាព។ រាល់លទ្ធផលនៃការខាតបង់លើឱនភាពនៃតម្លៃអាចមានផលប៉ះពាល់អវិជ្ជមានជាសារវន្តទៅលើលក្ខខណ្ឌហិរញ្ញវត្ថុ និងលទ្ធផលនៃប្រតិបត្តិការ។

ការរៀបចំលំហូរសាច់ប្រាក់នាពេលអនាគតដែលទាក់ទងនឹងការវិនិច្ឆ័យ និងការប៉ាន់ស្មានសំខាន់ៗ ខណៈពេលដែលក្រុមហ៊ុនជឿជាក់ថាការសន្មតគឺសមស្រប និងសមហេតុផល ការផ្លាស់ប្តូរសំខាន់ៗក្នុងការសន្មតដែលអាចមានផលប៉ះពាល់ជាសារវន្តក្នុងការវាយតម្លៃលើតម្លៃដែលអាចប្រមូលមកវិញបាន ហើយអាចបណ្តាលឱ្យមានឱនភាពលើតម្លៃ។

## ខ. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ
ខាងក្រោមនេះ គឺជាការវិនិច្ឆ័យសំខាន់ៗ ក្រៅពីការប៉ាន់ស្មានដែលពាក់ព័ន្ធទាំងនោះ គណៈគ្រប់គ្រងបានដំណើរការក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ហើយវាមានផលប៉ះពាល់ខ្លាំងបំផុតលើចំនួនទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

*ការទទួលស្គាល់នៃចំណូលកិច្ចសន្យា*

ការទទួលស្គាល់នៃកិច្ចសន្យាសាងសង់ តម្រូវអោយមានការវិនិច្ឆ័យយ៉ាងម៉ត់ចត់ ក្នុងការកំណត់ទិសដៅការងារជាក់ស្តែង និងការចំណាយដែលបានប៉ាន់ស្មានដើម្បីបញ្ចប់ការងារ។

*ការកំណត់រយៈពេលក្នុងការបំពេញកិច្ចសន្យា*

ក្រុមហ៊ុនបានវាយតម្លៃថាកិច្ចសន្យាជាមួយអតិថិជនដែលមានការអនុវត្តកាតព្វកិច្ចលើសពីមួយ នោះប្រាក់ចំណូលដែលកើតចេញពីការទទួលស្គាល់តាមពេលវេលា ការបំពេញកាតព្វកិច្ច គឺផ្អែកលើរបាយការណ៍ការបំពេញសេវាកម្មដែលបានសន្យាក្នុងកិច្ចសន្យាត្រូវបានបញ្ចប់។ ទន្ទឹមនឹងនេះដែរ នៅពេលដែលមានការអនុវត្តកាតព្វកិច្ចតែមួយ ប្រាក់ចំណូលដែលកើតចេញពីការទទួលស្គាល់ក្នុងរយៈពេលណាមួយ នៅពេលសិទ្ធិក្នុងការគ្រប់គ្រងសន្និធិត្រូវបានផ្ទេរទៅឱ្យអតិថិជន។

*ការកំណត់តម្លៃប្រតិបត្តិការ និងចំនួនទឹកប្រាក់ដែលបានបំពេញលើកាតព្វកិច្ច*

ក្រុមហ៊ុនពិចារណាលើលក្ខខណ្ឌនៃកិច្ចសន្យា និងការអនុវត្តអាជីវកម្មតាមទម្លាប់របស់ខ្លួន ដើម្បីកំណត់តម្លៃប្រតិបត្តិការ។ តម្លៃប្រតិបត្តិការគឺជាចំនួនទឹកប្រាក់នៃការពិចារណាដែលក្រុមហ៊ុនរំពឹងថានឹងមានសិទ្ធិជាថ្នូរនឹងសេវាកម្មដែលត្រូវអនុវត្ត និងការផ្ទេរសិទ្ធិក្នុងការគ្រប់គ្រងលើសន្និធិទៅឱ្យអតិថិជន។

ក្រុមហ៊ុនបានវាយតម្លៃថាកិច្ចសន្យាជាមួយអតិថិជនដែលមានកាតព្វកិច្ចលើសពីមួយ។ ប្រាក់ចំណូលដែលកើតឡើងពីកិច្ចព្រមព្រៀងដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ទទួលស្គាល់តាមពេលវេលា គឺផ្អែកលើរបាយការណ៍ការបំពេញសេវាកម្មដែលបានសន្យាក្នុងកិច្ចសន្យាត្រូវបានបញ្ចប់។ ក្រុមហ៊ុនបែងចែកតម្លៃប្រតិបត្តិការទៅតាមការបំពេញកាតព្វកិច្ចត្ត និងទទួលស្គាល់ប្រាក់ចំណូលតាមពេលវេលា។

ចំណូលប្រតិបត្តិការ ដែលមានការបំពេញកាតព្វកិច្ចតែមួយ ក្រុមហ៊ុនបានវាយតម្លៃថាប្រាក់ចំណូលដែលកើតឡើងពីកិច្ចព្រមព្រៀងដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ទទួលស្គាល់តាមពេលវេលា ដោយផ្អែកលើការផ្ទេរសិទ្ធិក្នុងការគ្រប់គ្រង។ សិទ្ធិក្នុងការគ្រប់គញរងលើសន្និធិសំដៅដល់ លទ្ធភាពក្នុងគ្រប់គ្រងការប្រើប្រាស់ និងការទទួលបានអត្ថប្រយោជន៍ពីកាប្រើប្រាស់ទ្រព្យសកម្មនោះ។ ក្រុមហ៊ុនបែងចែកតម្លៃប្រតិបត្តិការ លើការបំពេញកាតព្វកិច្ច និងទទួលស្គាល់ចំណូលក្នុងកាលបរិច្ឆេទណាមួយ។

*ការកំណត់សមតុល្យថ្លៃដើមកិច្ចសន្យា*

ក្រុមហ៊ុនបានវាយតម្លៃថាការកើនឡើងលើថ្លៃដើមក្នុងការធ្វើកិច្ចសន្យាជាមួយអតិថិជន ដែលមានដូចជាកម្រៃជើងសារលើការលក់ដែលបានទូទាត់ គឺជាចំណាយកើតឡើងក្នុងក្រុមហ៊ុន ដែលនឹងមិនកើតឡើងប្រសិនបើកិច្ចសន្យាមិនត្រូវបានធ្វើឡើង និងត្រូវតែត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម។

*ភតិសន្យាជួល*

ការវាយតម្លៃថាតើការរៀបចំមានរួមបញ្ចូលនូវភតិសន្យាដោយអាស្រ័យលើសមាសធាតុផ្សេងឬទេ។ ការរៀចំ គឺឬមានរួមបញ្ចូលនូវភតិសន្យានៅពេលដែលបានបំពេញប្រសិនបើការរៀបចំអាស្រ័យលើទ្រព្យសកម្មជាក់លាក់ ឬទ្រព្យសកម្មហើយការរៀបចំមានបង្ហាញពីសិទ្ធប្រើប្រាស់ទ្រព្យសកម្មនោះ។

*ភតិសន្យាជួលលើទ្រព្យសកម្មដែលមានតម្លៃទាប*

ក្នុងការវាយតម្លៃថាភតិសន្យាជួលមានតម្លៃទាប គណៈគ្រប់គ្រងពិចារណាលើខ្លឹមសារសេដ្ឋកិច្ចរបស់ទ្រព្យសកម្មមូលដ្ឋានទាំងស្រុង។

*អត្រាអប្បហារដែលបានប្រើប្រាស់ក្នុងការកំណត់សមតុល្យយោងនៃបំណុលភតិសន្យារបស់ក្រុមហ៊ុន*

បំណុលភតិសន្យារបស់ក្រុមហ៊ុនត្រូវបានធ្វើអប្បហារក្នុងអត្រាដែលបានកំណត់តាមរយៈការយោងទៅតាមទីផ្សារនាចុងកាលបរិច្ឆេទនៃរបាយការណ៍ដូចដែលបានបកស្រាយដោយ GDT។ ការវិនិច្ឆ័យសំខាន់ៗ គឺត្រូវបានតម្រូវនៅពេលដែលកំណត់ពីប្រភេទនៃអត្រាការប្រាក់របស់ប្រាក់កម្ចីដែលត្រូវបានរួមបញ្ចូលនៅក្នុងចំនួនប្រជាជនដែលអត្រាអប្បហារត្រូវបានយកមកប្រើប្រាស់។

*រំលស់សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម*

រំលស់របស់ទ្រព្យសកម្មដែលបានជួល គឺត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្រ្តរំលស់ថេរដើម្បីបែងចែងថ្លៃដើម តម្លៃកាកសំណល់សុទ្ធ លើអាយុកាលនៃការប្រើប្រាស់ដែលបានប៉ាន់ស្មានទុកដែលតិចជាងរវាងរយៈពេលជួលដែលនៅសល់ និងអាយុកាលរំពឹងទុករបស់ទ្រព្យសកម្ម។

*ចំណាយពន្ធលើប្រាក់ចំណូល*

ក្រុមហ៊ុននឹងទទួលស្គាល់នូវបំណុលសម្រាប់ការចំណាយពន្ធដែលរំពឹងទុកដោយផ្អែកលើការប៉ាន់ប្រមាណថាពន្ធនោះត្រូវបានកំណត់តាមរយៈការបកស្រាយបច្ចុប្បន្នរបស់គណៈគ្រប់គ្រងតាមច្បាប់ពន្ធផ្សេងៗដែលជាកម្មវត្ថុនៃការប្រែប្រួលតាមកាលវេលាកំណត់។ ការកំណត់ចុងក្រោយនៃចំណាយពន្ធនឹងត្រូវធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារ។

នៅពេលលទ្ធផលពន្ធចុងក្រោយខុសគ្នាពីចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់ដំបូងភាពខុសគ្នានេះនឹងជះឥទ្ធិពលដល់សំវិធានធនពន្ធនៅក្នុងឆ្នាំហិរញ្ញវត្ថុដែលបានកំណត់។

*ការទទួលស្គាល់ពន្ធពន្យារលើទ្រព្យសកម្ម*

វិសាលភាពនៃទ្រព្យសកម្មអាចត្រូវបានទទួលស្គាល់ដោយផ្អែកលើការប៉ាន់ស្មាននៃប្រូបាប៊ីលីតេដែលប្រាក់ចំណូលជាប់ពន្ធនាពេលអនាគតនឹងអាចប្រើបាន ហើយភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន និងខាតតាមមូលដ្ឋានពន្ធ អាចយកមកប្រើប្រាស់បាន។ លើសពីនេះទៅទៀត ការវិនិច្ឆ័យសំខាន់ត្រូវបានទាមទារនៅក្នុងការវាយតម្លៃផលប៉ះពាល់នៃដែនកំណត់ផ្អែកច្បាប់ ឬសេដ្ឋកិច្ចណាមួយ ឬភាពមិនច្បាស់លាស់នៅក្នុងប្រព័ន្ធយុត្តាធិការពន្ធផ្សេងៗ។

(ទំព័រនេះត្រូវទុកឱ្យចន្លោះទទេដោយចេតនា)

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ដីទំនេរ | គ្រឿងម៉ាស៊ីន | យានយន្ត | បរិក្ខារការិយាល័យ | គ្រឿងសង្ហារឹម | ការកែលម្អដី | អគារកំពុងសាងសង់ | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **សមតុល្យយោងដុល** | | | | | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | ២.១៦៧.៦២០ | ៥៥០.៦០២ | ៥៧៣.២៦៨ | ៦១.៣៧៦ | ៨.៦៥៣ | - | ៥២.១៦៥ | ៣.៤១៣.៦៨៤ | ១៣.៨០៨.៣៥២ |
| ទិញបន្ថែម | - | ១១៣.៤៤១ | ៤៩០ | ៧.៨១៧ | ២៥៧ | - | ៦០.៨០១ | ១៨២.៨០៦ | ៧៤៣.៦៥៥ |
| ផ្ទេរចេញ | - | - | - | - | - | ៥២.១៦៥ | (៥២.១៦៥) | - | - |
| ការលក់ចេញ | - | (១១.១០២) | (៣៥០) | (២.៧៦០) | - | - | - | (១៤.២១២) | (៥៧.៨១៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ១០០.០០៨ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ២.១៦៧.៦២០ | ៦៥២.៩៤១ | ៥៧៣.៤០៨ | ៦៦.៤៣៣ | ៨.៩១០ | ៥២.១៦៥ | ៦០.៨០១ | ៣.៥៨២.២៧៨ | ១៤.៥៩៤.២០១ |
| **រំលស់បង្គរ** | | | | | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | - | ២៩៥.៨៧៨ | ៤៦៥.៨៥៦ | ៤៤.៩២៨ | ៧.០០៧ | - | - | ៨១៣.៦៦៩ | ៣.២៩១.២៩១ |
| រំលស់ | - | ១០៥.៤៧៨ | ១៧.០៨១ | ៨.៨១៨ | ១.១៩៥ | ៥.២១៧ | - | ១៣៧.៧៨៩ | ៥៦០.៥២៦ |
| ការលក់ចេញ | - | (៩.២៨៦) | (២១៧) | (២.៧៣៩) | - | - | - | (១២.២៤២) | (៤៩.៨០០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ២៤.៣៤៩ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | - | ៣៩២.០៧០ | ៤៨២.៧២០ | ៥១.០០៧ | ៨.២០២ | ៥.២១៧ | - | ៩៣៩.២១៦ | ៣.៨២៦.៣៦៦ |
| **សមតុល្យយោងនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | ២.១៦៧.៦២០ | ២៦០.៨៧១ | ៩០.៦៨៨ | ១៥.៤២៦ | ៧០៨ | ៤៦.៩៤៨ | ៦០.៨០១ | ២.៦៤៣.០៦២ | ១០.៧៦៧.៨៣៥ |

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ដីទំនេរ<br>ដុល្លារអាមេរិក | គ្រឿងម៉ាស៊ីន<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារការិយាល័យ<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម<br>ដុល្លារអាមេរិក | ការកែលម្អដី<br>ដុល្លារអាមេរិក | អគារកំពុងសាងសង់<br>ដុល្លារអាមេរិក | ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|---|---|---|---|
| សមតុល្យយោងដុល | | | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ២.១៦៧.៦២០ | ៥៩៥.៦១០ | ៥៧២.២០៤ | ៦១.៨៨០ | ៧.៥៦៣ | - | - | ៣.៤០៤.៨៧៧ | ១៣.៨៧៤.៨៧៤ |
| ទិញបន្ថែម | - | ៩៦.០០៥ | ១០.៦៤៥ | ១៥.៩៤៨ | ២.១៤៣ | - | ៥២.១៦៥ | ១៧៦.៩០៦ | ៧២១.២៤៦ |
| ការលក់ចេញ | - | - | (៩.៥៨១) | - | - | - | - | (៩.៥៨១) | (៣៩.០៦២) |
| លុបចេញពីបញ្ជី | - | (១៤១.០១៣) | - | (១៦.៤៥២) | (១.០៥៣) | - | - | (១៥៨.៥១៨) | (៦៤៦.២៧៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | (១០២.៤២៨) |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ២.១៦៧.៦២០ | ៥៥០.៦០២ | ៥៧៣.២៦៨ | ៦១.៣៧៦ | ៨.៦៥៣ | - | ៥២.១៦៥ | ៣.៤១៣.៦៨៤ | ១៣.៨០៨.៣៥២ |
| រំលស់បង្គរ | | | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | - | ៣៥២.៥១៨ | ៤៥១.៨៦០ | ៤៨.៦៣៩ | ៧.៤១៩ | - | - | ៨៦០.៤៣៦ | ៣.៥០៦.២៧៧ |
| រំលស់ | - | ៨៣.៣៧៨ | ២៣.៥៧៧ | ១២.៧៤១ | ៦៤១ | - | - | ១២០.៣៣៧ | ៤៩០.៦១៤ |
| ការលក់ចេញ | - | - | (៩.៥៨១) | - | - | - | - | (៩.៥៨១) | (៣៩.០៦២) |
| លុបចេញពីបញ្ជី | - | (១៤០.០១៨) | - | (១៦.៤៥២) | (១.០៥៣) | - | - | (១៥៧.៥២៣) | (៦៤២.២២១) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | (២៤.៣១៧) |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | - | ២៩៥.៨៧៨ | ៤៦៥.៨៥៦ | ៤៤.៩២៨ | ៧.០០៧ | - | - | ៨១៣.៦៦៩ | ៣.២៩១.២៩១ |
| សមតុល្យយោងនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ២.១៦៧.៦២០ | ២៥៤.៧២៤ | ១០៧.៤១២ | ១៦.៤៤៨ | ១.៦៤៦ | - | ៥២.១៦៥ | ២.៦០០.០១៥ | ១០.៥១៧.០៦១ |

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងជាមួយធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ ក្នុងចំនួនទឹកប្រាក់ ១.៦៩០.០០០ ដុល្លារអាមេរិក មានអត្រាការប្រាក់ ៨% ក្នុងមួយឆ្នាំ ជាមួយនឹងការទូទាត់រយៈពេល ៧២ (ចិតសិបពីរ) ខែគិតចាប់ពីកាលបិរច្ឆេទដែលឥណទានមានប្រសិទ្ធភាព។ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ប្រាក់ដើមនៃឥណទានដែលនៅសល់មានចំនួន ១.៣៨៤.០១៦ ដុល្លារអាមេរិក។ ឥណទាននេះត្រូវបានដាក់ធានាដោយដីឡូត៍ចំនួនពីរប្លង់ដែលមានទំហំសរុបចំនួន ១០.៣២២ ម៉ែត្រការ៉េ ដែលមានវិញ្ញាប័ណ្ណប័ត្របញ្ជាក់កម្មសិទ្ធិលេខ ១២១២០១០៣-០៤៩៥ និង ២១២០១០៣-០៤៩៦ ដោយប្លង់លេខ ៤៩៥ និងប្លង់លេខ ៤៩៦ មានទីតាំងស្ថិតនៅភូមិស្វាយចេក សង្កាត់គោករកា ខណ្ឌព្រែកព្នៅ ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានកត់ត្រាជាទ្រព្យសម្បត្តិ និងបរិក្ខាររបស់ក្រុមហ៊ុន ដែលមានតម្លៃ ២.១៦៧.៦២០ ដុល្លារអាមេរិក។ ប័ណ្ណកម្មសិទ្ធិដីមួយប្លង់ត្រូវបានចុះបញ្ជីក្រោមឈ្មោះរបស់លោក នាង វិធី និងលោកស្រី លឹម មុយលី ដែលជាតំណាងឱ្យក្រុមហ៊ុន។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ក្រុមហ៊ុនបានទូទាត់រួចរាល់ទៅលើបំណុលដែលនៅសល់ទាក់ទងទៅនឹងការទិញដីឡូត៍ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០៖ មានចំនួន ៤៨៤.៥២០ ដុល្លារអាមេរិក)។

## ៧. ទ្រព្យសកម្មអរូបី

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **សមតុល្យយោងដុល** | | | | |
| សមតុល្យយោងនៅថ្ងៃទី១ ខែមករា | ៤២.៨៤៥ | ១៧៣.៣០៨ | ៤១.៩៤៦ | ១៧០.៩៣០ |
| បូកបន្ថែម | - | - | ៨៩៩ | ៣.៦៦៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ១.២៤៣ | - | (១.២៨៧) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ** | ៤២.៨៤៥ | ១៧៤.៥៥១ | ៤២.៨៤៥ | ១៧៣.៣០៨ |
| **រំលស់បង្គរ** | | | | |
| សមតុល្យនៅថ្ងៃទី១ ខែមករា | ៥.៣៨៩ | ២១.៧៩៨ | ១.១៦៥ | ៤.៧៤៧ |
| រំលស់លើទ្រព្យសកម្មអរូបី | ៣.៤៧០ | ១៤.១១៦ | ៤.២២៤ | ១៧.២២១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ១៧៨ | - | (១៧០) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ** | ៨.៨៥៩ | ៣៦.០៩២ | ៥.៣៨៩ | ២១.៧៩៨ |
| **សមតុល្យយោងនៅថ្ងៃទី៣១ ខែធ្នូ** | ៣៣.៩៨៦ | ១៣៨.៤៥៩ | ៣៧.៤៥៦ | ១៥១.៥១០ |

## ៨. សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម និងបំណុលភតិសន្យា

*ក្រុមហ៊ុនក្នុងនាមជាអ្នកជួល*

ក្រុមហ៊ុនមានកិច្ចសន្យាជួល ទៅលើអគារដែលជាទីតាំងការិយាល័យរបស់ខ្លួនសម្រាប់រយៈពេលដប់ឆ្នាំ (១០ឆ្នាំ) ជាកិច្ចសន្យាដែលមិនអាចលុបចោលបាន ជាមួយនឹងជម្រើសក្នុងការបន្តកិច្ចសន្យាជួលសម្រាប់រយៈពេលបន្តរបន្ទាប់ពីកិច្ចសន្យាចាស់ត្រូវបានបញ្ចប់។ ក្រុមហ៊ុនមិនបានធ្វើការត្រួតពិនិត្យឡើងវិញ ទៅលើការចាត់ចែង និងជួលបន្តរទៅលើទ្រព្យសកម្មដែលបានជួលនោះទេ។

សមតុល្យយោងនៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មដែលបានទទួលស្គាល់ និងបម្រែបម្រួលក្នុងអំឡុងការិយបរិច្ឆេទដូចខាងក្រោម៖

| | ឆ្នាំ២០២១ | | ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **សមតុល្យយោងដុល** | | | | |
| សមតុល្យយោងនៅថ្ងៃទី១ ខែមករា | ៣៩២.៩៤១ | ១.៥៨៩.៤៤៦ | ៣៩២.៩៤១ | ១.៦០១.២៣៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ១១.៣៩៦ | - | (១១.៧៨៩) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ** | ៣៩២.៩៤១ | ១.៦០០.៨៤២ | ៣៩២.៩៤១ | ១.៥៨៩.៤៤៦ |
| **រំលស់បង្គរ** | | | | |
| សមតុល្យនៅថ្ងៃទី១ ខែមករា | ៣២២.៥៣៩ | ១.៣០៤.៦៧០ | ២៨៣.២៤៦ | ១.១៥៤.២២៨ |
| រំលស់លើទ្រព្យសកម្មអរូបី | ៣៧.៦៥៧ | ១៥៣.១៨៩ | ៣៩.២៩៣ | ១៦០.១៩៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៩.៥៨០ | - | (៩.៧៥៦) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ** | ៣៦០.១៩៦ | ១.៤៦៧.៤៣៩ | ៣២២.៥៣៩ | ១.៣០៤.៦៧០ |
| **សមតុល្យយោងនៅថ្ងៃទី៣១ ខែធ្នូ** | ៣២.៧៤៥ | ១៣៣.៤០៣ | ៧០.៤០២ | ២៨៤.៧៧៦ |

តារាងខាងក្រោមនេះពិពណ៌នាអំពីលក្ខណៈនៃសកម្មភាពភតិសន្យាជួលរបស់ក្រុមហ៊ុន តាមប្រភេទនៃទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ត្រូវបានទទួលស្គាល់នៅក្នុងតារាងតុល្យការៈ

| **ទ្រព្យសម្បត្តិដែលមានសិទ្ធិប្រើប្រាស់** | **ចំនួននៃទ្រព្យសម្បត្តិដែលមានសិទ្ធិប្រើប្រាស់** | **ចំណាត់ថ្នាក់នៃរយៈពេលដែលនៅសល់** | **រយៈពេលនៃការជួលជាមធ្យមដែលនៅសល់** | **ចំនួននៃការជួលដែលមានជម្រើសបន្ត** | **ចំនួននៃការជួលដែលមានជម្រើសក្នុងការទិញ** | **ចំនួននៃការជួលជាមួយនឹងការទូទាត់អថេរដែលភ្ជាប់ទៅនឹងសន្ទស្សន៍** | **ចំនួននៃការជួលដែលមានជម្រើសបញ្ចប់** |
|---|---|---|---|---|---|---|---|
| អគារការិយាល័យ | ១ | ១.៨ | ១.៨ | - | - | - | - |

បំណុលភតិសន្យាត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៤.២)** | | (កំណត់សម្គាល់ ៤.២) |
| បំណុលរយៈពេលខ្លី | **៤៨.៥០៩** | **១៩៧.៦២៦** | ៦០.០៩០ | ២៤៣.០៦៤ |
| បំណុលរយៈពេលវែង | - | - | ៤៨.៥១០ | ១៩៦.២២៣ |
| | **៤៨.៥០៩** | **១៩៧.៦២៦** | ១០៨.៦០០ | ៤៣៩.២៨៧ |

តារាងខាងក្រោម បង្ហាញអំពីសមតុល្យយោង និងបម្រែបម្រួលនៃបំណុលភតិសន្យាក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | **ឆ្នាំ២០២១** | | ឆ្នាំ២០២០ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៤.២)** | | (កំណត់សម្គាល់ ៤.២) |
| **នៅថ្ងៃទី១ ខែមករា** | **១០៨.៦០០** | **៤៣៩.២៨៧** | ១៦៣.២២៣ | ៦៦៥.១៣៤ |
| ការកើនឡើងនៃការប្រាក់ | **៧.១១០** | **២៨.៩២៣** | ១២.៥៧៧ | ៥១.២៧៧ |
| ការទូទាត់សង | **(៦៧.២០១)** | **(២៧៣.៣៧៤)** | (៦៧.២០០) | (២៧៣.៩៧៥) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | **២.៧៩០** | - | (៣.១៤៩) |
| **នៅថ្ងៃទី៣១ ខែធ្នូ** | **៤៨.៥០៩** | **១៩៧.៦២៦** | ១០៨.៦០០ | ៤៣៩.២៨៧ |

## ៨.១. ការផ្ទៀងផ្ទាត់ទៅលើបំណុល ដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទាន

បម្រែបម្រួកលើបំណុលរបស់ក្រុមហ៊ុន ដែលកើតឡើងពីសកម្មភាពហិរញ្ញប្បទានត្រូវបានចាត់ថ្នាក់ដូចខាងក្រោម៖

| | **ថ្ងៃទី១ ខែមករា ឆ្នាំ២០២១** | **សម្រាប់ចុងការិយបរិច្ឆេទនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | | **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | |
|---|---|---|---|---|---|---|
| | | **ដកមកប្រើប្រាស់** | **ការសងត្រឡប់** | **លំហូរមិនមែនសាច់ប្រាក់** | | |
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** |
| **បំណុលភតិសន្យា** | **១០៨.៦០០** | **-** | **(៦៧.២០១)** | **៧.១១០** | **៤៨.៥០៩** | **១៩៧.៦២៦** |

| | ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | សម្រាប់ចុងការិយបរិច្ឆេទនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | | នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|---|
| | | ដកមកប្រើប្រាស់ | ការសងត្រឡប់ | លំហូរមិនមែនសាច់ប្រាក់ | | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| បំណុលភតិសន្យា | ១៦៣.២២៣ | - | (៦៧.២០០) | ១២.៥៧៧ | ១០៨.៦០០ | ៤៣៩.២៨៧ |

## ៨.២. ការទូទាត់បំណុលភតិសន្យាអប្បរមានាពេលអនាគត

ព័ត៌មានលម្អិតនៃការទូទាត់បំណុលភតិសន្យាអប្បរមានាពេលអនាគត ដែលទាក់ទងនឹងការជួលការិយាល័យត្រូវបានសង្ខេបដូចខាងក្រោម៖

| | **ទូទាត់ភតិសន្យាអប្បរមា** | | | |
|---|---|---|---|---|
| | **ក្នុងអំឡុងពេលមួយឆ្នាំ** | **១ ទៅ២ ឆ្នាំ** | **សរុប ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | | | |
| **បំណុលភតិសន្យា** | **៥០.៤០០** | **-** | **៥០.៤០០** | **២០៥.៣៣០** |
| **សេវាហិរញ្ញវត្ថុ** | **(១.៨៩១)** | **-** | **(១.៨៩១)** | **(៧.៧០៤)** |
| **តម្លៃបច្ចុប្បន្នសុទ្ធ** | **៤៨.៥០៩** | **-** | **៤៨.៥០៩** | **១៩៧.៦២៦** |

| | ទូទាត់ថ្លៃជួលអប្បរមា | | | |
|---|---|---|---|---|
| | ក្នុងអំឡុងពេលមួយឆ្នាំ | ១ ទៅ២ ឆ្នាំ | សរុប ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | | | |
| បំណុលភតិសន្យា | ៦៧.២០០ | ៥០.៤០០ | ១១៧.៦០០ | ៤៧៥.៦៩២ |
| សេវាហិរញ្ញវត្ថុ | (៧.១១០) | (១.៨៩០) | (៩.០០០) | (៣៦.៤០៥) |
| តម្លៃបច្ចុប្បន្នសុទ្ធ | ៦០.០៩០ | ៤៨.៥១០ | ១០៨.៦០០ | ៤៣៩.២៨៧ |

## ៩. ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ប្រាក់តម្កល់ | ២០.០៥០ | ៨១.៦៨៤ | ២០.០៥០ | ៨១.១០២ |
| ប័ណ្ណបំណុលដែលត្រូវទទួល | - | - | ៣៩.០០០ | ១៥៧.៧៥៥ |
| | ២០.០៥០ | ៨១.៦៨៤ | ៥៩.០៥០ | ២៣៨.៨៥៧ |

## ១០. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| សាច់ប្រាក់ក្នុងធនាគារ | ២១៨.៦០៣ | ៨៩០.៥៨៩ | ២៧៧.៩៩៣ | ១.១២៤.៤៨២ |
| សាច់ប្រាក់ក្នុងដៃ | ៦.៥១៦ | ២៦.៥៤៦ | ៥.១៣១ | ២០.៧៥៥ |
| | ២២៥.១១៩ | ៩១៧.១៣៥ | ២៨៣.១២៤ | ១.១៤៥.២៣៧ |

## ១១. ប្រាក់តម្កល់ធានា

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ប្រាក់តម្កល់ធានាលើឧបករណ៍ឥណទាន | ៦៥.០០០ | ២៦៤.៨១០ | ២១០.៥៤៥ | ៨៥១.៦៥៥ |

ប្រាក់តម្កល់ធានាមានរយៈពេល ១២ ខែត្រូវបានប្រើប្រាស់ជាការធានាសុវត្ថិភាព ក្នុងការផ្តល់ឧបករណ៍ឥណទានដែលបានផ្តល់ដល់ក្រុមហ៊ុន ដោយទទួលបានការប្រាក់ ៦% ក្នុងមួយឆ្នាំ។ ប្រាក់បញ្ញើសន្សំទាំងនេះជាប្រាក់បញ្ញើរជាមួយធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ និង ធនាគារ មេយប៉ែង (ខេមបូឌា) ភីអិលស៊ី។

## ១២. គណនីពាណិជ្ជត្រូវទទួល

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| គណនីពាណិជ្ជត្រូវទទួល | ៤.៥១០.៦៦៦ | ១៨.៣៧៦.៤៥៣ | ៩៥៥.០៧៩ | ៣.៨៦៣.២៩៥ |
| គណនីត្រូវទទួលរក្សាទុក | ១.៧៦២.៣៩១ | ៧.១៧៩.៩៨១ | ៥៣២.១៤០ | ២.១៥២.៥០៦ |
| | ៦.២៧៣.០៥៧ | ២៥.៥៥៦.៤៣៤ | ១.៤៨៧.២១៩ | ៦.០១៥.៨០១ |

## ១៣. សន្និធិ - សុទ្ធ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| វត្ថុធាតុដើមសម្រាប់តំឡើងប្រព័ន្ធម៉ាស៊ីនត្រជាក់ HVAC | **២.១៦៧.២៥៨** | **៨.៨២៩.៤០៩** | ១.៦៣៣.៨១៦ | ៦.៦០៨.៧៨៦ |

ក្នុងឆ្នាំ២០២១ តម្លៃសរុបរបស់សន្និធិរួមមានចំនួន ៩.៥៦៩.០៤៤ ដុល្លារអាមេរិក (ឆ្នាំ២០២០៖ មានចំនួន ៥.៥២៨.៩៦៧ ដុល្លារអាមេរិក) ត្រូវបានរួមបញ្ចូលទៅក្នុងថ្លៃដើមនៃសេវាកម្ម និងទំនិញដែលបានលក់។

## ១៤. ទ្រព្យសកម្មរយៈពេលខ្លីផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ចំណាយបង់មុន | **៦៣០.៥០៦** | **២.៥៦៨.៦៨១** | ៤៤៤.៣៩៧ | ១.៧៩៧.៥៨៦ |
| ឥណទានបុគ្គលិក | **៣១២.២៣៣** | **១.២៧២.០៣៧** | ១០.០០០ | ៤០.៤៤៩ |
| បុរេប្រទានប្រាក់បៀវត្ស | **៣.៧៧១** | **១៥.៣៦៣** | - | - |
| សម្ភារៈប្រើប្រាស់ | **៤៥២** | **១.៨៤២** | - | - |
| ឥណទានអាករលើតម្លៃបន្ថែមយោងទៅការិយថ្មី | - | - | ៣.០៧៩ | ១២.៤៥៥ |
| | **៩៤៦.៩៦២** | **៣.៨៥៧.៩២៣** | ៤៥៧.៤៧៦ | ១.៨៥០.៤៩០ |

អត្រាការប្រាក់លើឥណទានបុគ្គលិកត្រូវបានកាត់កងដោយក្រុមហ៊ុន ដែលមានចន្លោះពី 0% ទៅ ១%ក្នុងមួយខែ។

## ១៥. ទ្រព្យសកម្មកិច្ចសន្យា/បំណុលកិច្ចសន្យា

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ទ្រព្យសកម្មកិច្ចសន្យា | **៣.៧៩១.៣៦៦** | **១៥.៤៤៦.០២៥** | ៣.១៥០.៨៣០ | ១២.៧៤៥.១០៧ |
| បំណុលកិច្ចសន្យា | **១៦១.៨៨០** | **៦៥៩.៤៩៩** | ៤០៧.៩៥៣ | ១.៦៥០.១៧០ |

ទ្រព្យសកម្មកិច្ចសន្យាតំណាងឱ្យ សិទ្ធិរបស់ក្រុមហ៊ុនដកជាទឹកប្រាក់លើកិច្ចសន្យាសាងសង់ ប៉ុន្តែមិនទាន់បានចេញវិក្កយបត្រនៅកាលបរិច្ឆេទនៃរបាយការណ៍។ ជាធម្មតាវិក្កយបត្រនឹងត្រូវបានចេញក្នុងរយៈពេល ៣០ថ្ងៃ ហើយការទូទាត់ត្រូវបានគេរំពឹងទុកក្នុងរយៈពេល ៦០ថ្ងៃ។

បំណុលកិច្ចសន្យាជា ចំនួនទឹកប្រាក់ដែលទទួលបានពីអតិថិជនសម្រាប់កិច្ចសន្យាសាងសង់ដែលប្រាក់ចំណូលត្រូវបានគេទទួលស្គាល់ក្នុងរយៈពេលសាងសង់អចលនទ្រព្យ។ បំណុលកិច្ចសន្យាត្រូវបានគេរំពឹងថា នឹងត្រូវបានទទួលស្គាល់ថាជាប្រាក់ចំណូលនៅពេលបញ្ចប់ការសាងសង់ដូចដែរបានព្រមព្រៀងគ្នា។

ការផ្លាស់ប្តូរសំខាន់ៗ លើបំណុលកិច្ចសន្យាក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៤.២)** | | (កំណត់សម្គាល់ ៤.២) |
| បំណុលកិច្ចសន្យានៅដើមការិយបរិច្ឆេទត្រូវបានទទួលស្គាល់ថាជាចំណូល | **៣៩៦.០៩០** | **១.៦១១.២៩៤** | ១៣៤.១០០ | ៥៤៦.៧២៦ |

## ១៦. ដើមទុន

ភាគហ៊ុនដែលបានអនុម័តឱ្យចេញផ្សាយត្រូវបានចាត់ថ្នាក់ជា ២ចំណាត់ថ្នាក់របស់ក្រុមហ៊ុនដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | |
|---|---|---|---|---|---|---|
| | **ចំនួនហ៊ុន** | | **សមតុល្យ** | ចំនួនហ៊ុន | | សមតុល្យt |
| | | **ដុល្លារអាមេរិក** | **ពាន់រៀល** | | ដុល្លារអាមេរិក | ពាន់រៀល |
| | | | **(កំណត់សម្គាល់ ៤.២)** | | | (កំណត់សម្គាល់ ៤.២) |
| ថ្នាក់ ក មានតម្លៃចារឹក ០.២៥ ដុល្លារអាមេរិកក្នុងមួយហ៊ុន | **១០.០០០.០០០** | **២.៥០០.០០០** | **១០.០០០.០០០** | ១០.០០០.០០០ | ២.៥០០.០០០ | ១០.០០០.០០០ |
| ថ្នាក់ ខ មានតម្លៃចារឹក ០.២៥ ដុល្លារអាមេរិកក្នុងមួយហ៊ុន | **២០.០០០.០០០** | **៥.០០០.០០០** | **២០.០០០.០០០** | ២០.០០០.០០០ | ៥.០០០.០០០ | ២០.០០០.០០០ |
| | **៣០.០០០.០០០** | **៧.៥០០.០០០** | **៣០.០០០.០០០** | ៣០.០០០.០០០ | ៧.៥០០.០០០ | ៣០.០០០.០០០ |

បម្រែបម្រួលដើមទុនដែលបានទូទាត់រួចរាល់មានដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | |
|---|---|---|---|---|---|---|
| | **ចំនួនហ៊ុន** | | **សមតុល្យ** | ចំនួនហ៊ុន | | សមតុល្យt |
| | | **ដុល្លារអាមេរិក** | **ពាន់រៀល** | | ដុល្លារអាមេរិក | ពាន់រៀល |
| | | | **(កំណត់សម្គាល់ ៤.២)** | | | (កំណត់សម្គាល់ ៤.២) |
| នាដើមការិយបរិច្ឆេទ | **១២.០០០.០០០** | **៣.០០០.០០០** | **១២.២២៥.៣០១** | ៥៧០.០០០ | ១៤២.៥០០ | ៥៧៥.២៧៣ |
| ការបន្ថែមដើមទុន | **៦.៤៦១.៥៣៨** | **១.៦១៥.៣៨៥** | **៦.៥៧១.៣៨៦** | ១១.៤៣០.០០០ | ២.៨៥៧.៥០០ | ១១.៦៥០.០២៨ |
| **នាចុងការិយបរិច្ឆេទ** | **១៨.៤៦១.៥៣៨** | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | ១២.០០០.០០០ | ៣.០០០.០០០ | ១២.២២៥.៣០១ |

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងឆ្នាំ២០២០ ព័ត៌មានលម្អិតអំពីការកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៤.២)** | | (កំណត់សម្គាល់ ៤.២) |
| លោក នាង វិធី | **២.១០០.០០០** | **៨.៥៥៦.០០១** | ២.១០០.០០០ | ៨.៥៥៦.០០១ |
| លោកស្រី លឹម មុយលី | **៩០០.០០០** | **៣.៦៦៩.៣០០** | ៩០០.០០០ | ៣.៦៦៩.៣០០ |
| ម្ចាស់ភាគហ៊ុនជាសាធារណៈជន | **១.៦១៥.៣៨៥** | **៦.៥៧១.៣៨៦** | - | - |
| | **៤.៦១៥.៣៨៥** | **១៨.៧៩៦.៦៨៧** | ៣.០០០.០០០ | ១២.២២៥.៣០១ |

### ១៦.១. បុព្វលាភដើមទុន

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១ ក្រុមហ៊ុនបានចុះបញ្ជីដោយជោគជ័យជាមួយផ្សារមូលប័ត្រកម្ពុជា ("CSX")។ ចំនួនហ៊ុនថ្មីដែលបានបោះផ្សាយមាន ៦.៤៦១.៥៣៨ ហ៊ុនជាមួយតម្លៃចារឹក ១.០០០ រៀល (០.២៥ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន ក្នុងតម្លៃលក់ចេញ ២.៣៨០ រៀល (០.៥៨ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន។ ក្រុមហ៊ុនទទួលទឹកប្រាក់ពីការបោះផ្សាយលក់ភាគហ៊ុនជាសាធារណៈលើកដំបូង ("IPO") ក្នុងទំហំទឹកប្រាក់ចំនួន ៣.៧៧៣.៥៣៩ ដុល្លារអាមេរិក ជាលទ្ធផលក្នុងបុព្វលាភភាគហ៊ុនចំនួន ២.១៥៨.១៥៤ ដុល្លារអាមេរិក (៨.៧៧៩.៣៧០.០០០ រៀល)។

## ១៧. ប្រាក់កម្ចី

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| កម្ចីរយៈពេលវែង | ៨១១.៣២០ | ៣.៣០៥.៣១៨ | ១.១៨១.៨២៤ | ៤.៧៨០.៤៧៨ |
| កម្ចីរយៈពេលខ្លី | ២.៥១៩.០១១ | ១០.២៦២.៤៥១ | ៩៦៧.២០៧ | ៣.៩១២.៣៥២ |
| | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ | ២.១៤៩.០៣១ | ៨.៦៩២.៨៣០ |

| | ២០២១ | | ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| **សមតុល្យនៅថ្ងៃទី១ ខែមករា** | ២.១៤៩.០៣១ | ៨.៦៩២.៨៣០ | ២.៣៣៦.៤៧០ | ៩.៥២១.១១៦ |
| ការទិញបន្ថែម | ៨.៤៨៦.៨២១ | ៣៤.៥២៤.៣៨៨ | ៤៧៥.៥៤៣ | ១.៩៣៨.៧៨៩ |
| ការទូទាត់សង | (៧.៣០៥.៥២១) | (២៩.៧១៨.៨៥៩) | (៦៦២.៩៨២) | (២.៧០២.៩៧៨) |
| សេវាការប្រាក់ | ៤៩៩.៧៦០ | ២.០៣៣.០២៣ | ៣៥៦.៨៩៨ | ១.៤៥៥.០៧៣ |
| ការប្រាក់ដែលបានទូទាត់ | (៤៩៩.៧៦០) | (២.០៣៣.០២៣) | (៣៥៦.៨៩៨) | (១.៤៥៥.០៧៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៦៩.៤១០ | - | (៦៤.០៩៧) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ** | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ | ២.១៤៩.០៣១ | ៨.៦៩២.៨៣០ |

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| **តាមកាលបរិច្ឆេទកំណត់** | | | | |
| ក្នុងអំឡុងពេលមួយឆ្នាំ | ២.៥១៩.០១១ | ១០.២៦២.៤៥១ | ៩៦៧.២០៧ | ៣.៩១២.៣៥២ |
| ពី២ឆ្នាំ ទៅ ៥ឆ្នាំ | ៨១១.៣២០ | ៣.៣០៥.៣១៨ | ១.១៣៤.៣៥១ | ៤.៥៨៨.៤៥០ |
| ច្រើនជាង ៥ឆ្នាំ | - | - | ៤៧.៤៧៣ | ១៩២.០២៨ |
| | ៣.៣៣០.៣៣១ | ១៣.៥៦៧.៧៦៩ | ២.១៤៩.០៣១ | ៨.៦៩២.៨៣០ |

## ១៧. ប្រាក់កម្ចី (ត)

| | ឆ្នាំ២០២១ | | ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **តាមស្ថានភាពទ្រព្យធានា៖** | | | | |
| កម្ចីដែលមានទ្រព្យបញ្ចាំ | **២.៧៥៤.៤៥០** | **១១.២២១.៦២៩** | ១.៣៨៤.០១៦ | ៦.១៩៤.១១៣ |
| កម្ចីដែលគ្មានទ្រព្យបញ្ចាំ | **៥៧៥.៨៨១** | **២.៣៤៦.១៤០** | ៧៦៥.០១៥ | ២.៤៩៨.៧១៧ |
| | **៣.៣៣០.៣៣១** | **១៣.៥៦៧.७៦៩** | ២.១៤៩.០៣១ | ៨.៦៩២.៨៣០ |
| **តាមប្រភេទរូបិយប័ណ្ណ៖** | | | | |
| ដុល្លារអាមេរិក | **៣.៣៣០.៣៣១** | **១៣.៥៦៧.៧៦៩** | ២.១៤៩.០៣១ | ៨.៦៩២.៨៣០ |
| ខ្មែររៀល | **-** | **-** | - | - |
| | **៣.៣៣០.៣៣១** | **១៣.៥៦៧.៧៦៩** | ២.១៤៩.០៣១ | ៨.៦៩២.៨៣០ |
| **តាមទំនាក់ទំនង៖** | | | | |
| មិនមែនជាភាគីពាក់ព័ន្ធ | **៣.៣៣០.៣៣១** | **១៣.៥៦៧.៧៦៩** | ១.៥៣១.៣០១ | ២.៤៩៨.៧១៧ |
| ភាគីពាក់ព័ន្ធ | **-** | **-** | ៦១៧.៧៣០ | ៦.១៩៤.១១៣ |
| | **៣.៣៣០.៣៣១** | **១៣.៥៦៧.៧៦៩** | ២.១៤៩.០៣១ | ៨.៦៩២.៨៣០ |
| **តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖** | | | | |
| កាលកំណត់ឥណទាន | | **១% ទៅ ៩%** | | ១% ទៅ ៩% |

## ១៨. ឥណទានវិបារូបណ៍

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ធនាគារវឌ្ឍនៈអាស៊ីចំកាត់ | **១.២១៨.៨៥៤** | **៤.៩៦៥.៦១១** | ១.១៣១.៩៩៤ | ៤.៥៧៨.៩១៦ |
| ធនាគារជីប ម៉ុង ខមមើសល ប៊ែង ម.ក | **៣៨៣.៧៩៨** | **១.៥៦៣.៥៩៣** | ៣៥១.៧៦៤ | ១.៤២២.៨៨៥ |
| ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ | **២៦៨.៤៦០** | **១.០៩៣.៧០៦** | ២៤០.៨៣៤ | ៩៧៤.១៧៤ |
| | **១.៨៧១.១១២** | **៧.៦២២.៩១០** | ១.៧២៤.៥៩២ | ៦.៩៧៥.៩៧៥ |

ឥណទានវិបារូបណ៍ជាមួយធនាគារវឌ្ឍនៈអាស៊ីចំកាត់ មានអត្រាការប្រាក់ ៨%ក្នុងមួយឆ្នាំ និងត្រូវបានធានាដោយការបញ្ចាំដីឡូត៍ របស់ក្រុមហ៊ុនដែលបានកត់ត្រាជាទ្រព្យសម្បត្តិ និងបរិក្ខារ ដែលមានតម្លៃ ២.១៦៧.៦២០ ដុល្លារអាមេរិក ព្រមទាំងទ្រព្យសម្បត្តិរបស់ម្ចាស់ភាគហ៊ុន និងបុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ។ កិច្ចសន្យាត្រូវបានចុះហត្ថលេខាដោយលោក នាង វិធី និងលោកស្រី លឹម មុយលី ដែលជាតំណាងឱ្យក្រុមហ៊ុននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ដែលមានទឹកប្រាក់កំណត់ចំនួន ១.៣០០.០០០ ដុល្លារអាមេរិក ដែលត្រូវទូទាត់ក្នុងរយៈពេល១២ខែគិតចាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យា។ ក្នុងអំឡុងការិយបរិច្ឆេទបច្ចុប្បន្ន ឥណទានវិបារូបណ៍ត្រូវបានបន្តដោយស្វ័យប្រវត្តិសម្រាប់ការិយបរិច្ឆេទបន្ទាប់ទៀត។

ឥណទានវិបារូបណ៍ជាមួយធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក មានអត្រាការប្រាក់ ៩%ក្នុងមួយឆ្នាំដែលមិនមានទ្រព្យធានាឡើយ។ កិច្ចព្រមព្រៀងត្រូវបានធ្វើឡើងវិញនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ដែលមានចំនួនទឹកប្រាក់កំណត់ចំនួន ៤០០.០០០ ដុល្លារអាមេរិក និងមានកាលបរិច្ឆេទកំណត់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១។ ក្នុងអំឡុងការិយបរិច្ឆេទនេះ ឥណទានវិបារូបណ៍ត្រូវបានរៀបចំឡើងវិញសម្រាប់ការិយបរិច្ឆេទថ្មី។

ឥណទានវិបារូបណ៍ជាមួយធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ មានអត្រាការប្រាក់ ៨%ក្នុងមួយឆ្នាំដែលត្រូវបានធានាដោយទ្រព្យសម្បត្តិរបស់ម្ចាស់ភាគហ៊ុន និងបុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ។ កិច្ចព្រមព្រៀងត្រូវបានធ្វើឡើងវិញនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ ដែលមានចំនួនទឹកប្រាក់កំណត់ចំនួន ៦០០.០០០ ដុល្លារអាមេរិក និងមានកាលបរិច្ឆេទកំណត់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១។

## ១៩. គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| គណនីត្រូវសង | ៦៦៨.៦៧៧ | ២.៧២៤.១៩០ | ៤៨៩.៦៣៣ | ១.៩៨០.៥៦៥ |
| ចំណាយបង្ករ | ៦៦៦.០៦៨ | ២.៧១៣.៥៦១ | ៧.៩៣៥ | ៣២.០៩៧ |
| ពន្ធផ្សេងៗត្រូវបង់ | ២៧៥.៩២៣ | ១.១២៤.១១១ | ១៣២.១០១ | ៥៣៤.៣៨៩ |
| ប្រាក់បៀវត្សត្រូវបង់ | ១៨១.០៨២ | ៧៣៧.៧២៨ | - | - |
| គណនីត្រូវសងបង្ករទុក | ៣១.៦២៥ | ១២៨.៨៤០ | ៥៩.៦៥៦ | ២៤១.៣០៩ |
| បំណុលបច្ចុប្បន្នផ្សេងៗ | ៧.៨៤០ | ៣១.៩៤០ | ៧.៨៤៣ | ៣១.៧២៦ |
| | ១.៨៣១.២១៥ | ៧.៤៦០.៣៧០ | ៦៩៧.១៦៨ | ២.៨២០.០៤៦ |

គណនីត្រូវសងបង្ករទុកដែលពាក់ព័ន្ធទៅនឹងចំនួនទឹកប្រាក់ដែលក្រុមហ៊ុនបានជំពាក់ក្រុមហ៊ុនម៉ៅការបន្តរ។ ក្រុមហ៊ុននឹងទូទាត់គណនីត្រូវសងបង្ករទុកចំនួន ៥០% នៅពេលដែលកិច្ចសន្យាដែលពាក់ព័ន្ធត្រូវបានបញ្ចប់ ហើយ ៥០%ទៀតនឹងត្រូវទូទាត់នៅចុងបញ្ចប់នៃកាលបរិច្ឆេទនៃការធានា ដែលជាធម្មតាមានរយៈពេលចាប់ពី ៣០ថ្ងៃទៅ ១៨០ថ្ងៃ។

## ២០. ចំណូល

| | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| សេវាកម្មសាងសង់ និងសេវាកម្មថែទាំ | ១៧.៥៦៦.៧៩០ | ៧១.៤៦១.៧០២ | ១៣.០៧១.៥០៧ | ៥៣.២៩២.៥៣៤ |
| លក់ទំនិញ | ៣៩៧.៤៣៨ | ១.៦១៦.៧៧៨ | ៣៩១.៦៨១ | ១.៥៩៦.៨៨៣ |
| | ១៧.៩៦៤.២២៨ | ៧៣.០៧៨.៤៨០ | ១៣.៤៦៣.១៨៨ | ៥៤.៨៨៩.៤១៧ |

## ២១. ថ្លៃដើមទំនិញ និងសេវាកម្ម

| | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| ថ្លៃដើមក្នុងការសាងសង់ និងសេវាកម្មថែទាំ | ១៥.០២៦.០០៦ | ៦១.១២៥.៧៩៣ | ១០.៨០៩.១៦៣ | ៤៤.០៦៨.៩៥៧ |
| ថ្លៃដើមទំនិញ | ៣៨៣.៤០៤ | ១.៥៥៩.៦៨៧ | ៣៩៤.៩៧១ | ១.៦១០.២៩៧ |
| | ១៥.៤០៩.៤១០ | ៦២.៦៨៥.៤៨០ | ១១.២០៤.១៣៤ | ៤៥.៦៧៩.២៥៤ |

## ២២. ចំណាយប្រតិបត្តិការ

| | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ចំណាយបុគ្គលិក | **៥០៦.២៧៦** | **២.០៥៩.៥៣១** | ៣២២.៩៩៣ | ១.៣១៦.៨៤២ |
| សេវាវិជ្ជាជីវៈ | **២៥៨.៣៧៧** | **១.០៥១.០៧៨** | ៦២.៦៦៥ | ២៥៥.៤៨៥ |
| ពន្ធផ្សេងៗ | **១៧៧.២៧១** | **៧២១.១៣៨** | ២៤០.៩៣១ | ៩៨២.២៧៦ |
| សម្ភារៈការិយាល័យ និងឧបករណ៍ការិយាល័យ | **១១៥.៦៥០** | **៤៧០.៤៦៤** | ៨០.៥១០ | ៣២៨.២៣៩ |
| សេវាធនាគារ | **១១៣.៧៧០** | **៤៦២.៨១៦** | ១១០.៥៧៣ | ៤៥០.៨០៦ |
| រំលស់ | **៧៣.៤៣៧** | **២៩៨.៧៤២** | ៨០.៤៧៧ | ៣២៨.១០៥ |
| ទឹកភ្លើង | **៧០.៥៩៦** | **២៨៧.១៨៥** | ៦០.៣៧២ | ២៤៦.១៣៧ |
| ធានារ៉ាប់រង | **៦៥.២១០** | **២៦៥.២៧៤** | ៦៣.៨៥៥ | ២៦០.៥០០ |
| ជួសជុល និងថែទាំ | **៤៦.៤៦៥** | **១៨៩.០២០** | ៥៤.៥២៤ | ២២២.២៩៤ |
| ការជួល | **១៧.២៣៨** | **៧០.១២៤** | ១៨.១៦៩ | ៧៤.០៧៥ |
| ទំនាក់ទំនង | **៨.៦១៥** | **៣៥.០៤៦** | ៦.៩០២ | ២៨.១៣៩ |
| ការកំសាន្ត | **៧.១៥៣** | **២៩.០៩៨** | ៥.៥០០ | ២២.៤២៤ |
| ការកែតម្រូវលើសន្និធិ | **៥.៦៨៦** | **២៣.១៣១** | ២១៤.៨៦៥ | ៨៧៦.០០៥ |
| ការធ្វើដំណើរ | - | - | ៤៣១ | ១.៧៥៧ |
| ចំណាយផ្សេងៗ | **១៧.៨៣១** | **៧២.៥៣៦** | ១៧៥.៥២០ | ៧១៥.៥៩៥ |
| | **១.៤៨៣.៥៧៥** | **៦.០៣៥.១៨៣** | **១.៤៩៨.៣២៧** | **៦.១០៨.៦៧៩** |

## ២៣. ចំណូលផ្សេងៗ

| | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ចំណូលការប្រាក់ | **៧.៣២០** | **២៩.៧៧៨** | ៤៩.២២១ | ២០០.៦៧៤ |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | **៣.៣៧៣** | **១៣.៧២១** | ៨២ | ៣៣៤ |
| ខាតបង់ពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ និង ទ្រព្យសកម្មអរូបី | **(១.៨២០)** | **(៧.៤០៤)** | (៩១៤) | (៣.៧២៦) |
| ចំណូលផ្សេងៗ | **១៩.១៩០** | **៧៨.០៦៥** | ៥.២៤២ | ២១.៣៧២ |
| | **២៨.០៦៣** | **១១៤.១៦០** | ៥៣.៦៣១ | ២១៨.៦៥៤ |

## ២៤. បន្ទុកហិរញ្ញប្បទាន

| | **សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ការប្រាក់លើប្រាក់កម្ចី | **៤៩៩.៧៦០** | **២.០៣៣.០២៤** | ៣៥៦.៨៩៨ | ១.៤៥៥.០៧៣ |
| ការប្រាក់លើបំណុលភតិសន្យា | **៧.១១០** | **២៨.៩២៣** | ១២.៥៧៧ | ៥១.២៧៧ |
| | **៥០៦.៨៧០** | **២.០៦១.៩៤៧** | ៣៦៩.៤៧៥ | ១.៥០៦.៣៥០ |

## ២៥. ពន្ធលើប្រាក់ចំណូល

ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលចំនួន ២០% នៃប្រាក់ចំណូលជាប់ពន្ធ ឬពន្ធអប្បបរមា ១% នៃចំណូលប្រចាំឆ្នាំយកតម្លៃមួយណាដែលខ្ពស់ជាង។ ពន្ធអប្បបរមា គឺជាពន្ធប្រចាំឆ្នាំដែលមានការទទួលខុសត្រូវស្មើនឹង ១% នៃប្រាក់ចំណូលដុល។

### ២៥.១. ចំណាយពន្ធលើប្រាក់ចំណូល

ការកែតម្រូវរវាងគណនេយ្យប្រាក់ចំណេញមុនពន្ធលើប្រាក់ចំណូល និងប្រាក់ចំណូលជាប់ពន្ធដែលបានប៉ាន់ស្មានសម្រាប់ការិយបរិច្ឆេទដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងឆ្នាំ២០២០ ត្រូវបានបង្ហាញដូចខាងក្រោម៖

| | **សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| គណនីប្រាក់ចំណេញមុនបង់ពន្ធ | **៥៩២.៤៣៦** | **២.៤១០.០៣០** | ៤៤៤.៨៨៣ | ១.៨១៣.៧៨៨ |
| **និយ័តកម្ម៖** | | | | |
| ភាពខុសគ្នាជាអចិន្ត្រៃយ៍ | **(៣៥.៩៣៥)** | **(១៤៦.១៨៤)** | ៣៦៦.៦១៤ | ១.៤៩៤.៦៨៧ |
| ប្រាក់ឧបត្ថមពន្ធ | **(៥៥៦.៥០១)** | **(២.២៦៣.៨៤៦)** | (១១១.៤៩១) | (៤៥៤.៥៤៧) |
| ពន្ធលើប្រាក់ចំណូលបានប៉ាន់ស្មាន | - | - | ៧០០.០០៦ | ២.៨៥៣.៩២៨ |
| ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០% | - | - | ១៤០.០០១ | ៥៧០.៧៨៤ |
| ពន្ធអប្បបរមាក្នុងអត្រា ១% នៃប្រាក់ចំណូល | **១៧៩.៧៥៤** | **៧៣១.២៣៩** | ១១៦.៣៦៥ | ៤៧៤.៤២០ |
| **ការប៉ាន់ស្មានការចំណាយពន្ធលើប្រាក់ចំណូល បច្ចុប្បន្ន** | **១៧៩.៧៥៤** | **៧៣១.២៣៩** | ១៤០.០០១ | ៥៧០.៧៨៤ |

ការប្រកាសពន្ធរបស់ក្រុមហ៊ុនអាចនឹង ត្រូវត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ។ ដោយសារតែការអនុវត្ត និងការតាក់តែងច្បាប់ពន្ធមានច្រើនប្រភេទ ហើយងាយនឹងបកស្រាយខុស ដូច្នេះចំនួនដែលបានកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ អាចនឹងមានការផ្លាស់ប្តូរនាពេលបន្ទាប់នៅពេលដែលអាជ្ញាធរពន្ធដារបានធ្វើការត្រួតពិនិត្យ។

### ២៥.២. យថាភាពលើពន្ធ

ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា មានសភាពថ្មីហើយត្រូវបានបែងចែកជាច្រើនប្រភេទ និងបទបញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ ដែលជាធម្មតាពុំមានភាពច្បាស់លាស់ មានភាពផ្ទុយគ្នា និងពឹងផ្អែកនៃការបកស្រាយ។ ជាញឹកញាប់ ការបកស្រាយខុសគ្នាៗជាច្រើនទៅកើតមាននោះឡើងក្នុងចំនោមអាជ្ញាធរពន្ធដារ និងយុត្តាធិការ។ ពន្ធដារ គឺជាកម្មវត្ថុនៃការពិនិត្យឡើងវិញ និងការសង្កេតដោយភ្នាក់ងារពន្ធដារផ្សេងៗជាច្រើន ដែលមានសមត្ថកិច្ចក្នុងការដាកពិន័យធ្ងន់ធ្ងរ និងពិន័យលើការប្រាក់។

កត្តាទាំងនេះហើយដែលអាចធ្វើឱ្យមានហានិភ័យពន្ធដារនៅក្នុង ព្រះរាជាណាចក្រកម្ពុជាខ្លាំងជាងប្រទេសដទៃទៀត។ គណៈគ្រប់គ្រងមានការជឿជាក់ថា ខ្លួនបានធ្វើសំវិធានធនបំណុលពន្ធគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទបញ្ញត្តិពន្ធរបស់ខ្លួន។ ទោះបីយ៉ាងនេះក្តី សមត្ថកិច្ចពន្ធពាក់ព័ន្ធអាចការបកស្រាយខុសៗគ្នា ហើយអាចធ្វើឱ្យមានផលប៉ះពាល់ជាសារវន្តចាប់តាំងពីពេលដែលក្រុមហ៊ុនចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម។

### ២៥.៣. ពន្ធលើប្រាក់ចំណូលត្រូវបង់

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **សមតុល្យដើមគ្រា** | **២៧.៩៦៥** | **១១៣.១១៨** | - | - |
| ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | **១៧៩.៧៥៤** | **៧៣១.២៣៩** | ១៤០.០០១ | ៥៧០.៧៨៤ |
| ពន្ធលើប្រាក់ចំណូលដែលបានទូទាត់ | **(១៧២.៩៤៣)** | **(៧០៣.៥៣២)** | (១១២.០៣៦) | (៤៥៦.៧៧១) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | **៨៥២** | - | (៨៩៥) |
| **បំណុលពន្ធលើប្រាក់ចំណូល** | **៣៤.៧៧៦** | **១៤១.៦៧៧** | ២៧.៩៦៥ | ១១៣.១១៨ |

## ២៦. សមតុល្យ និងប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ

ខាងក្រោមនេះ គឺជាសមតុល្យដែលនៅជំពាក់របស់ភាគីពាក់ព័ន្ធ៖

| **ភាគីសម្ព័ន្ធញាត្តិ** | **ទំនាក់ទំនង** | **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **សមតុល្យត្រូវទទួល/ត្រូវសងទៅម្ចាស់ភាគហ៊ុន** | | | | | |
| លោក នាង វិធី | ភាគទុននិក | **១៣៤.៤២១** | **៥៤៧.៦៣១** | (៥.៦៤២) | (២២.៨២២) |

សមតុល្យត្រូវសងទៅ/ត្រូវទទួលពីម្ចាស់ភាគហ៊ុន គឺមិនមានទ្រព្យធានា គ្មានការប្រាក់ និងការទូទាត់សងតាមតម្រូវការ។

## ២៦. សមតុល្យ និងប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ (ត)

ក្នុងអំឡុងការិយបរិច្ឆេទ ប្រតិបត្តិការជាមួយភាគទុនិកត្រូវបានកត់ត្រាដូចខាងក្រោម៖

| ភាគីសម្ព័ន្ធញាត្តិ | ទំនាក់ទំនង | **សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|---|
| | | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| លោក នាង វិធី | ការទូទាត់ជំនួសភាគទុនិក | **៧៤៧.៨៧៩** | **៣.០៤២.៣៧២** | - | - |
| | ការទូទាត់សងពីម្ចាស់ភាគហ៊ុន | **(៧០៥.៨៧៩)** | **(២.៨៧១.៥១៦)** | - | - |
| | ការទូទាត់ជំនួសឱ្យក្រុមហ៊ុន | **(៣៣.៥៤៨)** | **(១៣៦.៤៧៣)** | - | - |
| | ការទូទាត់សងទៅម្ចាស់ភាគហ៊ុន | **១៣១.៦១១** | **៥៣៥.៣៩៤** | - | - |
| | កាត់កងជាមួយសមតុល្យត្រូវទទួលពី/ត្រូវសងទៅម្ចាស់ភាគហ៊ុន | **-** | **-** | ២៧.៤៣២ | ១១១.៨៤០ |

## ២៧. ប្រតិបត្តិការទាក់ទងនឹងបុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ

បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ ត្រូវបានគេស្គាល់ថាជាបុគ្គលទាំងឡាយណាដែលមានសិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យសកម្មភាពរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោល។ គណៈគ្រប់គ្រងសំខាន់ៗ រួមមានប្រធានក្រុមប្រឹក្សាភិបាលជាដើម។

| | **សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ប្រាក់ខែ និងអត្ថប្រយោជន៍បន្ថែម | **១៧១.១៥០** | **៦៩៦.២៣៨** | ៦៤.០០០ | ២៦០.៩២៨ |

## ២៨. កិច្ចសន្យា

នៅការិយបរិច្ឆេទនៃរបាយការណ៍ ក្រុមហ៊ុនមានការសន្យាភតិសន្យាជួល ក្រោមលក្ខខណ្ឌការសន្យាដែលមិនអាចលុបចោលបាន សម្រាប់ការជួលអគារអន្តេវាសិកដ្ឋាន ក្រោមការរៀបចំកិច្ចសន្យាជួលប្រតិបត្តិការ។

ព័ត៌មានលម្អិតនៃការទូទាត់ភតិសន្យាអប្បបរមា នាពេលអនាគតដែលទាក់ទងនឹងការជួលបន្ទប់ស្នាក់នៅត្រូវបានសង្ខេបដូចខាងក្រោម៖

| | **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៤.២)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| ក្នុងអំឡុងពេលមួយឆ្នាំ | ១១.៨៨០ | ៤៨.៣២៨ | ១៤.១០០ | ៥៧.៤៨៦ |
| ចន្លោះរវាងពី ២ឆ្នាំ ទៅ៥ ឆ្នាំ | - | - | ១៦.១៧៥ | ៦៥.៩៤៥ |
| ច្រើនជាង ៥ឆ្នាំ | - | - | - | - |
| | ១១.៨៨០ | ៤៨.៣២៨ | ៣០.២៧៥ | ១២៣.៤៣១ |

## ២៩. ការធ្វើចំណាត់ថ្នាក់នៅលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែង តាមថ្លៃដើមបានរំលស់** | | | | |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | **២០.០៥០** | **៨១.៦៨៤** | ៥៩.០៥០ | ២៣៨.៨៥៧ |
| ប្រាក់តម្កល់ធានា | **៦៥.០០០** | **២៦៤.៨១០** | ២១០.៥៤៥ | ៨៥១.៦៥៥ |
| សមតុល្យត្រូវសងទៅម្ចាស់ភាគហ៊ុន | **១៣៤.៤២១** | **៥៤៧.៦៣១** | - | - |
| គណនីពាណិជ្ជដែលត្រូវទទួល | **៦.២៧៣.០៥៧** | **២៥.៥៥៦.៤៣៤** | ១.៤៨៧.២១៩ | ៦.០១៥.៨០១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | **២២៥.១១៩** | **៩១៧.១៣៥** | ២៨៣.១២៤ | ១.១៤៥.២៣៧ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | **៦.៧១៧.៦៤៧** | **២៧.៣៦៧.៦៩៤** | ២.០៣៩.៩៣៨ | ៨.២៥១.៥៥០ |

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | (កំណត់សម្គាល់ ៤.២) | | (កំណត់សម្គាល់ ៤.២) |
| **បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែង តាមថ្លៃដើមបានរំលស់** | | | | |
| ប្រាក់កម្ចី | **៣.៣៣០.៣៣១** | **១៣.៥៦៧.៧៦៩** | ២.១៤៩.០៣១ | ៨.៦៩២.៨៣០ |
| បំណុលភតិសន្យា | **៤៨.៥០៩** | **១៩៧.៦២៦** | ១០៨.៦០០ | ៤៣៩.២៨៧ |
| ឥណទានវិបារូបណ៍ | **១.៨៧១.១១២** | **៧.៦២២.៩១០** | ១.៧២៤.៥៩២ | ៦.៩៧៥.៩៧៥ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេង* | **១.៥៥៥.២៩២** | **៦.៣៣៦.២៥៩** | ៥៦៥.០៦៧ | ២.២៨៥.៦៩៧ |
| សមតុល្យត្រូវសងទៅម្ចាស់ភាគហ៊ុន | - | - | ៥.៦៤២ | ២២.៨២២ |
| **បំណុលហិរញ្ញវត្ថុសរុប** | **៦.៨០៥.២៤៤** | **២៧.៧២៤.៥៦៤** | ៤.៥៥២.៩៣២ | ១៨.៤១៦.៦១១ |

** លើកលែងពន្ធផ្សេងៗដែលត្រូវបង់ និងបុរេប្រទានពីអតិថិជន*

## ៣០. គោលបំណង និងគោលនយោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

*ហានិភ័យហិរញ្ញវត្ថុ*

ក្រុមហ៊ុនត្រូវប្រឈមនឹងហានិភ័យហិរញ្ញវត្ថុដែលកើតឡើងពីប្រតិបត្តិការអាជីវកម្ម និងការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ។ គោលនយោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដើម្បីធានាថាមានធនធានគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍអាជីវកម្មរបស់ក្រុមហ៊ុនខណៈការគ្រប់គ្រងហានិភ័យឥណទាន ហានិភ័យលទ្ធភាពទូទាត់សងបំណុល ហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យអត្រាការប្រាក់។ ក្រុមហ៊ុនដំណើរគោលនយោបាយ និងនីតិវិធីដែលបានកំណត់យ៉ាងច្បាស់ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលដើម្បីធានាប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងហានិភ័យ។

ផ្នែកសំខាន់ៗនៃហានិភ័យហិរញ្ញវត្ថុដែលក្រុមហ៊ុនប្រឈម ហើយគោលនយោបាយដែលជាចំណុចសំខាន់នៃសកម្មភាពរតនាគារ ដែលបានកំណត់បង្ហាញដូចខាងក្រោម៖

### (ក). ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនប្រសិនបើអតិថិជន ឬដៃគូសហការជាមួយឧបករណ៍ហិរញ្ញវត្ថុខកខានមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យា។ វាជាគោលនយោបាយរបស់ក្រុមហ៊ុន ក្នុងការបញ្ចូលឧបករណ៍ហិរញ្ញវត្ថុជាមួយសមភាគីដែលទទួលបានឥណទាន។ ក្រុមហ៊ុនមិនរំពឹងថានឹងជួបប្រទះនូវការខាតបង់ឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតឡើយ។

ការផ្តោតសំខាន់ទៅលើហានិភ័យឥណទាន មាននៅពេលដែលការផ្លាស់ប្តូរកត្តាសេដ្ឋកិច្ច ឧស្សាហកម្ម និងភូមិសាស្ត្រជះឥទ្ធិពលដល់ក្រុមដៃគូដែលមានហានិភ័យឥណទាន សរុបទាក់ទងនឹងហានិភ័យឥណទានសរុបរបស់ក្រុមហ៊ុន។ ប្រតិបត្តិការរបស់ក្រុមហ៊ុនត្រូវបានចូលរួមជាមួយសមភាគី ដែលគួរឱ្យកត់សម្គាល់ដោយកាត់បន្ថយការប្រមូលផ្តុំហានិភ័យឥណទាន។

កត្តាដែលបណ្តាលឱ្យក្រុមហ៊ុនអាចប្រឈមនឹងហានិភ័យឥណទានមានដូចខាងក្រោម៖

***<u>គណនីពាណិជ្ជកម្មដែលត្រូវទទួល</u>***

ក្រុមហ៊ុនបានអនុម័តដាក់ឱ្យប្រើប្រាស់ ស.ទ.រ ហ.អ.ក ៩ ជាគំរូសាមញ្ញក្នុងការបង្ហាញពីការរំពឹងទុកនៃទទួលស្គាល់អាយុកាលនៃការខាតបង់ឥណទាន សម្រាប់រាល់គណនីពាណិជ្ជកម្មដែលត្រូវទទួល ដោយសារមិនមានសមាសធាតុហិរញ្ញប្បទានគួរអោយគត់សម្គាល់ណាមួយកើតមានឡើង។

ក្នុងការវាស់ស្ទង់ការខាតបង់ឥណទានដែលរំពឹងទុក ការទទួលបានត្រូវបានវាយតម្លៃជាសមូហភាពនៅពេលដែលពួកគេមានលក្ខណៈហានិភ័យឥណទានរួមគ្នា។

អត្រានៃការខាតបង់ដែលបានរំពឹងទុក គឺផ្អែកទៅលើការខាតបង់ឥណទានប្រវត្តិសាស្ត្ររយៈពេល ៣ឆ្នាំកន្លងមកមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ក៏ដូចជាការខាតបង់ឥណទានប្រវត្តិសាស្ត្រក្នុងអំឡុងការិយបរិច្ឆេទ។ អត្រាប្រវត្តិសាស្ត្រត្រូវបានកែតម្រូវ ដើម្បីឆ្លុះបញ្ចាំងពីកត្តា ម៉ាក្រូសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងនាពេលខាងមុខ ដែលជះឥទ្ធិពលដល់សមត្ថភាពរបស់អតិថិជនក្នុងការទូទាត់ត្រឡប់វិញនូវសមតុល្យទឹកប្រាក់ដែលនៅសល់។ ការប្រឈមនឹងហានិភ័យឥណទានរយៈពេលខ្លី ផលប៉ះពាល់នៃកត្តាម៉ាក្រូសេដ្ឋកិច្ច មិនត្រូវបានចាត់ទុកជាកត្តាគួរឱ្យកត់សម្គាល់នៅក្នុងការិយបរិច្ឆេទនៃរបាយការណ៍នោះទេ។

គណនីពាណិជ្ជដែលត្រូវទទួលត្រូវបានលុបចោល (ឧទាហរណ៍៖ មិនមានការទទួលស្គាល់) នៅពេលដែលគ្មានការរំពឹងទុកដ៏សមហេតុផលណានៃទទួលស្គាល់ឡើងវិញ។ ការខកខានក្នុងការបង់ប្រាក់ក្នុងរយៈពេល ១៨០ថ្ងៃ គិតចាប់ពីថ្ងៃចេញវិក័យបត្រ និងការខកខានមិនបានចូលរួមជាមួយក្រុមហ៊ុនទៅលើការទូទាត់ជំនួសក្នុងចំណោមមធ្យោបាយផ្សេងទៀតត្រូវបានចាត់ទុកថាជាសូចនាករដែលមិនមានការរំពឹងទុកសមហេតុសមផល។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងឆ្នាំ២០២០ គណៈគ្រប់គ្រងមានទស្សនៈថាគណនីពាណិជ្ជដែលត្រូវទទួល ត្រូវបានវាយតម្លៃថាមានហានិភ័យឥណទានទាបដែលអាចកំណត់ថាការខាតបង់ឱនភាពតម្លៃត្រូវបានចាត់ទុកជាសារវន្ត។

***<u>សាច់ប្រាក់ និងសាច់ប្រាក់សមមូល</u>***

ហានិភ័យឥណទានទៅលើសាច់ប្រាក់ និងសាច់ប្រាក់សមមូល និងសាច់ដំកល់ទុករយៈពេលខ្លីត្រូវបានចាត់ទុកថាជាការធ្វេសប្រហែសដោយសារតែសមភាគី គឺជាធនាគារក្នុងស្រុកដែលល្បីឈ្មោះ។

### (ខ). ហានិភ័យលទ្ធភាពទូទាត់សងបំណុល

លទ្ធភាពទូទាត់សងបំណុល គឺជាហានិភ័យមូលនិធិដែលសហគ្រាស ជួបការលំបាកក្នុងការរៃអង្គាសថវិកាដើម្បីបំពេញការសន្យារបស់ក្រុមហ៊ុន ជាមួយនឹងឧបករណ៍ហិរញ្ញវត្ថុ។ ហានិភ័យលទ្ធភាពទូទាត់សងបំណុលអាចលទ្ធផលនៃភាពអសមត្ថភាពក្នុងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅក្នុងតម្លៃសមស្របៗ គោលនយោបាយរបស់ក្រុមហ៊ុន គឺដើម្បីត្រួតពិនិត្យជាប្រចាំនូវតម្រូវការសាច់ប្រាក់បច្ចុប្បន្ន និងលទ្ធភាពទូទាត់សងបំណុលដែលបានរំពឹងទុក ដើម្បីធានាបានថាខ្លួនអាចរក្សាសាច់ប្រាក់បម្រុងបានគ្រប់គ្រាន់ក្នុងការបំពេញនូវតម្រូវការសាច់ប្រាក់រយៈពេលខ្លី និង រយៈពេលវែងរបស់ខ្លួនបាន។

ហានិភ័យលទ្ធភាពទូទាត់សងបំណុល ជាទូទៅកើតឡើងពីប្រាក់កម្ចី បំណុលភតិសន្យា ឥណទានរូបារូបណ៍ គណនីពាណិជ្ជកម្ម និងបំណុលផ្សេងទៀត រួមទាំងសមតុល្យជំពាក់ភាគទុននិក។

### *ការវិភាគទៅលើឧបករណ៍ហិរញ្ញវត្ថុដោយការិយបរិច្ឆេទនៃកិច្ចសន្យា*

តារាងខាងក្រោមបង្ហាញនូវការវិភាគអំពី បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនតាមរយៈក្រុមនៃបំណុលដែលដល់អាយុកាលកំណត់។ ចំនួនទឹកប្រាក់ជាសមតុល្យដុល និងមិនមានបញ្ចុះតម្លៃ និងរួមបញ្ចូលទាំងការទូទាត់ការប្រាក់តាមកិច្ចសន្យា និងមិនរាប់បញ្ចូលនូវផលប៉ះពាល់នៃកិច្ចព្រមព្រៀងជាក់ស្តែង។

| | **បច្ចុប្បន្ន ដុល្លារអាមេរិក** | **ច្រើនជាង ៣០ ថ្ងៃ ដុល្លារអាមេរិក** | **ច្រើនជាង ៩០ ថ្ងៃ ដុល្លារអាមេរិក** | **ច្រើនជាង ១ឆ្នាំ ដុល្លារអាមេរិក** | **លើសពី ៥ឆ្នាំ ដុល្លារអាមេរិក** | **សរុប ដុល្លារអាមេរិក** |
|---|---|---|---|---|---|---|
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** | | | | | | |
| **បំណុលហិរញ្ញវត្ថុ** | | | | | | |
| ប្រាក់កម្ចី | **៣៦៧.៧៣០** | **១.៧៤៣.៥២០** | **៤០៧.៧៦១** | **៨១១.៣២០** | **-** | **៣.៣៣០.៣៣១** |
| បំណុលភតិសន្យា* | **៥.៦០០** | **១៦.៨០០** | **២៨.០០០** | **-** | **-** | **៥០.៤០០** |
| ឥណទានវិបារូបណ៍ | **១.៨៧១.១១២** | **-** | **-** | **-** | **-** | **១.៨៧១.១១២** |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ** | **១.៥៥៥.២៩២** | **-** | **-** | **-** | **-** | **១.៥៥៥.២៩២** |
| សមតុល្យត្រូវសងទៅម្ចាស់ភាគហ៊ុន | **-** | **-** | **-** | **-** | **-** | **-** |
| **បំណុលហិរញ្ញវត្ថុសរុប** | **៣.៧៩៩.៧៣៤** | **១.៧៦០.៣២០** | **៤៣៥.៧៦១** | **៨១១.៣២០** | **-** | **៦.៨០៧.១៣៥** |
| **សមតុល្យជាពាន់រៀល (សម្គាល់ ៤.២)** | **១៥.៤៨០.១១៦** | **៧.១៧១.៥៤៤** | **១.៧៧៥.២៩០** | **៣.៣០៥.៣១៨** | **-** | **២៧.៧៣២.២៦៨** |

**មុនដកបន្ទុកហិរញ្ញប្បទាន*
***លើកលែងពន្ធផ្សេងៗដែលត្រូវបង់ និងបុរេប្រទានពីអតិថិជន*

| | បច្ចុប្បន្ន ដុល្លារអាមេរិក | ច្រើនជាង ៣០ ថ្ងៃ ដុល្លារអាមេរិក | ច្រើនជាង ៩០ ថ្ងៃ ដុល្លារអាមេរិក | ច្រើនជាង ១ឆ្នាំ ដុល្លារអាមេរិក | លើសពី ៥ឆ្នាំ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | | | | | |
| បំណុលហិរញ្ញវត្ថុ | | | | | | |
| ប្រាក់កម្ចី | - | ៦១៧.៧៣០ | ៣៤៩.៤៧៧ | ១.១៣៤.៣៥១ | ៤៧.៤៧៣ | ២.១៤៩.០៣១ |
| បំណុលភតិសន្យា* | ៥.៦០០ | ១៦.៨០០ | ៤៤.៨០០ | ៥០.៤០០ | - | ១១៧.៦០០ |
| ឥណទានវិបារូបណ៍ | ១.៧២៤.៥៩២ | - | - | - | - | ១.៧២៤.៥៩២ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ** | ៥៦៥.០៦៧ | - | - | - | - | ៥៦៥.០៦៧ |
| សមតុល្យត្រូវសងទៅម្ចាស់ភាគហ៊ុន | ៥.៦៤២ | - | - | - | - | ៥.៦៤២ |
| បំណុលហិរញ្ញវត្ថុសរុប | ២.៣០០.៩០១ | ៦៣៤.៥៣០ | ៣៩៤.២៧៧ | ១.១៨៤.៧៥១ | ៤៧.៤៧៣ | ៤.៥៦១.៩៣២ |
| សមតុល្យជាពាន់រៀល (សម្គាល់ ៤.២) | ៩.៣០៧.១៤៥ | ២.៥៦៦.៦៧៤ | ១.៥៩៤.៨៥០ | ៤.៧៩២.៣១៨ | ១៩២.០២៨ | ១៨.៤៥៣.០១៥ |

**មុនដកបន្ទុកហិរញ្ញប្បទាន*
***លើកលែងពន្ធផ្សេងៗដែលត្រូវបង់ និងបុរេប្រទានពីអតិថិជន*

### (គ). ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យនៃការប្តូររូបិយប័ណ្ណបរទេស របស់ក្រុមហ៊ុនកើតឡើងពីប្រតិបត្តិការនៃការប្តូររូបិយប័ណ្ណបរទេស។

ក្នុងអំឡុងនៃការិយបរិច្ឆេទ ការប៉ះពាល់របស់ក្រុមហ៊ុនចំពោះហានិភ័យនេះគឺមានតិចតួចបំផុត ព្រោះប្រតិបត្តិការភាគច្រើនរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។

### (ឃ). ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃសមស្របនៃលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនប្រែប្រួល ដោយសារតែការផ្លាស់ប្តូរអត្រាការប្រាក់នៅក្នុងទីផ្សារ។

ក្រុមហ៊ុនមិនប្រឈមនឹងហានិភ័យអត្រាការប្រាក់នោះទេ ដោយសារតែក្រុមហ៊ុនមិនមានអត្រារយៈពេលខ្លីណាមួយ ដោយផ្អែកទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុនោះទេ។

## ៣១. ការគ្រប់គ្រងដើមទុន

គោលបំណងចម្បងនៃការគ្រប់គ្រងដើមទុនរបស់ក្រុមហ៊ុនគឺដើម្បីធានាថា ក្រុមហ៊ុនអាចរក្សាសមាមាត្រដើមទុនគ្រប់គ្រាន់ដើម្បីគាំទ្រដល់អាជីវកម្មរបស់ខ្លួន និងបង្កើនតម្លៃដល់ម្ចាស់ភាគហ៊ុន។

ក្រុមហ៊ុនគ្រប់គ្រងរចនាសម្ព័ន្ធដើមទុន និងកែសំរួលវាដោយផ្អែកលើការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច។ ដើម្បីរក្សា ឬកែសម្រួលរចនាសម្ព័ន្ធដើមទុនក្រុមហ៊ុនអាចកែសំរួលភាគលាភដែលត្រូវបង់ទៅម្ចាស់ភាគហ៊ុន និងបោះផ្សាយសន្លឹកហ៊ុនថ្មី។ មិនមានការផ្លាស់ប្តូរណាមួយក្នុងគោលបំណងនៃគោលនយោបាយ ឬដំណើរការក្នុងអំឡុងចុងការិយបរិច្ឆេទនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងឆ្នាំ២០២០ឡើយ។

## ៣២. ព្រឹត្តិការណ៍ក្រោយការិយបរិច្ឆេទរបាយការណ៍

មិនមានការកែតម្រូវ ឬព្រឹត្តិការណ៍ដែលមិនតម្រូវឱ្យធ្វើការកែតម្រូវ បានកើតឡើងក្នុងអំឡុងកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ នៃរបាយការណ៍ និងនាការិយបរិច្ឆេទនៃការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឡើយ។

## ៣៣. ការអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១។

# ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ២០២១

# ឧបសម្ព័ន្ធរបាយការណ៍ប្រចាំឆ្នាំ ២០២១

# សម្រាប់ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង

# របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

## ផ្នែកទី១. ភាគហ៊ុនិក

### ក. រចនាសម្ព័ន្ធភាគហ៊ុនិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១)

#### ១. ព័ត៌មានរបស់ភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| ពី ៥% ទៅ ៣០% | ខ្មែរ | រូបវន្តបុគ្គល | ១ | ៣,៦០០,០០០ | ១៩.៥% |
| | ខ្មែរ | នីតិបុគ្គល | ១ | ៣,៤០០,០០០ | ១៨.៤២% |
| ពី ៣០% | ខ្មែរ | រូបវន្តបុគ្គល | ១ | ៨,៤០០,០០០ | ៤៥.៥% |

#### ២. ម្ចាស់ភាគហ៊ុនដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ក្រុមហ៊ុនដែលបានចុះបញ្ជី

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ២ | ១២,០០០,០០០ | ៦៥% |
| បុគ្គលិកជាន់ខ្ពស់ | ១៥ | ៥០៩,០០០ | ២.៧៦% |
| និយោជិត | ២៤ | ១០៦,៨០០ | ០.៥៨% |
| សរុប | ៥១ | ១២,៦១៥,៨០០ | ៦៨.៣៤% |

### ខ. សិទ្ធិ និងកាតព្វកិច្ចរបស់ភាគហ៊ុនិក

#### ១. សិទ្ធិរបស់ម្ចាស់ភាគហ៊ុន

លើកលែងតែមានការចែងផ្សេងពីនេះក្នុងលក្ខន្តិកៈនេះ ឬសេចក្តីសម្រេចពិសេសរបស់ភាគហ៊ុនិក អ្នកកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន ត្រូវមានៈ

- សិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក រួមទាំងសិទ្ធិបោះឆ្នោតដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងក្នុងកិច្ចប្រជុំណាមួយរបស់ភាគហ៊ុនិក។ ភាគហ៊ុននីមួយៗរបស់ក្រុមហ៊ុនផ្តល់ដល់អ្នកកាន់កាប់នូវសិទ្ធិបោះឆ្នោត ០១ (មួយ) សំឡេងក្នុងមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិទទួលបានភាគលាភ ឬផលប្រយោជន៍ដែលបានប្រកាសដោយក្រុមហ៊ុន។
- សិទ្ធិទទួលបានទ្រព្យសម្បត្តិ ដែលនៅសល់បន្ទាប់ពីការរំលាយ និងជម្រះបញ្ជីក្រុមហ៊ុន។

- សិទ្ធិទទួលបានព័ត៌មានគ្រប់ប្រភេទ រួមទាំងព័ត៌មានអំពីអាជីវកម្មរបស់ក្រុមហ៊ុន ព្រមទាំងសៀវភៅ និងកំណត់ត្រាគណនេយ្យរបស់ក្រុមហ៊ុន ព្រមទាំងអាចពិនិត្យបញ្ជីឈ្មោះភាគហ៊ុនិកបាននៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងម៉ោងធ្វើការ ឬនៅពេលប្រជុំមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិបុព្វក្រ័យ÷ ភាគហ៊ុនិកនីមួយៗមានសិទ្ធិបុព្វក្រ័យក្នុងការជាវបានមុននូវភាគហ៊ុនថ្មីដែលបោះចេញដោយក្រុមហ៊ុនស្របទៅតាមអនុបាតនៃការកាន់កាប់ភាគហ៊ុនរបស់ខ្លួន ហើយដែលភាគហ៊ុនថ្មីទាំងនោះស្ថិតក្នុងប្រភេទតែមួយជាមួយនឹងមូលបត្រកម្មសិទ្ធិដែលខ្លួនកំពុងកាន់កាប់។
- ការទទួលខុសត្រូវរបស់ភាគហ៊ុនិកនីមួយៗ ត្រូវបានកម្រិតត្រឹមចំនួនភាគហ៊ុនដែលបានទិញ។

### ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្ត

ការទទួលខុសត្រូវរបស់ភាគហ៊ុនិកនីមួយៗ ត្រូវបានកម្រិតត្រឹមចំនួនភាគហ៊ុនដែលបានទិញ។

## គ. មហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ និងមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ

### ១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ និងមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ

ក្រុមហ៊ុនត្រូវរៀបចំមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ តែមិនឱ្យលើសពី ០៦ (ប្រាំមួយ) ខែបន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធនីមួយៗ។ មហាសន្និបាតភាគហ៊ុនិកវិសាមញ្ញអាចធ្វើឡើងគ្រប់ពេល ករណីមានការស្នើសុំរបស់ក្រុមប្រឹក្សាភិបាលដោយសំឡេងភាគច្រើន នៃចំនួនសមាជិកនៃក្រុមប្រឹក្សាភិបាល ឬដោយសំណើជាលាយលក្ខណ៍អក្សររបស់ភាគហ៊ុនិកដែលកាន់កាប់យ៉ាងតិច ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់កាលបរិច្ឆេទ និងពេលវេលានៃមហាសន្និបាតភាគហ៊ុនិក។ មហាសន្និបាតភាគហ៊ុនិក ត្រូវធ្វើឡើងនៅអាសយដ្ឋានចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅកន្លែងដទៃទៀតដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ឬភាគហ៊ុនិកដែលជាអ្នកកោះប្រជុំ។

សម្រាប់គោលបំណងកំណត់ចំនួនភាគហ៊ុនិក ដែលមានសិទ្ធិទទួលបានសេចក្តីជូនដំណឹង ឬមានសិទ្ធិបោះឆ្នោតនៅក្នុងកិច្ចប្រជុំណាមួយរបស់ភាគហ៊ុនិក ឬនៅក្នុងកិច្ចប្រជុំលើកពេលណាមួយ ក្រុមប្រឹក្សាភិបាលអាចកំណត់នូវកាលបរិច្ឆេទកំណត់ទុកមុន សម្រាប់ការកំណត់ចំនួនភាគហ៊ុនិកនោះ ដោយមិនត្រូវលើសពី ៥០ (ហាសិប) ថ្ងៃ ឬមិនត្រូវតិចជាង ២០ (ម្ភៃ) ថ្ងៃ មុនកាលបរិច្ឆេទធ្វើមហាសន្និបាតភាគហ៊ុនិកដែលចំណាត់ការពិសេសតម្រូវឱ្យមានការកំណត់ចំនួនភាគហ៊ុនិកនោះត្រូវធ្វើឡើង។

ប្រសិនបើក្រុមប្រឹក្សាភិបាលមិនបានបង្កើតកាលបរិច្ឆេទកំណត់ទុកមុន នោះកាលបរិច្ឆេទកំណត់ទុកមុនត្រូវកំណត់នៅថ្ងៃធ្វើការចុងក្រោយ មុនពេលជូនដំណឹងអំពីកិច្ចប្រជុំ ឬប្រសិនបើគ្មានការជូនដំណឹងទេ ត្រូវយកថ្ងៃបើកកិច្ចប្រជុំ។

ចំពោះកាលបរិច្ឆេទកំណត់ទុកមុន ដើម្បីកំណត់ចំនួនភាគហ៊ុនិកសម្រាប់បញ្ហាណាមួយ ក្រៅពីសិទ្ធិទទួលសេចក្តីជូនដំណឹងអំពីកិច្ចប្រជុំ ឬសិទ្ធិបោះឆ្នោត ត្រូវយកថ្ងៃធ្វើការចុងក្រោយ ដែលក្រុមប្រឹក្សាភិបាលអនុម័តសេចក្តីសម្រេចដែលទាក់ទងនឹងបញ្ហានោះ។

នៅពេលការកំណត់ចំនួនភាគហ៊ុនិក ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក ត្រូវបានធ្វើឡើង ការកំណត់នេះត្រូវអនុវត្តចំពោះការលើកពេលកិច្ចប្រជុំផង ដែរ លើកលែងតែក្រុមប្រឹក្សាភិបាលបានកំណត់កាលបរិច្ឆេទកំណត់ទុកមុនថ្មី។

ប្រធានក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាភិបាល ត្រូវជូនដំណឹងអំពីមហាសន្និបាតភាគហ៊ុនិក តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយអេឡិចត្រូនិចដល់ភាគហ៊ុនិកទាំងអស់ ដែលមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក ឱ្យបានយ៉ាងតិច ២០ (ម្ភៃ) ថ្ងៃ ប៉ុន្តែមិនឱ្យលើសពី ៥០ (ហាសិប) ថ្ងៃ មុនកាលបរិច្ឆេទមហាសន្និបាតឡើយ។ ការជូនដំណឹងនោះត្រូវបញ្ជាក់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃមហាសន្និបាត ព្រមទាំងរបៀបវារៈដែលត្រូវពិភាក្សា និងសម្រេចផងដែរ។

មហាសន្និបាតភាគហ៊ុនិក ត្រូវកោះប្រជុំដោយប្រធានក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាភិបាល។ ប្រសិនបើប្រធានក្រុមប្រឹក្សា-ភិបាល ឬក្រុមប្រឹក្សាភិបាលពុំធ្វើការកោះប្រជុំក្នុងរយៈពេល ២១ (ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីទទួលបានសំណើ នោះភាគហ៊ុនិកណាម្នាក់ដែលបានចុះហត្ថលេខាលើសំណើ អាចកោះប្រជុំបាន។

ប្រសិនបើមិនអាចកោះប្រជុំ ឬរៀបចំមហាសន្និបាតភាគហ៊ុនិកបានទៅតាមបែបបទដូចមានបញ្ជាក់ក្នុងលក្ខន្តិកៈនេះឬច្បាប់ អភិបាលឬភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំអាចស្នើសុំតុលាការឱ្យចេញសេចក្តីសម្រេចណែនាំឱ្យមានការរៀបចំកិច្ចប្រជុំ តាមរបៀបណាមួយដែលតុលាការយល់ថាសមស្រប។ តុលាការអាចសម្រេចកែប្រែ ឬលើកលែងចោលនូវចំនួនកូរ៉ុមដែលតម្រូវដោយលក្ខន្តិកៈនេះចំពោះមហាសន្និបាតភាគហ៊ុនិកដែលត្រូវកោះហៅ និងរៀបចំឡើង។

ភាគហ៊ុនិកចូលរួមសន្និបាតដោយផ្ទាល់ ឬដោយសិទ្ធិប្រទាន ដែលកាន់កាប់ភាគហ៊ុនយ៉ាងហោចណាស់ ៧៥% (ចិតសិបប្រាំភាគរយ) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទើបអាចកែប្រែរបៀបវារៈនៃមហាសន្និបាតភាគហ៊ុនិកបាន ទោះបីជាមុនពេលមហាសន្និបាត ឬក្នុងពេលមហាសន្និបាតក៏ដោយ។

កូរ៉ុមនៃមហាសន្និបាតភាគហ៊ុនិក ត្រូវតែជាភាគហ៊ុនិកចូលរួមមហាសន្និបាតដោយផ្ទាល់ ឬដោយសិទ្ធិប្រទាន ដែលកាន់កាប់ភាគហ៊ុនចំនួនលើសពី ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត។ ភាគហ៊ុនដែលតំណាងសិទ្ធិប្រទាន នឹងត្រូវរាប់បញ្ចូលដើម្បីកំណត់កូរ៉ុមនៃមហាសន្និបាតភាគហ៊ុនិក។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនសម្រាប់ធ្វើមហាសន្និបាតណាមួយ នោះមហាសន្និបាតនោះនឹងត្រូវផ្អាករយៈពេល៣០ (សាមសិប)ថ្ងៃ។ ការជូនដំណឹងអំពីការផ្អាកមហាសន្និបាត ត្រូវផ្ញើជូនគ្រប់ភាគហ៊ុនិកទាំងអស់។ នៅពេលចាប់បន្តមហាសន្និបាតដែលបានផ្អាកនោះ ភាគហ៊ុនិកទាំងអស់ដែលមានវត្តមានក្នុងមហាសន្និបាតដែលផ្អាកនោះ ជាកូរ៉ុមដែលអាចធ្វើមហាសន្និបាតបាន។

ភាគហ៊ុនិក អាចផ្តល់សិទ្ធិប្រទានជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងណាម្នាក់ឱ្យចូលរួម និងបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក។ សិទ្ធិប្រទាននោះមានសុពលភាពសម្រាប់តែមហាសន្និបាតភាគហ៊ុនិកមួយលើកប៉ុណ្ណោះ (ចំពោះមហាសន្និបាតភាគហ៊ុនិកដែលបានផ្អាកនោះ ក៏ចាត់ទុកថាជាផ្នែកដូចគ្នាមួយនៃមហាសន្និបាតភាគហ៊ុនិកនោះផងដែរ)។ សិទ្ធិប្រទានអាចដកហូតមកវិញបានគ្រប់ពេលហើយ ត្រូវបានដកដោយស្វ័យប្រវត្តិ ប្រសិនបើភាគហ៊ុនិកដែលបានផ្តល់សិទ្ធិប្រទាននោះបានចូលរួមមហាសន្និបាតភាគហ៊ុនិកដោយផ្ទាល់។ ករណីអ្នកតំណាងចូលរួមបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក លិខិតតែងតាំងអ្នកតំណាងរូបនោះត្រូវដាក់ជូនប្រធានក្រុមប្រឹក្សាភិបាលនៅក្នុងអំឡុង ឬមុនពេលចាប់ផ្តើមកិច្ចប្រជុំ។

លិខិតផ្តល់សិទ្ធិប្រទានដល់អ្នកតំណាង ត្រូវចុះកាលបរិច្ឆេទ និងមានហត្ថលេខារបស់ភាគហ៊ុនិក ព្រមទាំងត្រូវបញ្ជាក់នូវ÷

- ចំនួនភាគហ៊ុនដែលកាន់កាប់ដោយភាគហ៊ុនិកដែលផ្តល់សិទ្ធិប្រទាន
- ឈ្មោះ និងអាសយដ្ឋានពេញលេញរបស់អ្នកតំណាងនោះ និង
- កិច្ចប្រជុំដែលអ្នកតំណាងនោះត្រូវបានតែងតាំងឱ្យចូលរួម។

មហាសន្និបាតភាគហ៊ុនិកនីមួយៗ ត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល។ ក្នុងករណីប្រធានក្រុមប្រឹក្សាភិបាលអវត្តមាន ភាគហ៊ុនិកដែលមានវត្តមានក្នុងកិច្ចប្រជុំត្រូវបោះឆ្នោតជ្រើសរើសតាំងប្រធានស្តីទី ដើម្បីដឹកនាំមហាសន្និបាតភាគហ៊ុនិកដោយមានសំឡេងឆ្នោតគាំទ្រភាគច្រើន។ ការបោះឆ្នោតក្នុងមហា-សន្និបាតភាគហ៊ុនិកត្រូវធ្វើឡើងដោយការលើកដៃឬដោយសន្លឹកឆ្នោត ទៅតាមការសម្រេចរបស់ប្រធាននៃមហាសន្និបាត។

លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈនេះ ដោយច្បាប់ឬដោយបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន រាល់សេចក្តីសម្រេចក្នុងមហាសន្និបាតភាគហ៊ុនិក តម្រូវឱ្យមានសន្លឹកឆ្នោតវិជ្ជមានយ៉ាងហោចណាស់ចំនួន ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតកាន់កាប់ដោយភាគហ៊ុនិក និងអ្នកតំណាង ដែលមានវត្តមានក្នុងកិច្ចប្រជុំ។ គ្មានសេចក្តីសម្រេចភាគហ៊ុនិកណាមួយត្រូវចងកាតព្វកិច្ចលើក្រុមហ៊ុនឡើយ លុះត្រាសេចក្តីសម្រេចនោះត្រូវបានអនុម័តតាមរបៀប និងនីតិវិធីដូចមានចែងក្នុងលក្ខន្តិកៈនេះ។

សេចក្តីសម្រេចរបស់កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកដែលមានចែងដូចខាងក្រោម ត្រូវអនុម័តដោយសំឡេងយ៉ាងតិច ៧៥% (ចិតសិបប្រាំភាគរយ) នៃសំឡេងឆ្នោតសរុបរបស់ភាគហ៊ុនិក និងអ្នកតំណាង ដែលមានវត្តមានក្នុងកិច្ចប្រជុំ និងមានសិទ្ធិបោះឆ្នោត (“សេចក្តីសម្រេចពិសេស”) ÷

- ការផ្លាស់ប្តូរនាមករណ៍ ឬទម្រង់របស់ក្រុមហ៊ុន។
- ការបង្កើន ឬបន្ថយដើមទុនចុះបញ្ជីក្រុមហ៊ុន។
- ការបញ្ចូល ឬការរំលាយក្រុមហ៊ុន។
- ការបង្កើន ការបន្ថយ ឬការកែប្រែទាក់ទងនឹងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន។
- ការបោះផ្សាយមូលបត្រ។
- ការកែប្រែថិរវេលាអត្ថិភាពរបស់ក្រុមហ៊ុន។
- ការកែប្រែលក្ខខណ្ឌកូរ៉ុមសម្រាប់កិច្ចប្រជុំភាគហ៊ុនិក ឬកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។
- ការកែប្រែប្រការទាំងឡាយនៃលក្ខន្តិកៈនេះ។
- ការទិញភាគហ៊ុនត្រលប់។
- តាមការតម្រូវផ្សេងទៀតដោយលក្ខន្តិកៈនេះ។

ដំណើរការនិងលទ្ធផលនៃមហាសន្និបាតភាគហ៊ុនិក ត្រូវកត់ត្រានៅក្នុងកំណត់ហេតុនៃមហាសន្និ-បាតភាគហ៊ុនិក ដោយត្រូវមានភ្ជាប់ឈ្មោះ និងហត្ថលេខារបស់អ្នកចូលរួម និងប្រធាននៃមហាសន្និបាតភាគហ៊ុនិក។ កំណត់ហេតុនៃមហាសន្និបាតភាគ

ហ៊ុនិកនីមួយៗ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល ឬប្រធាននៃមហាសន្និបាត និងលេខាធិការក្រុមហ៊ុន ព្រមទាំងត្រូវរក្សាទុកនៅទីស្នាក់ការចុះបញ្ជី។

ច្បាប់ចម្លង ឬសម្រង់នៃកំណត់ហេតុកិច្ចប្រជុំ ត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវ និងពិតប្រាកដដោយលេខាធិការក្រុមហ៊ុន និងត្រូវបញ្ជាក់ដោយប្រធានក្រុមប្រឹក្សាភិបាល ឬប្រធាននៃមហាសន្និបាតភាគហ៊ុនិក។

### ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិក

ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទើបតែចុះបញ្ជីនៅ ផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី ០៦ ខែកញ្ញា ២០២១។ ដូច្នេះហើយ ក្រុមហ៊ុនមិនទាន់រៀបចំនូវមហាសន្និបាតភាគហ៊ុនិកនៅឡើយទេ។

## ឃ. ការបែងចែកភាគលាភ

### ១. គោលនយោបាយភាគលាភ

ក្រុមហ៊ុន មានបំណងអនុញ្ញាតឱ្យភាគហ៊ុនិកចូលរួមក្នុងប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈការបែងចែកភាគលាភឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ខណៈពេលនៃការលៃបម្រុងឱ្យបានគ្រប់គ្រាន់សម្រាប់ការរីកចម្រើនរបស់ក្រុមហ៊ុននាពេលអនាគត។ ភាគលាភដែលត្រូវបានប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ ឌី ប៊ី ឌី ស្របតាមការអនុម័តរបស់ភាគហ៊ុនិក ក្នុងឆ្នាំសារពើពន្ធ ត្រូវបែងចែកក្នុងចំណោម ភាគហ៊ុនិកប្រភេទ “ខ” និងប្រភេទ ”ក”។

លទ្ធភាពក្នុងការទូទាត់ភាគលាភនាពេលអនាគតជូនភាគហ៊ុនិក គឺស្ថិតនៅលើកត្តាជាច្រើនរួមមាន ប្រតិបត្តិការហិរញ្ញវត្ថុ តម្រូវការលំហូរសាច់ប្រាក់ ទុនបម្រុងរក្សាទុក តម្រូវការចំណាយមូលធន និងកត្តាផ្សេងៗទៀតដែលត្រូវពិចារណាដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

#### ១.១. ភាគលាភអប្បបរមាដែលត្រូវបានធានា

ដើម្បីជាការលើកទឹកចិត្តដល់វិនិយោគិនសាធារណៈ និងដោយមានការយល់ព្រមពីភាគហ៊ុនិក ក្រុមប្រឹក្សាភិបាលរបស់ ឌី ប៊ី ឌី បានអនុម័តគោលនយោបាយភាគលាភ ដែលមានការធានាទិន្នផលភាគលាភអប្បបរមាប្រចាំឆ្នាំស្មើនឹង ៥,៥% សម្រាប់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រភេទ “ក”។ ភាគហ៊ុនិកប្រភេទ “ខ” មិនមានសិទ្ធិទទួលបានភាគលាភអប្បបរមាដែលត្រូវបានធានាចំពោះភាគហ៊ុនប្រភេទ “ក” ឡើយ ក្នុងរយៈពេលធានាភាគលាភអប្បបរមាដែលកំណត់ក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ប៉ុន្តែអាចទទួលបានភាគលាភដែលត្រូវបានបែងចែកលើសពីភាគលាភអប្បបរមា (បើសិនជាមាន)។

ភាគហ៊ុនិកប្រភេទ “ក” ត្រូវបានធានាផ្តល់ជូននូវទិន្នផលភាគលាភប្រចាំឆ្នាំក្នុងអត្រា ៥,៥% (អាចជាភាគរយជាសាច់ប្រាក់ ឬភាគលាភជាភាគហ៊ុន) នៃចំនួនភាគហ៊ុនសរុប ដែលកាន់កាប់ មុនថ្ងៃអិចឌីវិឌិនដ៍ (Ex-Dividend Day) គុណនឹងតម្លៃបោះផ្សាយលក់ភាគហ៊ុនប្រភេទ “ក” លើកដំបូង (IPO) ក្នុងរយៈពេល ៣ (បី) ឆ្នាំ ដែលភាគលាភអប្បបរមាត្រូវបានធានា អាចត្រូវបានប្រកាស និងបែងចែក។ ក្នុងករណីដែលមានមូលនិធិដែលអាចត្រូវបានប្រកាស និងបែងចែកជាភាគលាភ ក្រុមប្រឹក្សាភិបាលរបស់ ឌី ប៊ី ឌី ត្រូវធ្វើការសម្រេចប្រកាស និងបែងចែកភាគលាភទៅ

ភាគហ៊ុនិកនៅពេលដែលការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងមានរយៈពេល ១២ខែ ឬតិចជាងរយៈពេល ១២ខែ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលរបស់ ឌី ប៊ី ឌី។

ឌី ប៊ី ឌី អាចបែងចែកភាគលាភ ក្នុងទម្រង់ភាគលាភជាភាគហ៊ុន ដោយផ្អែកលើថ្លៃបិទ នៅថ្ងៃជួញដូរមុនថ្ងៃអិចឌីវិឌិនដ៍។ ឌី ប៊ី ឌី ត្រូវប្រកាសភាគលាភ ដែលអាចជាសាច់ប្រាក់ ឬជាភាគហ៊ុន ដើម្បីចែកជូនម្ចាស់ភាគហ៊ុនប្រភេទ "ក" ទៅតាមកម្រិតនៃភាគលាភអប្បបរមាដែលត្រូវបានធានា លើកលែងតែករណីមានការហាមឃាត់ដោយច្បាប់។ ក្នុងករណីមូលនិធិដែលអាចត្រូវបានប្រកាស និងបែងចែកជាភាគលាភ ធំជាងភាគលាភអប្បបរមាដែលត្រូវបានធានា តែ ឌី ប៊ី ឌី ពុំមានសាច់ប្រាក់គ្រប់គ្រាន់ ឬមិនមានគោលបំណងក្នុងការទូទាត់ជាភាគហ៊ុន ទំហំភាគលាភអប្បបរមាដែលត្រូវបានធានាដែលមិនត្រូវបានបែងចែកពេញលេញ នឹងត្រូវបង្គរទៅឆ្នាំបន្ទាប់រហូតដល់ការបែងចែកអាចធ្វើទៅបាន។ក្នុងករណីមូលនិធិដែលអាចត្រូវបានប្រកាស និងបែងចែកជាភាគលាភតូចជាងភាគលាភអប្បបរិមាដែលត្រូវបានធានា ចំនួនរយៈពេលនៃធានាភាគលាភអប្បបរមាដែលនៅសល់ នឹងត្រូវពន្យារទៅមុខដោយរាប់ចាប់ពីឆ្នាំបន្ទាប់។

### ១.២. ការប្រកាសភាគលាភ

ការជូនដំណឹងស្តីពីការបែងចែកភាគលាភ នឹងត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគហ៊ុនិក។

### ១.៣. ការទូទាត់ភាគលាភ

ក្រុមប្រឹក្សាភិបាល មានសិទ្ធិកំណត់ប្រាក់ចំណេញសុទ្ធមួយផ្នែក ដែលសមស្របសម្រាប់ទុកជាទុនបម្រុងដើម្បីប្រើប្រាស់ក្នុងប្រតិបត្តិការអាជីវកម្ម ស្របតាមច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន។

ករណីក្រុមហ៊ុន បានទទួលរងនូវការខាត ភាគលាភនឹងមិនត្រូវបានបែងចែកឡើយ រហូតដល់ការខាតបង់នោះ ត្រូវបានដោះស្រាយឡើងវិញ។

## ២. ព័ត៌មាននៃការបែងចែកភាគលាភសម្រាប់រយៈពេល ៣ឆ្នាំ ចុងក្រោយ

| ល.រ | ព្រឹត្តិការណ៍នាលម្អិតអំពីការបែងចែកភាគលាភ | ២០២១ | ២០២០ | ២០១៩ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ | មិនមាន | មិនមាន | ១៥ កក្កដា ២០១៩ |
| ២ | កាលបរិច្ឆេទកំណត់ទុក | មិនមាន | មិនមាន | ១៥ កក្កដា ២០១៩ |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | មិនមាន | មិនមាន | ១៥ កក្កដា ២០១៩ |

## ផ្នែកទី២. ក្រុមប្រឹក្សាភិបាល

### ក. ក្រុមប្រឹក្សាភិបាល

#### ១. សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទតែងតាំង | កាលបរិច្ឆេទបញ្ចប់អាណត្តិ |
|---|---|---|---|---|
| ១ | លោក នាង វិធី | ប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលប្រតិបត្តិ | ១០ មីនា ២០១៩ | ១០ មីនា ២០២២ |
| ២ | លោកស្រី លឹម មុយលី | អភិបាលប្រតិបត្តិ និង នាយកហិរញ្ញវត្ថុ | ១២ តុលា ២០២០ | ១២ តុលា ២០២៣ |
| ៣ | លោក ហ៊ុយ វ៉ាថារ៉ូ | អភិបាលឯករាជ្យ | ១២ តុលា ២០២០ | ១២ តុលា ២០២៣ |
| ៤ | លោក ថៃ វ៉ាន់ថា | អភិបាលមិនប្រតិបត្តិ | ១២ តុលា ២០២០ | ១២ តុលា ២០២៣ |

#### ២. ប្រវត្តិរូបសង្ខេបរបស់សមាជិកក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | តួនាទី | បទពិសោធន៍ |
|---|---|---|---|
| ១ | លោក នាង វិធី | ប្រធានក្រុមប្រឹក្សាភិបាល និងនាយកគ្រប់គ្រង | លោក នាង វិធី គឺជាស្ថាបនិករបស់ ឌី ប៊ី ឌី។ ឌី ប៊ី ឌី គឺជាក្រុមហ៊ុនជំនាញវិស្វកម្ម និងសំណង់ ដែលធ្វើប្រតិបត្តិការជាង ២០ឆ្នាំ កន្លងមកហើយ។ លោក គឺជានាយកគ្រប់គ្រងដែលមានចំណេះដឹង និងបទពិសោធន៍ជាច្រើន ពាក់ព័ន្ធនឹងផ្នែកវិស្វកម្ម និងសំណង់។ លោកមានជំនាញតម្លើងប្រអប់បញ្ជា និងធ្លាប់ជាវិស្វករអគ្គិសនី និងគម្រោង នៅប្រទេសបារាំង និងប្រទេសកម្ពុជា មុនពេលលោកបង្កើត ឌី ប៊ី ឌី។ ជាមួយនឹងបទពិសោធន៍របស់លោករយៈពេល ១២ឆ្នាំ នៅប្រទេសបារាំង និង ២៣ឆ្នាំ នៅប្រទេសកម្ពុជា លោកនាងវិធី បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចចិត្ត និងការទទួលខុសត្រូវក្នុងការដឹកនាំបេសកកម្ម ការគ្រប់គ្រងផែនការ និងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាព។ លោកទទួលបានបរិញ្ញាបត្រ ផ្នែកវិស្វកម្មប្រព័ន្ធអគ្គិសនីពី Lycee La Martiniere Monplaisure នៅទីក្រុង លីយ៉ុង ប្រទេសបារាំង។ |
| ២ | លោកស្រី លឹម មុយលី | អភិបាលប្រតិបត្តិ និង នាយកហិរញ្ញវត្ថុ | លោកស្រី លឹម មុយលី គឺជានាយកហិរញ្ញវត្ថុរបស់ ឌី ប៊ី ឌី។ លោកស្រី មានបទពិសោធន៍ជាច្រើនឆ្នាំពាក់ព័ន្ធនឹងការងារឡូជីស្ទីក គណនេយ្យ និងហិរញ្ញវត្ថុ។ លោក |

| | | | |
|---|---|---|---|
| | | | ស្រីទទួលខុសត្រូវក្នុងការងារ ស្វែងរកមូលធនសម្រាប់ចំណាយរបស់គម្រោង ធានានូវលំហូរសាច់ប្រាក់ និងអនុវត្តនូវស្តង់ដាគណនេយ្យប្រកបដោយប្រសិទ្ធភាព។ លោកស្រី មានសញ្ញាបត្របរិញ្ញាបត្រផ្នែកគណនេយ្យពីវិទ្យាស្ថានវ៉ាន់ដា។ |
| ៣ | លោក ហ៊ុយ វ៉ាថារ៉ូ | អភិបាលឯករាជ្យ | លោក ហ៊ុយ វ៉ាថារ៉ូ គឺជាអភិបាលឯករាជ្យរបស់ ឌី ប៊ី ឌី។ លោក គឺជានាយកគ្រប់គ្រង និងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្ត កម្ពុជារី និងជាប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមធានារ៉ាប់រងកម្ពុជាតាំងពីឆ្នាំ ២០១៤ មក។ លោក មានបទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុជាង ២០ឆ្នាំ មកហើយ។ លោកមានសញ្ញាបត្រអនុបណ្ឌិតផ្នែកអភិវឌ្ឍអន្តរជាតិពីសាកលវិទ្យាល័យអន្តរជាតិប្រទេសជប៉ុន (Nigata ប្រទេសជប៉ុន) សញ្ញាបត្របរិញ្ញាបត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសញ្ញាបត្រផ្នែកបច្ចេកទេសអគ្គិសនីពីវិទ្យាស្ថានបច្ចេកវិទ្យាប្រទេសកម្ពុជា។ |
| ៤ | លោក ថៃ វ៉ាន់ថា | អភិបាលមិនប្រតិបត្តិ | លោក ថៃ វ៉ាន់ថា គឺជាអភិបាលមិនប្រតិបត្តិ របស់ ឌី ប៊ី ឌី។ លោកជា អគ្គនាយករង ក្រុមហ៊ុន អ៊ីរ៉ូទិច អាហ៍រណនីហ៍រណ ខូអិលធីឌី តាំងពីឆ្នាំ២០០០ និងជាស្ថានិក home Photography តាំងពីឆ្នាំ ២០០៩។ លោក មានសញ្ញាបត្របរិញ្ញាបត្រ និងអនុបណ្ឌិតផ្នែករដ្ឋបាលធុរកិច្ច ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ |

### ៣. អភិបាល ដែលជាអភិបាល ភាគហ៊ុនិក ម្ចាស់ក្រុមហ៊ុន ឬសហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត

| ល.រ | ឈ្មោះ | ក្រុមហ៊ុន/ស្ថាប័ន | តួនាទីជាអភិបាល/ភាគហ៊ុនិក/ម្ចាស់ក្រុមហ៊ុន/សហកម្មករសិទ្ធិករ |
|---|---|---|---|
| ១ | លោក ហ៊ុយ វ៉ាថារ៉ូ | ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជារី | នាយកគ្រប់គ្រង និងជាសមាជិកក្រុមប្រឹក្សាភិបាល |
| | | សមាគមធានារ៉ាប់រងកម្ពុជា | ប្រធានក្រុមប្រឹក្សាភិបាល |
| ២ | លោក ថៃ វ៉ាន់ថា | ក្រុមហ៊ុន Home Photography | ម្ចាស់ក្រុមហ៊ុន |

## ៤. សិទ្ធិអំណាច និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល

ឌី បី ឌី ស្ថិតនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាភិបាល។ យោងតាមលក្ខន្តិកៈរបស់ ឌី បី ឌី ក្រុមប្រឹក្សាភិបាល មានសិទ្ធិអំណាចជាទូទៅក្នុងការគ្រប់គ្រងក្រុមហ៊ុនដែលរួមមានដូចខាងក្រោម÷

- ធានាថាក្រុមហ៊ុនធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយភាគហ៊ុនិក និងភាគីពាក់ព័ន្ធ
- បង្កើត តាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រ និងផែនការធុរកិច្ចរបស់ក្រុមហ៊ុន និងធានាថាធនធានត្រូវបានរៀបចំជាស្រេច ដើម្បីឆ្លើយតបគោលដៅដែលបានកំណត់
- បង្កើត តាមដាន និងវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- បង្កើត តាមដាន និងវាយតម្លៃប្រសិទ្ធភាពសវនកម្ម
- បង្កើត និងតាមដានគោលនយោបាយគ្រប់គ្រងហានិភ័យ
- រៀបចំគោលនយោបាយ ស្តីពីប្រាក់បំណាច់
- កំណត់លក្ខណៈវិនិច្ឆ័យ និងនីតិវិធីជ្រើសតាំងអភិបាល
- តែងតាំង និងដកហូតពីមុខតំណែង ជាលេខាធិការក្រុមហ៊ុន ប្រធានសវនកម្មផ្ទៃក្នុង និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល
- ធានាសាធនភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដោយបំពេញតួនាទី និងភារកិច្ចឱ្យអស់ពីលទ្ធភាព
- បង្កើតយន្តការ និងនីតិវិធីនៃការការពារសិទ្ធិរបស់ភាគហ៊ុនិក ដោយធានាថាភាគហ៊ុនិកដែលបានកាន់កាប់ភាគហ៊ុនភាគតិចក៏មានសិទ្ធិចូលរួមឈរឈ្មោះជាអភិបាល ឬស្នើបេក្ខភាពអភិបាល
- បង្កើតយន្តការ និងនីតិវិធីនៃការបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក ជាអាទិ៍ ការដាក់ឱ្យអនុវត្តប្រព័ន្ធបោះឆ្នោតត្រួតដើម្បីធានាបាននូវការការពារផលប្រយោជន៍របស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច
- បង្កើតយន្តការអនុញ្ញាតឱ្យភាគហ៊ុនិកដែលមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន និងភាគហ៊ុនិកដែលមានសិទ្ធិកាន់កាប់លើភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនលើសលប់ បង្ហាញព័ត៌មានដល់សាធារណៈជន តាមរយៈក្រុមហ៊ុនពាក់ព័ន្ធនឹងការប្រែប្រួលការកាន់កាប់ភាគហ៊ុន
- បង្កើតយន្តការ និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ
- បង្កើតគោលនយោបាយផ្សេងៗទៀតរបស់ក្រុមហ៊ុន
- ត្រូវអនុវត្តតាមច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន
- តួនាទីនានា ដែលតម្រូវដោយច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនានាជាធរមាន។

## ៥. ការប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទនៃកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ២៣ កញ្ញា ២០២១ | កិច្ចប្រជុំសាមញ្ញ | ៤ |
| ២ | ០៨ ធ្នូ ២០២១ | កិច្ចប្រជុំសាមញ្ញ | ៤ |
| ៣ | ៣០ មីនា ២០២២ | កិច្ចប្រជុំសាមញ្ញ | ៤ |

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១. រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

#### ១.១. គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ហ៊ុយ វ៉ាថារ៉ូ | ប្រធានគណៈកម្មាធិការសវនកម្ម | ១២ តុលា ២០២០ | ១ | ១ |
| ២ | ថៃ វ៉ាន់ថា | សមាជិក | ១២ តុលា ២០២០ | ១ | ១ |
| ៣ | លឹម មុយលី | សមាជិក | ១២ តុលា ២០២០ | ១ | ១ |

- **គណៈកម្មាធិការសវនកម្ម មានតួនាទី និងភារៈកិច្ចដូចខាងក្រោម÷**

  ១. ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុទាំងអស់

  ២. ពិនិត្យលើការត្រួតពិនិត្យផ្ទៃក្នុង

  ៣. ពិនិត្យលើការធ្វើសវនកម្មផ្ទៃក្នុង

  ៤. ពិនិត្យលើការធ្វើសវកម្មដោយសវនករឯករាជ្យ

  ៥. រាយការណ៍ និងផ្តល់របាយការណ៍ជូនក្រុមប្រឹក្សាភិបាល និង

  ៦. អនុវត្តកិច្ចការផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

- **លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម**

  ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទើបតែចុះបញ្ជីនៅ ផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី ០៦ ខែកញ្ញា ២០២១។ ដូច្នេះហើយ ក្រុមហ៊ុនមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការដំណើរការគណៈកម្មាធិការសវនកម្មរបស់ខ្លួននៅឆ្នាំ២០២១ ឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ។

### ២. ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ

ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក មិនមានការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការនោះទេ ។

## គ. ប្រាក់បំណាច់ ឬលាភការ

### ១. គោលការណ៍ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

គិតត្រឹមកាលបរិច្ឆេទនៃឯកសារផ្តល់ព័ត៌មាន ឌី ប៊ី ឌី កំពុងសិក្សា និងវិភាគអំពីសមត្ថភាពរបស់ខ្លួនក្នុងការបង្កើនប្រាក់បំណាច់ ឬលាភការជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់ទាំងអស់ នាពេលបច្ចុប្បន្ន ឬឆ្នាំខាងមុខដោយពិចារណាទៅលើលទ្ធផលការងាររបស់បុគ្គលិកនីមួយៗ លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេស។

២. ប្រាក់បំណាច់ និងបុគ្គលទទួលលាភការ

| ល.រ | ប្រាក់បំណាច់ និងបុគ្គលទទួលលាភការ | ប្រាក់បំណាច់ ឬចំនួនលាភការ (ដុល្លាអាមេរិក) | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | ១៧១,១៥០ | |
| ២ | បុគ្គលិកជាន់ខ្ពស់ | ៤០០,០៥៥.៧៧ | |

## ឃ. ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ

ឌី បី ឌី អ៊ិនជីនារីង ម.ក ទើបតែចុះបញ្ជីនៅ ផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី ០៦ ខែកញ្ញា ២០២១។ ដូច្នេះហើយ ក្រុមហ៊ុនមិនទាន់ធ្វើការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិនៅឡើយទេ។

## ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់មិនត្រូវបានបង្ហាញទេ នេះដោយសារតែ ឌី បី ឌី មិនបានរក្សាការកត់ត្រាកម្មវិធីបណ្តុះបណ្តាលអភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ក្នុងឆ្នាំ២០២១ ដោយសារតែ ឌី បី ឌី ទើបតែចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាផ្លូវការ នៅចុងឆ្នាំ២០២១ ហើយ ឌី បី ឌី ទើបតែដឹងថាព័ត៌មាននេះតម្រូវឱ្យដាក់ផ្សាយ។ ព័ត៌មានបណ្តុះបណ្តាលនឹងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២២ ។

# ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

## ក. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

### គោលបំណង និងតម្លៃស្នូល

បេសកកម្មរបស់ក្រុមហ៊ុនឌី បី ឌី អ៊ិនជីនារីងគឺបង្កើតឈ្មោះក្រុមហ៊ុនឌី បី ឌី អ៊ិនជីនារីង និងសំណង់ ដោយរក្សា គុណភាពល្អប្រសើរ និងការទទួលខុសត្រូវ ភាពឆ្លាតវៃ និងសេវាកម្មបម្រើអតិថិជនប្រកបដោយការប្រកួតប្រជែងអោយនៅដដែលដូចដែលធ្លាប់បានផ្តល់អោយតាំងពីឆ្នាំ ១៩៩៨ មកម្លេះ ។

តម្លៃស្នូលរបស់យើង ត្រូវបានទទួលស្គាល់ថា ធុរៈកិច្ចជោគជ័យត្រូវបានរកឃើញអាស្រ័យលើការប្តេជ្ញាចិត្ត ចំពោះគោលការណ៍ពិតប្រាកដ ។

### បុគ្គលិក

ជំនាញ ចំណង់ចំណូលចិត្ត និងតាមរយៈការដឹកនាំរបស់បុគ្គលិកដែលមានទេព្យកោសល្យ ធ្វើអោយភាជោគជ័យរបស់យើងសម្រេចបាន ។ យើង គោរពនិងលើកទឹកចិត្តគំនិត ភាពចម្រុះ និងវប្បធម៌របស់បុគ្គលិកយើង ។

### អតិថិជន

យើងប្តេជ្ញាចិត្តចំពោះអតិថិជនរបស់យើង និងបង្កើតឧស្សាហកម្មស្តង់ដារ ក្នុងការផ្តល់សេវាកម្ម និងការចែកចាយ ។

យើងទទួលយកភាពជាម្ចាស់ក្នុងការដោះស្រាយបញ្ហារបស់អតិថិជនរបស់យើង និងការចូលរួមក្នុងឱកាសថ្មីៗ ។

យើងជឿជាក់លើការផ្តល់នូវឧត្តមភាពឥតខ្ចោះនូវអ្វីគ្រប់យ៉ាងដែលយើងធ្វើ ។
យើងជឿជាក់លើការផ្តល់នូវឧត្តមភាពឥតខ្ចោះទៅលើអ្វីគ្រប់យ៉ាងដែលយើងធ្វើ។

**សុចរិតភាព**

យើងត្រូវតែប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តរបស់យើងក្នុងការធ្វើសកម្មភាពប្រកបដោយក្រមសីលធមិនិងសុចរិតភាព - នៅក្នុងអ្វីដែលយើងធ្វើរាល់ថ្ងៃ។

**សុវត្ថិភាព**

យើងជាក្រុមហ៊ុនដែលផ្តល់សុវត្ថិភាពខ្ពស់ ។ យើងទាំងអស់គ្នាមានការទទួល ខុសត្រូវក្នុងការរក្សាខ្លួនរបស់យើង និងមិត្តរួមការងាររបស់យើងអោយមាន សុវត្ថិភាព និងរាល់ការបំពេញការងារអោយអតិថិជនប្រកបដោយសុវត្ថិភាព ។

**ការច្នៃប្រឌិត**

ក្រុមហ៊ុនរបស់យើងមានភាពខុសគេដោយសារតែយើងប្រឈមខ្លួនឯង ដើម្បីស្វែងរកវិធីសាស្ត្រថ្មីក្នុងការចែកចាយជំនាញរបស់យើងតាមរយៈដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតដែលអាចឱ្យអតិថិជនម្នាក់ៗអាចដឹងពីចក្ខុវិស័យរបស់ខ្លួន។

**សុចរិតភាពនូវអ្វីដែលយើងធ្វើ**

នៅ ឌី ប៊ី ឌី យើងបេជ្ញាចិត្តធ្វើអ្វីដែលត្រឹមត្រូវនូវអ្វីដែលធ្វើទាំងអស់ ។ យើងជឿជាក់ថាការប្តេជ្ញាចិត្តចំពោះភាពស្មោះត្រង់បានធ្វើឱ្យក្រុមហ៊ុនរបស់យើងក្លាយជាអ្នកដឹកនាំឧស្សាហកម្ម និងនៅតែបន្តការរីកចម្រើនតទៅមុខទៀត ។ ក្រមសីលធម៏វិជ្ជាជីវៈ (ក្រម) បង្ហាញពីគុណតម្លៃវិជ្ជាជីវៈ សីលធមិ ហិរញ្ញវត្ថុនិងសង្គមរបស់ក្រុមហ៊ុនយើង។ វាកំណត់នូវអ្វីដែលជាការរំពឹងទុករបស់និយោជិក របស់ ឌី ប៊ី ឌី និង គ្រប់ទីកន្លែងដែលយើងធ្វើជំនួញ។ ក្រមរបស់យើងតំណាងអោយការប្តេជ្ញាចិត្តរបស់យើងចំពោះអតិថិជន ម្ចាស់ភាគហ៊ុន ដៃគូនិងសហគមន៍ដែលយើងរស់នៅនិងធ្វើការ។

គុណតម្លៃស្នូលរបស់យើងគឺជាគ្រឹះសម្រាប់ក្រមនេះ។ គោលការណ៍ខាងក្រោមនេះបានដាក់ចេញនូវគោលការណ៍ណែនាំសម្រាប់ឥរិយាបទដែលយើងត្រូវតែអនុវត្តតាម÷

- ឥរិយាបទខាងសីលធមិគឺជាមូលដ្ឋានសម្រាប់អ្វីគ្រប់យ៉ាងដែលយើងធ្វើ។
- ឌី ប៊ី ឌីមានការប្តេជ្ញាចិត្តក្នុងការប្រព្រឹត្តចំពោះនិយោជិករបស់ខ្លួនដោយស្មើភាពនិងផ្តល់ឱ្យយើងម្នាក់ៗនូវឱកាសសម្រាប់ការរីកចម្រើននិងលូតលាស់ ។
- ការធ្វើការងារជាក្រុម ការគោរពគ្នាទៅវិញទៅមកនិងការជឿទុកចិត្តគ្នា និងការប្រាស្រ័យទាក់ទងគ្នាគឺជាគ្រឹះនៃវប្បធមិរបស់ឌី ប៊ី ឌី។
- ការបំពេញតម្រូវការរបស់អតិថិជនមានសារៈសំខាន់បំផុត
- យើងប្តេជ្ញាគោរពតាមច្បាប់ វិធាន និងបទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា

**ឌី ប៊ី ឌី មួយ ក្រមមួយ**

យើងទាំងអស់គ្នាមានកតព្វកិច្ចអាន យល់ និងធ្វើតាមសីលធម៌វិជ្ជាជីវៈនេះ ។ វាអនុវត្តចំពោះសហសេវិកទាំងអស់ វិស្វករ មន្ត្រី និងនាយក រួមមបញ្ចូលទាំងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើងនិងក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា ដែលមានចំណាប់អារម្មណ៍ភាគច្រើនទៅលើ ឌី ប៊ី ឌី។ លើសពីនេះទៀត យើងរំពឹងថាអ្នកផ្គត់ផ្គង់ ភ្នាក់ងារ ដៃគូអាជីវកម្ម ក្រុមហ៊ុនម៉ៅការ ក្រុមហ៊ុនម៉ៅការបន្តនិងភាគីទីបីផ្សេងទៀតត្រូវដឹងហើយនឹងធ្វើតាមគោលការណ៍ស្រដៀងគ្នានៃស្តង់ដារសីលធម៌ទាំងនេះដូចដែលបានបញ្ជាក់នៅទីនេះ។ ការប្រើប្រាស់ក្រមរបស់យើងអនុញ្ញាតិអោយយើងរក្សាកេរ្តិ៍ឈ្មោះ ក្នុងការធ្វើធុរៈកិច្ចតាមរបៀបត្រឹមត្រូវ។ ចុងបញ្ចប់ យើងម្នាក់ៗត្រូវតែ÷

- គោរពតាមក្រមនេះ
- មិនត្រូវជួយអ្នកដ៏ទៃក្នុងការរំលោភច្បាប់នេះ
- បញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីក្រមសីលធម៌និងការរៀនសូត្រឱ្យបានទាន់ពេលវេលា។

អ្នកត្រូវទទួលខុសត្រូវក្នុងការអាន និងយល់នូវក្រមនេះ និងរំពឹងថាមិនមានការរំលាភបំពាន។ ការរំលោភក្រមនេះនឹងបណ្តាលឱ្យមានវិធានការដោះស្រាយ ។

**យើងពឹងផ្អែកទៅលើការគោរពរបស់បុគ្គលិករបស់យើង**

**ការប្តេជ្ញាចិត្តរបស់យើងចំពោះការធ្វើពិពិធកម្ម**

ឌី ប៊ី ឌី ប្តេជ្ញាចិត្តក្នុងការជម្រុញកន្លែងធ្វើការដែលយើងទាំងអស់គ្នាបង្កើតឡើងដោយសេចក្តីថ្លៃថ្នូរ និងការគោរព ។ យើងជឿជាក់ថាភាពខុសគ្នារវាងប្រវត្តិ បទពិសោធន៍ និងទស្សនវិស័យរបស់យើងផ្តល់អោយក្រុមហ៊ុនរបស់យើងមានភាព ខ្លាំងដែលយើងត្រូវការដើម្បីដឹកនាំទីផ្សារ និងឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់យើងចំពោះការធ្វើពិពិធកម្ម។ យើងទាំងអស់គ្នាមានទំនួលខុសត្រូវក្នុងការប្រព្រឹត្តចំពោះសហសេវិករបស់យើង - ក៏ដូចជាអ្នកដាក់ពាក្យសុំការងារ - ដោយការគោរពនិងដោយមិនរើសអើង។

ឌី ប៊ី ឌី ផ្តល់នូវឱកាសការងារស្មើៗគ្នាសម្រាប់បេក្ខជនទាំងអស់។ នេះផ្តល់ឱ្យយើងម្នាក់ៗនូវការគិតពិចារណាស្មើៗគ្នាសម្រាប់ការងារដោយមិនគិតពីប្រវត្តិ។ ការរក្សាកន្លែងធ្វើការប្រកបដោយការគោរពក៏មានន័យថាយើងមិនបានចូលរួមឬអត់ធ្មត់នឹងការរំខានយាយីណាមួយឡើយ។ ដើម្បីឱ្យកាន់តែច្បាស់ “ការរំខានយាយី” គឺជាសកម្មភាពដែលបង្កើតឬស្វែងរកការបង្កើតអរិភាព ការបំភិតបំភ័យ ឬការបំពាននៅក្នុងបរិយាកាស ។ ការរំខានយាយីអាចរួមមានប៉ុន្តែមិនកំណត់ត្រឹម÷

- ពាក្យសម្ដី (អនុសាសន៍ សំណូមពរ កប្លែង ឬស្នើសុំក្នុងការរួមភេទ)
- រូបភាព (ការគូររូប រូបថត ឬវីដេអូ)

អកប្បកិរិយារាងកាយ (រូបរាងគួរឱ្យចង់សើចឬការប៉ះដែលមិនពេញចិត្ត) ។

**រក្សាទីកន្លែងការងាររបស់យើងអោយមានសមត្ថភាព**

សុវត្ថិភាពគឺជាគុណតម្លៃស្នូល DBD និងសុវត្ថិភាពនិងសុវត្ថិភាពរបស់បុគ្គលិកទ្រព្យសម្បត្តិរាងកាយនិងបរិដ្ឋានដែលយើងធ្វើប្រតិបត្តិការគឺជាការទទួលខុសត្រូវរួមគ្នារបស់និយោជិក ឌី ប៊ី ឌី ម្នាក់ៗ។ យើងម្នាក់ៗមានទំនួលខុសត្រូវខាងសីលធម៌

និងច្បាប់ក្នុងការអនុវត្តតាមច្បាប់និងបទបញ្ញត្តិដែលត្រូវអនុវត្តក៏ដូចជាតម្រូវការផ្ទៃក្នុងរបស់យើងដែលទាក់ទងទៅនឹងសុវត្ថិភាពសុខភាពនិងបរិស្ថាននៃការងារដែលយើងធ្វើនិងកន្លែងដែលយើងគ្រប់គ្រង។

**ដឹកនាំដោយសមធម៌**

ការគ្រប់គ្រងរបស់យើងបម្រើអោយធនធាន និងគម្រូដល់ការធ្វើធុរៈកិច្ច ។ ដោយហេតុផលនេះអ្នកគ្រប់គ្រងមានទំនួលខុសត្រូវបន្ថែមនៅពេលនិយាយអំពីការលើកស្ទួយក្រមរបស់យើង។ ពួកគេត្រូវបានគេរំពឹងថានឹងលើកកម្ពស់បរិយាកាសការងារជាវិជ្ជ ដែលបុគ្គលិកទាំងអស់ត្រូវបានគេគោរពដោយសេចក្តីថ្លៃថ្នូរនិងការគោរព និងមានអារម្មណ៍ងាយស្រួលក្នុងការលើកឡើងនូវកង្វល់ដែលមាន។ អ្នកគ្រប់គ្រងក៏ត្រូវខិតខំផងដែរដើម្បីបង្កើតវប្បធម៌នៃការអនុវត្ត។ នេះអាចត្រូវបានធ្វើដោយផ្នែកដោយ÷

- ដើរតួជាគំរូសម្រាប់ការអនុវត្តន៍ក្រម។
- ជំរុញបរិយាកាសលើកទឹកចិត្តឱ្យមានការពិភាក្សាបើកចំហអំពីកង្វល់ផ្នែកច្បាប់និងកង្វល់ក្រមសីលធម៌។
- ការពារអោយបានតឹងរឹង នូវការរំលោភបំពានទៅលើក្រម គោលការណ៍ក្រុមហ៊ុនឬច្បាប់របស់យើង។

**ឌី ប៊ី ឌី ពឹងផ្អែកទៅលើភាពស្មោះត្រង់របស់យើង**

**ជៀសវាងទំនាស់ផលប្រយោជន៍**

យើងម្នាក់ៗមានចំណែកផ្ទាល់ខ្លួនក្នុងការធ្វើសកម្មភាពដើម្បីផលប្រយោជន៍ល្អបំផុតរបស់ ឌី ប៊ី ឌី។ ដើម្បីធានាបាននូវភាពជោគជ័យជាបន្តរបស់យើងវាជាការសំខាន់ណាស់ដែលយើងត្រូវចៀសវាងទំនាស់ផលប្រយោជន៍មិនថា ជាក់ស្តែង សក្តានុពល ឬការយល់ឃើញ។ “ ទំនាស់ផលប្រយោជន៍” កើតឡើងនៅពេលយើងប្រើជំហររបស់យើងជា ឌី ប៊ីឌី ឬព័ត៌មានដែលយើងទទួលបានក្នុងកំឡុងពេលដែលយើងកំពុងធ្វើការងារ តាមរបៀបមួយដែលអាចបង្កើតឱ្យមានទំនាស់រវាងផលប្រយោជន៍ផ្ទាល់ខ្លួន និងផលប្រយោជន៍របស់ក្រុមហ៊ុនឬ អតិថិជនរបស់យើង។

**អំណោយធុរៈកិច្ច និងការកំសាន្ត**

ការទទួលយកឬការផ្តល់អំណោយម្តងម្កាល ជាអាហារឬការកំសាន្ត ជាមួយដៃគូអាជីវកម្មត្រូវបានអនុញ្ញាតក្នុងកាលៈទេសៈខ្លះ។ ទោះយ៉ាងណាក៏ដោយយើងត្រូវតែធ្វើសកម្មភាពអោយស្របតាម តម្លៃស្នូលរបស់ក្រមយើង ច្បាប់ផ្សេងៗដែលគ្រប់គ្រងសកម្មភាពរបស់យើង និងតម្រូវការរបស់កិច្ចសន្យា។ អំណោយណាមួយដែលអាចបង្កើតជាកាតព្វកិច្ចឬមានឥទ្ធិពលលើទំនាក់ទំនងអាជីវកម្មមិនគួរផ្តល់ឱ្យឬទទួលយកឡើយ។ សម្រាប់ហេតុផលនេះយើងអាចផ្តល់ជូនឬទទួលយកអំណោយជាអាហារ ឬការកម្សាន្តស្របតាមច្បាប់ដែលអាចអនុវត្តបាន។

យើងមិនត្រូវផ្តល់អោយ ឬទទួលយកនូវការគួរសមទាំងនេះទេប្រសិនបើ÷

- វាខុសច្បាប់នៅក្នុងច្បាប់ឬបទបញ្ញត្តិដែលអាចអនុវត្តបាន.
- វាគឺទម្រង់មួយដែលអង្គភាពអាចចូលរួមក្នុងលទ្ធកម្មសកម្ម។
- វាគឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងដែលត្រូវធ្វើឬទទួលយកអ្វីត្រលប់មកវិញ។
- វាជាសាច់ប្រាក់រឺ សាច់ប្រាក់សមមូល ដូចជាកាត វិរិញ្ញាបនប័ត្រ ប្រាក់កម្ចី មូលប័ត្រកម្មសិទ្ធិ ។ល។
- វាអាចត្រូវបានបកស្រាយថាជាការសូកសំណូកឬ ការសងត្រលប់មកវិញ។

- វាអាចនឹងសមហេតុផលដែលត្រូវបានបកស្រាយថាជារង្វាន់សម្រាប់ការអនុគ្រោះ ការគិតពិចារណាជាក់ស្តែងឬ ការយល់ឃើញ ឬការបង្កើតកាតព្វកិច្ចលើភាគីម្ខាងទៀត។

### ការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននិងទិន្នន័យសម្ងាត់

យើងបានខិតខំជាខ្លាំងដើម្បីទទួលបានទ្រព្យសម្បត្តិដ៏មានតម្លៃរបស់យើង ទាំងទ្រព្យសម្បត្តិរូបវន្តនិងអរូបី។ ទ្រព្យសម្បត្តិរូបវ័ន្តរបស់ ឌី ប៊ី ឌី រួមមានអាគារគ្រឿងបរិក្ខារ យានយន្ត បរិក្ខារប្រព័ន្ធកុំព្យូទ័រ ធនធាន និងការកត់ត្រា។ យើងទទួលខុសត្រូវក្នុងការការពារទ្រព្យសម្បត្តិទាំងនោះពីការបាត់បង់ ការខូចខាត ការប្រើប្រាមិនត្រឹមត្រូវ ការលួចនិងការខ្ជះខ្ជាយ។ យើងអាចធ្វើដូច្នេះបាន លុះត្រាតែការប្រើធនធានរបស់ក្រុមហ៊ុនដោយប្រាជ្ញានិងសម្រាប់តែគោលបំណងអាជីវកម្មប៉ុណ្ណោះ។ វាក៏សំខាន់ផងដែរក្នុងការការពារទ្រព្យសម្បត្តិអរូបីរបស់យើងដូចជាកេរ្តិ៍ឈ្មោះ និងសុច្ចន្ទៈរបស់យើងនៅក្នុងសហគមន៍ដែលយើងធ្វើប្រតិបត្តិការ។ ទ្រព្យសម្បត្តិទាំងនេះក៏រួមបញ្ចូលព័ត៌មានសម្ងាត់របស់យើងផងដែរដូចជា ផែនការអាជីវកម្ម កម្មសិទ្ធិបញ្ញា សំណើ ការឌីសាញបច្ចេកទេសច្នៃប្រឌិត ការបង្កើតប៉ាតង់ ព័ត៌មានហិរញ្ញវត្ថុ បញ្ជីអតិថិជន និងព័ត៌មានផ្សេងទៀតដែលយើងបានកែច្នៃ ដែលជាផ្នែកមួយនៃការងាររបស់យើងសម្រាប់ ឌី ប៊ី ឌី។

យើងក៏មានកាតព្វកិច្ចការពារទិន្នន័យបុគ្គលិកស្របតាមការអនុវត្តច្បាប់ ។ គ្មាននរណាម្នាក់អាចទទួលបានកំណត់ត្រាបុគ្គលិកនាពេលបច្ចុប្បន្នឬអតីត - ដូចជាប្រាក់ឈ្នួល ការធានារ៉ាប់រង ឯកសារអត្ថប្រយោជន៍ និងការធ្វើការ - ដោយគ្មានការអនុញ្ញាតិត្រឹមត្រូវ។

### ការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័ររបស់ក្រុមហ៊ុន

ដូចគ្នាទៅនឹងកាតព្វកិច្ចការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន យើងក៏មានកាតព្វកិច្ចប្រើប្រាស់ធនធានកុំព្យូទ័រ បណ្តាញអ៊ីនធឺណេតនិងប្រព័ន្ធអ៊ីម៉ែលប្រកបដោយទំនួលខុសត្រូវ និងសុវត្ថិភាព។ ធនធានទាំងនេះត្រូវបាន ផ្តល់ជូនសម្រាប់គោលបំណងអាជីវកម្ម និងត្រូវបានបម្រុងទុកសម្រាប់ប្រើក្នុងធុរៈកិច្ច ។

### ទីផ្សារពឹងផ្អែកលើភាពស្មោះត្រង់របស់យើង

### ទទួលបានអាជីវកម្មដោយភាពស្មោះត្រង់

ដើម្បីបម្រើដៃគូអាជីវកម្មរបស់យើងឱ្យអស់ពីសមត្ថភាព យើងត្រូវមានភាពស្មោះត្រង់ជានិច្ចអំពីអ្វីដែល ឌី ប៊ី ឌីអាចនឹងសម្រេចបាន និងមិនអាចសម្រេចបាន។ រាល់ពេលដែលយើងពិភាក្សាអំពីសមត្ថភាពរបស់យើង លិខិតបញ្ជាក់គុណវុឌ្ឍិ និងប្រវត្តិសាជីវកម្ម ដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរក្តី យើងត្រូវតែប្រាកដថាជាមនុស្សរាប់អាននិងត្រឹមត្រូវ។

### ការប្រកួតប្រជែងដោយស្មើភាព

ដោយសារ ឌី ប៊ី ឌី ប្រកួតប្រជែងដោយផ្អែកលើគុណភាពនៃផលិតផលនិងសេវាកម្ម យើងប្តេជ្ញាលើកកម្ពស់ការប្រកួតប្រជែងដោយយុត្តិធមិគ្រប់ពេល។

### ជៀសវាងការអនុវត្តអំពើពុករលួយ

ឌី ប៊ី ឌីមានមោទនភាពចំពោះការងារដែលខ្លួនធ្វើនៅទូទាំងប្រទេស។ យើងជឿជាក់ថាសមត្ថភាពរបស់យើងក្នុងការបន្តពង្រឹងទំនាក់ទំនងការងារល្អជាមួយក្រុមហ៊ុន សហគមន៍ និងរដ្ឋាភិបាល ទូទាំងប្រទេសគឺពឹងផ្អែកលើការធ្វើសកម្មភាពប្រកបដោយ

ក្រមសីលធម៌នៅក្នុងការធ្វើជំនួញរបស់យើង។ នេះមានន័យថាយើងមិនដែលផ្តល់ឱ្យឬទទួលយកការទូទាត់មិនត្រឹមត្រូវតាមទម្រង់ណាមួយឡើយ។ ស្រដៀងគ្នានេះដែរយើងមិនត្រូវផ្តល់ឬសងប្រាក់ត្រឡប់មកវិញដែលជាការត្រឡប់មកវិញនូវប្រាក់ដែលបានបង់រួចហើយ (ឬដោយសារតែត្រូវបង់) ជារង្វាន់សម្រាប់ការរៀបចំឬជម្រុញការរៀបចំអាជីវកម្ម។ យើងមិនអាចរក្សាទុកភាគីទីបីឬចូលរួមក្នុងការបណ្តាក់ទុនរួមគ្នាឬសមាគមអាជីវកម្មផ្សេងទៀត ដែលបានចូលរួមក្នុងសកម្មភាពណាមួយដែលយើងត្រូវបានហាមឃាត់មិនឱ្យចូលរួមនៅក្នុងអាជីវកម្មយើងឡើយ។

## ម្ចាស់ភាគហ៊ុន ដៃគូអាជីវកម្ម និងអតិថិជន ពឹងផ្អែកលើឧត្តមភាពរបស់យើង

## ការផ្តល់ផលិតផល និងសេវាកម្ម ដែលមានគុណភាព

មូលដ្ឋានគ្រឹះនៃកេរ្តិ៍ឈ្មោះរបស់ ឌី ប៊ី ឌី គឺគុណភាពខ្ពស់នៃផលិតផលនិងសេវាកម្មដែលយើងផ្តល់ជូន។ ដើម្បីរក្សាស្តង់ដាររបស់យើងឱ្យខ្ពស់ យើងម្នាក់ៗត្រូវតែអនុវត្តតាមនីតិវិធីត្រួតពិនិត្យគុណភាពទាំងអស់ និងអនុវត្តតាមកិច្ចសន្យាជាក់លាក់គ្រប់ពេលវេលា។

## ការផ្តល់អាជ្ញាប័ណ្ណ

យើងទទួលខុសត្រូវក្នុងការរក្សាអាជ្ញាប័ណ្ណសមស្រប។ ក្រុមហ៊ុនរបស់យើងប្តេជ្ញាបង្ហាញសេវាកម្មវិជ្ជាជីវៈតែនៅក្នុងយុត្តាធិការដែលយើងទទួលបានការអនុញ្ញាត ធ្វើដូច្នេះលើកលែងតែមានការលើកលែងដោយច្បាប់ដែលអាចអនុវត្តបាន។

## កំណត់ត្រាគណនេយ្យត្រឹមត្រូវ

យើងម្នាក់ៗត្រូវបំពេញការងាររបស់យើងដើម្បីធ្វើឱ្យប្រាកដថាឯកសារហិរញ្ញវត្ថុដែលក្រុមហ៊ុនរបស់យើងបង្ហាញជូនសាធារណជនមានភាពត្រឹមត្រូវនិងស្មោះត្រង់។ ព័ត៌មានដែលយើងកត់ត្រាផ្តល់នូវទស្សនៈត្រឹមត្រូវនៃប្រតិបត្តិការរបស់យើង និងអនុញ្ញាតឱ្យក្រុមហ៊ុនរបស់យើងធ្វើការសម្រេចចិត្តអាជីវកម្មដែលមានព័ត៌មានល្អ។ ដូច្នេះរាល់ព័ត៌មានទាំងអស់ដែលយើងបញ្ជូនទៅក្នុងកំណត់ត្រាក្រុមហ៊ុន ត្រូវតែជាព័ត៌មានជាក់លាក់ត្រឹមត្រូវនិងពេញលេញ។

## ការរក្សាកំណត់ត្រា

រក្សាកំណត់ត្រារបស់យើងឱ្យមានសណ្តាប់ធ្នាប់ជួយឱ្យយើងបង្កើតទំនុកចិត្តជាមួយអតិថិជន និយ័តករ និងម្ចាស់ភាគហ៊ុន។ ការប្តេជ្ញាចិត្តនេះអនុវត្តទាំងឯកសារជាលាយលក្ខណ៍អក្សរ និងអេឡិចត្រូនិក រួមទាំងឯកសារដូចជា សារអេឡិចត្រូនិចនិងរូបភាព។ សរុបសេចក្តីមកយើងត្រូវយកចិត្តទុកដាក់លើរាល់កំណត់ត្រាដែលយើងបង្កើតទទួល ឬ រក្សាដើម្បីបំពេញការងាររបស់យើង។ ការគ្រប់គ្រងកំណត់ត្រាទាំងនេះប្រកបដោយប្រសិទ្ធភាពអនុញ្ញាតឱ្យយើងធានាថាវាអាចរកបាននៅពេលដែលមានតម្រូវការចាំបាច់។

## សវនកម្មនិងការស៊ើបអង្កេត

ក្នុងអំឡុងពេលនៃការងាររបស់អ្នក ក្រុមហ៊ុនឬអតិថិជន អាចស្នើសុំឱ្យអ្នកចូលរួមក្នុងការធ្វើសវនកម្មឬការស៊ើបអង្កេតរបស់ឌី ប៊ី ឌី ឬនិយោជិកជាក់លាក់។

**សុចរិតភាពហិរញ្ញវត្ថុ**

**ការការពារការលាងលុយកខ្វក់**

ឌី ប៊ី ឌី ប្តេជ្ញាជួយក្នុងការប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់ទូទាំងពិភពលោក។ " ការលាងលុយកខ្វក់" គឺជាដំណើរការដែលមនុស្សម្នាក់ ឬក្រុមមនុស្សព្យាយាមលាក់បាំងមូលនិធិខុសច្បាប់ ឬការប៉ុនប៉ងដើម្បីធ្វើឱ្យប្រភពនៃមូលនិធិខុសច្បាប់របស់ពួកគេមើលទៅស្របច្បាប់។ ដើម្បីកុំអោយ ឌី ប៊ី ឌី ចូលរួមក្នុងការប្រព្រឹត្តខុសដោយចេតនានេះ យើងគួរឧស្សាហ៍យកចិត្តទុកដាក់ចំពោះអតិថិជនអ្នកផ្គត់ផ្គង់ភ្នាក់ងារអន្តរការីនិងដៃគូអាជីវកម្មដទៃទៀតដែលមានបំណងធ្វើអាជីវកម្មជាមួយក្រុមហ៊ុនរបស់យើង។

សហគមន៍របស់យើងពឹងផ្អែកទៅលើភាពស្មោះត្រង់ និងការច្នៃប្រឌិតរបស់យើង

**និរន្តរភាពបរិស្ថាន**

ក្នុងនាមជាពលរដ្ឋសាជីវកម្មល្អ យើងអនុវត្តតាមច្បាប់បទប្បញ្ញត្តិ និងបរិស្ថានទាំងអស់ដែលមានប្រសិទ្ធិភាពនៅគ្រប់ទីកន្លែងដែលយើងធ្វើធុរៈកិច្ច។ ដល់ទីបញ្ចប់នេះ យើងខិតខំឥតឈប់ឈរដើម្បីបង្កើនការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនៅក្នុងកន្លែងធ្វើការរបស់យើងនិងកាត់បន្ថយស្នាមដានបរិស្ថាន។

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

ក្រមសីលធម៌របស់ ឌី ប៊ី ឌី ត្រូវបានបង្ហាញដល់ក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកទាំងអស់ ក៏ដូចជាសាធារណៈជនផងដែរ។ ជាធម្មតា ក្រុមហ៊ុនធ្វើបទបង្ហាញដល់បុគ្គលិកតាមរយៈការបណ្តុះបណ្តាលផ្ទៃក្នុង និងការប្រជុំ និងជាសាធារណៈដោយផ្សព្វផ្សាយនៅលើគេហទំព័ររបស់ក្រុមហ៊ុន។

## គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

គិតត្រឹមឆ្នាំ ២០២១ ក្រុមហ៊ុនមិនទាន់មានយន្តការ និងនីតិវិធីសម្រាប់ត្រួតពិនិត្យការអនុវត្តក្រមសីលធម៌នៅឡើយទេ។ ប៉ុន្តែបើមានការប្រព្រឹត្តខុសពីគណៈកម្មាធិការ និងគណៈគ្រប់គ្រង នឹងមានការស៊ើបអង្កេត និងចាត់វិធានការតាមផ្លូវច្បាប់។

## ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

### ១. គោលនយោបាយសម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | មិនមាន |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | មិនមាន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | មិនមាន |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងច្រើនលើសលុប | មិនមាន |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | មិនមាន |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | មិនមាន |
| ៧ | ផ្សេងៗ | មិនមាន |

២. ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ឈ្មោះភាគីជាប់ពាក់ព័ន្ធ | ទំនាក់ទំនង | ប្រតិបត្តិការ | ២០២១ (ពាន់រៀល) |
|---|---|---|---|---|
| ១ | នាង វិធី | ភាគហ៊ុនិក និង នាយកគ្រប់គ្រង | ការទូទាត់ជំនួសភាគហ៊ុនិក | ៧៤៨ |
| | | | ការទូទាត់សងពីភាគហ៊ុនិក | (៧០៦) |
| | | | ការទូទាត់ជំនួសក្រុមហ៊ុន | ៣៤ |
| | | | ការទូទាត់សងទៅភាគហ៊ុនិក | ១៣២ |

## ផ្នែកទី៤. ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

### ក. សង្ខេបអំពីគោលនយោបាយគ្រប់គ្រងហានិភ័យ

អាជីវកម្ម ឬស្ថានភាពហិរញ្ញវត្ថុរបស់ ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក អាចរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយកត្តាហានិភ័យជាច្រើន។ អាស្រ័យហេតុនេះ ក្រុមហ៊ុនត្រូវចាត់វិធានការកាត់បន្ថយហានិភ័យ ដូចមានចែងខាងក្រោម÷

**១. ហានិភ័យនៃការប៉ាន់ស្មានតម្លៃទាប**

គម្រោងភាគច្រើនដែល ឌី ប៊ី ឌី ទទួលបាន ត្រូវបានណែនាំតាមរយៈអតិថិជនរបស់ ឌី ប៊ី ឌី ឬតាមរយៈការចូលរួមដេញថ្លៃ។ ហានិភ័យអាចនឹងកើតមាននៅពេលដែល ឌី ប៊ី ឌី ប៉ាន់ស្មានតម្លៃទាបនៅពេលដែលដេញថ្លៃគម្រោង ដោយសារការប៉ាន់ស្មានតម្លៃទាបពេកទៅលើសម្ភារៈ ឬកម្លាំងពលកម្ម។ កត្តាច្រើនដែលអាចនាំឲ្យមានការប៉ាន់ស្មានតម្លៃទាប រួមមាន ថ្លៃដើមពលកម្មដែលមិនអាចដឹងមុន ពេលវេលា កំហុសក្នុងគំនូសព្រាង ភាពខុសគ្នានៃលក្ខណៈបច្ចេកទេស ការប្រែប្រួលនៃតម្លៃវត្ថុធាតុដើម និងការផ្លាស់ប្តូរវិសាលភាពការងារ។ ការប៉ាន់ស្មានតម្លៃទាបជាងតម្លៃជាក់ស្តែងនៃគម្រោង អាចផ្តល់ផលប៉ះពាល់អវិជ្ជមានដល់ប្រាក់ចំណេញ។

**វិធានការកាត់បន្ថយ÷**

ឌី ប៊ី ឌី បានបង្កើតស្តង់ដារ និងគោលការណ៍ណែនាំយ៉ាងក្បោះក្បាយសម្រាប់រាល់ការដេញថ្លៃគម្រោង ដែលរួមមានបីដំណាក់កាល ÷ (១) ការស្ទង់មតិដែលដឹកនាំដោយក្រុមអ្នកស្ទង់មតិ (២) ការប៉ាន់ស្មានតម្លៃ និង (៣) សុពលភាពដែលត្រូវបានត្រួតពិនិត្យដោយអ្នកដេញថ្លៃដែលទទួលបានការអនុញ្ញាត។ ដំណើរការត្រួតពិនិត្យការដេញថ្លៃ ត្រូវបានធ្វើឡើងដោយអ្នកជំនាញរបស់ក្រុមហ៊ុន ក្នុងនោះរួមមានក្រុមអ្នកជំនាញផ្នែកច្បាប់ និងអ្នកជំនាញបច្ចេកទេស ដែលត្រួតពិនិត្យឡើងវិញនូវគំនូសព្រាង និងលក្ខណៈបច្ចេកទេស ក៏ដូចជាត្រួតពិនិត្យការអនុវត្តនៅនឹងកន្លែងរបស់គម្រោងនីមួយៗ។

**២. ហានិភ័យនៃកង្វះខាតសម្ភារៈ និងការប្រែប្រួលតម្លៃ**

ឌី ប៊ី ឌី ពឹងផ្អែកយ៉ាងខ្លាំងទៅលើការផ្គត់ផ្គង់ និងផលិតផលដែលទទួលបានពីទីផ្សារបរទេសដោយសារតែកង្វះខាតនៅកម្ពុជា។ ជាឧទាហរណ៍ជាក់ស្តែង ផលិតផលដែលប្រើក្នុងអាជីវកម្មរបស់ ឌី ប៊ី ឌី គឺដែកថែប និងបេតុង ដែលក្រុមហ៊ុន បាននាំចូលពីទីផ្សារថៃ ចិន និងវៀតណាម ភាគច្រើន។ ជាធម្មតា តម្លៃប្រែប្រួលចំពោះផលិតផលទាំងនេះ គឺប្រែប្រួលពី ៣% ទៅ

៥% ក្នុងមួយឆ្នាំ។ តម្លៃ និងវត្តមានរបស់ផលិតផលជារួម អាចរងផលប៉ះពាល់ដោយកត្តាជាច្រើន ដូចជា តម្រូវការទីផ្សារ និងស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ការប្រែប្រួលអាកាសធាតុ តម្លៃប្រេងឥន្ធនៈ និងស្ថានភាពនយោបាយជាដើម។

ដោយសារលក្ខណៈនៃអាជីវកម្មរបស់ខ្លួន ឌី ប៊ី ឌី ត្រូវបានតម្រូវឱ្យដាក់ឯកសារដេញថ្លៃលើគម្រោងនានា ហើយនិងចុះកិច្ចសន្យាផ្អែកលើតម្លៃដេញថ្លៃ។ ឌី ប៊ី ឌី ដាក់តម្លៃដេញថ្លៃគម្រោងដោយផ្អែកលើការប៉ាន់ស្មានដ៏ល្អបំផុតរបស់ខ្លួន រួមបញ្ចូលទាំងការប៉ាន់ស្មានថ្លៃដើមនៃការផ្គត់ផ្គង់។ ប្រសិនបើថ្លៃដើមនៃការផ្គត់ផ្គង់ កើនឡើងបន្ទាប់ពីការដេញថ្លៃត្រូវបានទទួលយក ឌី ប៊ី ឌី មិនអាចស្នើថ្លៃដើមបន្ថែមទៅអតិថិជនបានទេ ហើយក្រុមហ៊ុន អាចនឹងគ្មានជម្រើសណាមួយក្រៅពីទិញមុខទំនិញនៅក្នុងតម្លៃថ្លៃ ដែលជាហេតុនាំឱ្យប្រាក់ចំណេញ ធ្លាក់ចុះ។ ហានិភ័យ ក៏អាចកើតមានផងដែរ នៅពេលដែលការផ្គត់ផ្គង់ចាំបាច់សម្រាប់គម្រោង ត្រូវពន្យារពេល ឬមិនមានជាបណ្តោះអាសន្ន ដែលបណ្តាលឱ្យរយៈពេលបញ្ចប់គម្រោងត្រូវបានពន្យារពេល និងថ្លៃដើមគម្រោងកើនឡើង។ រាល់ការកើនឡើងនៃថ្លៃដើមផ្គត់ផ្គង់ ឬការពន្យារពេលក្នុងការទទួលការផ្គត់ផ្គង់ អាចជះឥទ្ធិពលអវិជ្ជមានដល់អាជីវកម្ម និងផលចំណេញរបស់ក្រុមហ៊ុន។

**វិធានការកាត់បន្ថយ÷**

ឌី ប៊ី ឌី រក្សាទំនាក់ទំនងយ៉ាងល្អជាមួយអ្នកផ្គត់ផ្គង់នានា និងមាននីតិវិធីដើម្បីកាត់បន្ថយហានិភ័យទាក់ទងនឹងការប្រែប្រួលនៃតម្លៃផ្គត់ផ្គង់។ នីតិវិធីសំខាន់ គឺការចរចារតម្លៃជាមុនជាមួយនឹងអ្នកផ្គត់ផ្គង់ ដូច្នេះតម្លៃផ្គត់ផ្គង់ ត្រូវបានកំណត់ក្នុងកំឡុងពេលនៃគម្រោង។ ជាផ្នែកមួយនៃដំណើរការចរចារ ឌី ប៊ី ឌី បានរួមបញ្ចូលតម្រូវការផ្គត់ផ្គង់នៃគម្រោងដែលកំពុងដំណើរការរបស់ខ្លួនភាគច្រើន ដើម្បីទទួលបានការបញ្ចុះតម្លៃយ៉ាងច្រើន និងបន្ថែមចំនុចខ្លាំងលើការចរចាររបស់ខ្លួន។ លើសពីនេះទៀត ឌី ប៊ី ឌី ព្យាយាមរកការផ្គត់ផ្គង់ចាំបាច់បំផុតមុនពេលចាប់ផ្តើមគម្រោង ដើម្បីកាត់បន្ថយទាំងការប្រែប្រួលតម្លៃ និងហានិភ័យនៃការពន្យារពេលផ្គត់ផ្គង់។

ទោះបីជា ឌី ប៊ី ឌី ត្រូវបានចុះកិច្ចសន្យាក្នុងតម្លៃ ជាមួយរយៈពេលសម្រាប់គម្រោងដែលបានដេញថ្លៃក៏ដោយ ក៏ ឌី ប៊ី ឌី អាចចរចារឡើងវិញជាមួយម្ចាស់គម្រោងទៅលើពេលវេលា និងតម្លៃថ្មី ប្រសិនបើព្រឹត្តិការណ៍ទីផ្សារណាមួយកើតមានឡើងដែលហួសពីដែនគ្រប់គ្រងរបស់ ឌី ប៊ី ឌី។

**៣. ហានិភ័យពីការប្រកួតប្រជែង**

ដោយសារវិស័យសំណង់រឹងមាំ និងមានការរីកចម្រើន ចំនួនក្រុមហ៊ុនសំណង់ទាំងបរទេស និងក្នុងស្រុកមានការកើនឡើងយ៉ាងឆាប់រហ័ស។ ឌី ប៊ី ឌី កំពុងប្រឈមមុខនឹងការប្រកួតប្រជែងកាន់តែខ្លាំងឡើងនៅក្នុងដំណើរការដេញថ្លៃសម្រាប់គម្រោងរបស់ខ្លួន។ ដៃគូប្រកួតប្រជែងនានាដែលមានដើមទុនច្រើន កំពុងបញ្ចុះតម្លៃក្នុងការដេញថ្លៃដើម្បីទទួលបានចំណែកទីផ្សារ។ កត្តានេះហើយដែលធ្វើឱ្យ ឌី ប៊ី ឌី ត្រូវបង្ខំចិត្តបញ្ចុះតម្លៃក្នុងការដេញថ្លៃដើម្បីទទួលបានគម្រោង។ បរិយាកាសប្រកួតប្រជែងនៅក្នុងវិស័យសំណង់កម្ពុជា អាចជះឥទ្ធិពលមិនល្អដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុន ដោយសារហានិភ័យនៃការបាត់បង់ការដេញថ្លៃ ឬការកាត់បន្ថយប្រាក់ចំណេញលើគម្រោងដែល ឌី ប៊ី ឌី ត្រូវបញ្ចុះតម្លៃដេញថ្លៃ។

**វិធានការកាត់បន្ថយ÷**

ដោយសារបទពិសោធន៍ដ៏ទូលំទូលាយនៅក្នុងវិស័យសំណង់កម្ពុជា ឌី ប៊ី ឌី អាចជ្រើសរើសគម្រោងដើម្បីដេញថ្លៃបានស្របតាមជំនាញរបស់ក្រុមហ៊ុន។ កត្តានេះ អនុញ្ញាតឱ្យ ឌី ប៊ី ឌី គ្រប់គ្រងថ្លៃដើមគម្រោង និងដាក់តម្លៃដេញថ្លៃសមរម្យ ដើម្បីឱ្យ

ក្រុមហ៊ុននៅតែទទួលបានផលចំណេញ។ លើសពីនេះទៀតកេរ្តិ៍ឈ្មោះដ៏រឹងមាំ និងបទពិសោធន៍ជាង ២៥ ឆ្នាំ ជួយឱ្យ ឌី ប៊ី ឌី ឈ្នះការដេញថ្លៃគម្រោង ទោះបីជាការដេញថ្លៃ មិនទាបពេកជាងក្រុមហ៊ុនដទៃទៀតក៏ដោយ។

## ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ទើបតែចុះបញ្ជីនៅ ផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី ០៦ ខែកញ្ញា ២០២១។ ដូច្នេះហើយ ក្រុមហ៊ុនមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការដំណើរការមុខងារសវនកម្មផ្ទៃក្នុងរបស់ខ្លួននៅឆ្នាំ២០២១ នៅឡើយទេ។

ទោះយ៉ាងណាក៏ដោយ នៅក្រោមវិសាលភាពនៃសវនកម្ម របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានធ្វើសវនកម្មចាប់តាំងពីចុងការិយបរិច្ឆេទនៃឆ្នាំ២០២០។ សវនករឯករាជ្យបានពិនិត្យ និងលើកបញ្ហាមួយចំនួនទាក់ទងនឹងសវនកម្មផ្ទៃក្នុង ហើយបញ្ហាសំខាន់ៗមួយចំនួនដែលលើកឡើងដោយសវនករឯករាជ្យត្រូវបានពិភាក្សាជាមួយថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាល ហើយត្រូវបានទទួលយក និងកែលម្អជាបណ្តើរៗដោយក្រុមហ៊ុនក្នុងការគ្រប់គ្រងប្រព័ន្ធផ្ទៃក្នុងរបស់ខ្លួន។

ក្រុមហ៊ុនបាននិងកំពុងរៀបចំនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងធនធានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ប្រតិបត្តិការសម្រាប់ផ្នែកនេះប្រកបដោយប្រសិទ្ធភាព។ របាយការណ៍សវនកម្មផ្ទៃក្នុងដោយសវនករផ្ទៃក្នុងនឹងត្រូវបានទទួលនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០២២ នាពេលខាងមុខ។

## គ. ការធ្វើសវនកម្ម

### ១. សវនកម្មផ្ទៃក្នុង

អង្គភាពសវនកម្មផ្ទៃក្នុង ស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់គណៈកម្មាធិការសវនកម្ម ដែលដឹកនាំដោយអភិបាលឯករាជ្យ។ ការទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុងរួមមាន ការបង្កើតផែនការសវនកម្ម និងការត្រួតពិនិត្យសវនកម្មផ្ទៃក្នុងរបស់ដំណើរការអាជីវកម្មសំខាន់ៗរបស់ក្រុមហ៊ុន ដូចខាងក្រោម÷

- បង្ហាញពីការវាយតម្លៃដែលមានតុល្យភាព និងអាចយល់បានអំពីការអនុវត្ត ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន
- រាយការណ៍អំពីដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនដោយលើកឡើងបញ្ហាដែលអាចកើតមាន
- ធានាភាពរឹងមាំនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីរក្សាផលប្រយោជន៍របស់ភាគហ៊ុនិក និងការវិនិយោគរបស់ភាគីពាក់ព័ន្ធ និងទ្រព្យសកម្មរបស់ក្រុមហ៊ុន។
- ស៊ើបអង្កេតដើម្បីវាយតម្លៃពីភាពសមស្រប និងប្រសិទ្ធិភាពនៃអភិបាលកិច្ច ប្រតិបត្តិការ និងប្រព័ន្ធព័ត៌មាន ដោយរាប់បញ្ចូលទាំងការរក្សាការពារទ្រព្យសកម្ម និងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ
- ផ្តល់ឱ្យគណៈកម្មាធិការសវនកម្ម និងបុគ្គលិកជាន់ខ្ពស់នូវរបាយការណ៍ប្រចាំឆ្នាំពាក់ព័ន្ធនឹងការអនុវត្តផែនការ និងយុទ្ធសាស្ត្រសវនកម្ម។

### ២. សវនកម្មខាងក្រៅ

| ល.រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទជ្រើសតាំង | តម្លៃសេវាសវនកម្ម | តម្លៃសេវាមិនមែនសវនកម្ម |
|---|---|---|---|---|
| ១ | Grant Thornton (Cambodai) Limited | ១២ កុម្ភៈ ២០២១ | ២៥,៦០០ | មិនមាន |

## ផ្នែកទី៥. ភាគីពាក់ព័ន្ធ

### ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោយ÷

| ល.រ | ខ្លឹមសារ | គោលនយោបាល | សកម្មភាព |
|---|---|---|---|
| ១ | សុខុមាលភាពរបស់អតិថិជន | មិនមាន | អនុលោមតាមក្រមសីលធមិ |
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់ / អ្នកម៉ៅការ | មិនមាន | |
| ៣ | ការគ្រប់គ្រង និងការការពារនិយោជិត | មិនមាន | |
| ៤ | ការគាំពារបរិស្ថាន | មិនមាន | |
| ៥ | អន្តរកម្មជាមួយសហគមន៍ | មិនមាន | |
| ៦ | ការការពារសិទ្ធិរបស់ម្ចាស់បំណុល | មិនមាន | |
| ៧ | កម្មវិធីប្រឆាំងអំពើពុករលួយ | មិនមាន | |

### ខ. ពិពណ៌នាអំពីទំនួលខុសត្រូវសង្គម

| ល.រ | អ្នកទទួលផលប្រយោជន៍ | ទំហំនៃការបរិច្ចាគ | គោលបំណងនៃការបរិច្ចាគ |
|---|---|---|---|
| ១ | សាលារៀនគៀនស្វាយ | ១,៥០៤ ដុល្លាអាមេរិក | ចូលរួមចំណែកផ្គត់ផ្គង់សម្ភារៈប្រឆាំងនឹងកូវីដ-១៩ |
| ២ | និស្សិត | មិនមាន | ផ្តល់កម្មវិធីកម្មសិក្សាដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍ |

## ផ្នែកទី៦. ការបង្ហាញព័ត៌មាន និងតម្លាភាព

### ក. បង្ហាញអំពីព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម÷

| ល.រ | ព័ត៌មាន | មាន / គ្មានបង្ហាញ |
|---|---|---|
| ១ | ចក្ខុវិស័យ / បេសកកម្ម / គោលដៅអាជីវកម្ម | មាន |
| ២ | សូចនាករហិរញ្ញវត្ថុ | មាន |
| ៣ | សូចនាករមិនមែនហិរញ្ញវត្ថុ | មាន |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មាន |
| ៥ | គោលនយោបាយភាគលាភ | មាន |
| ៦ | ជីវប្រវត្តិរបស់អភិបាល | មាន |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មិនមាន |
| ៨ | ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មាន |

*ការបណ្តុះបណ្តាលសម្រាប់អភិបាលមិនត្រូវបានបង្ហាញទេ នេះដោយសារតែ ឌី ប៊ី ឌី មិនបានរក្សាការកត់ត្រាកម្មវិធីបណ្តុះបណ្តាលអភិបាលទាំងអស់ក្នុងឆ្នាំ២០២១ ដោយសារតែ ឌី ប៊ី ឌី ទើបតែចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាផ្លូវការ នៅចុងឆ្នាំ ២០២១ ហើយ ឌី ប៊ី ឌី ទើបតែដឹងថាព័ត៌មាននេះតម្រូវឲ្យដាក់ផ្សាយ។ ព័ត៌មានបណ្តុះបណ្តាលនឹងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២២ ។*

**ខ. ពិពណ៌នាអំពីយន្តការនៃការបង្ហាញព័ត៌មាន ដោយរៀបរាប់ពីមធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន**

ក្រុមហ៊ុន ឌី ប៊ី ឌី កំពុងប្រើប្រាស់វិធីសាស្ត្របង្ហាញព័ត៌មានតាមរយៈ ផ្សារមូលបត្រកម្ពុជា (CSX) គេហទំព័រ និង Facebook Page របស់ក្រុមហ៊ុន។ ការបង្ហាញទាំងនោះរួមមានព័ត៌មានទាន់ពេល ព័ត៌មានតាមកាលកំណត់ និងព័ត៌មានស្ម័គ្រចិត្ត។ បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានរបស់ ឌី ប៊ី ឌី គឺលោកស្រី លឹម មុយលី ដែលជានាយកប្រតិបត្តិ និងប្រធានផ្នែកហិរញ្ញវត្ថុ។

## គ. ទំនាក់ទំនងជាមួយវិនិយោគិន

### ១. បង្ហាញពីយន្តការ និងនីតិវិធីនៃការទំនាក់ទំនងជាមួយវិនិយោគិន

វិនិយោគិនរបស់ ឌី ប៊ី ឌី អាចទាក់ទងទៅកាន់ ឌី ប៊ី ឌី ដូចខាងក្រោម៖

- អាស័យដ្ឋាន ដីឡូតិ៍ ៦៨ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
- អ៊ីម៉ែល: services@dbdengineering.com
- លេខទូរសព្ទ: (+៨៥៥) ០៧៨ ៧០០ ៥៩៨

### ២. ពិពណ៌នាដោយសង្ខេបអំពីទំនាក់ទំនងជាមួយនឹងវិនិយោគិនក្នុងរយៈពេល ១ (មួយ)ឆ្នាំចុងក្រោយ

មិនមានទំនាក់ទំនងនោះទេកាលពីឆ្នាំមុន ដោយសារ ឌី ប៊ី ឌី ទើបតែចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាផ្លូវការ ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០២១ នេះ។

**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង**

អាសយដ្ឋានៈ ដីឡូតិ៍ ៦៨ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ប្រទេសកម្ពុជា

អ៊ីម៉ែល: services@dbdengineering.com

គេហទំព័រ: https://dbdengineering.com

លេខទូរសព្ទ: (+៨៥៥) ០៧៨ ៧០០ ៥៩៨